# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


# សារណាបញ្ចប់ការសិក្សា

## ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០២១


តាក់តែងឡើងដោយ

និស្សិត **វ៉េង សេរីរតនា**

**គី ស៊ីវហ៊ុន**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឌុយ ចាន់ឌីណា**



ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ៥

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គី ស៊ីវហ៊ុន** និង **វ៉េង សេរីតនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៥ ឆ្នាំសិក្សា ២០១៧ - ២០១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំទាំងពីរនាក់ សូមធ្វើការគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក និងអ្នកម្ដាយរបស់យើងខ្ញុំទាំងពីរនាក់ ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ និងផ្ដល់ការឧបត្ថម្ភទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្នែករូបរាងកាយ និងស្មារតី ជាពិសេសការលើកទឹកចិត្តឱ្យមានភាពស្វាហាប់ រឹងមាំក្នុងគ្រប់កាលៈទេសៈទាំងអស់។
- លោកឯកឧត្តមសកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកនិងលោកស្រីសាស្ត្រាចារ្យទាំងអស់ដែលបានផ្ដល់នូវចំណេះដឹងតាមរយៈការណែនាំបង្រៀន ផ្ដល់ជាឧទាហរណ៍ជាក់ស្ដែងអំពីបទពិសោធន៍ក្នុងជីវិតពិត និងផ្ដល់ជាការប្រៀនប្រដៅនានាទាំងផ្នែកជំនាញរឹងនិងជំនាញទន់យ៉ាងមានតម្លៃដល់រូបយើងខ្ញុំ។
- លោកសាស្ត្រាចារ្យបណ្ឌិត **ឌុយ ចាន់ឌីណា** ដែលបានផ្ដល់ជាជំនួយក្នុងការជ្រោមជ្រែង ផ្ដល់ជាគំនិតយោបល់សម្រាប់កែប្រែស្នាដៃនៃការស្រាវជ្រាវនេះឱ្យមានភាពប្រសើរឡើង និងបញ្ចប់ដោយជោគជ័យ។
- លោកពូ អ្នកមីង និងបងប្អូនទាំងអស់ រួមទាំងមិត្តៗ ដែលជួយចូលរួមក្នុងការបញ្ចេញទស្សនៈនិងការយល់ឃើញទាក់ទងនឹងប្រធានបទរបស់យើងខ្ញុំតាមរយៈការឆ្លើយទៅនឹងកម្រងសំណួរនៅក្នុងការស្រង់មតិ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមបួងសួងដល់វត្ថុស័ក្តសិទ្ធិនៅក្នុងលោក ផ្ដល់នូវប្រសិទ្ធពរជ័យដល់លោកអ្នកទាំងអស់ឱ្យជួបប្រទះតែសេចក្ដីសុខ សេចក្ដីចម្រើន កុំបីអាក់ខានឡើយ ជាពិសេសសូមជួបប្រទះនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ជារាងដរាបតទៅ។

# ,អារម្ភកថា

*ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ* ជាការសិក្សាស្រាវជ្រាវមួយដែលទាក់ទងទៅនឹងដំណើរការនៃការអភិវឌ្ឍន៍សង្គមតាមរយៈការពង្រីកសក្តានុពលធនធានមនុស្សដោយចាប់ផ្តើមចេញពីការពង្រឹងសមត្ថភាពចំណេះដឹង និងការផ្តល់អំណាចទៅដល់ស្ត្រី ដើម្បីឱ្យស្ត្រីមានឱកាសនិងលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងជោគវាសនារបស់ខ្លួនដែលទាក់ទងទៅនឹងរបៀបរបបនៃការរស់នៅ កម្រិតសិក្សា និងកម្រិតជីវភាពឱ្យមានភាពសមប្រកប មុននឹងក្លាយខ្លួនជាតួអង្គដែលចង្កូតដ៏សំខាន់ ក្នុងការរួមចំណែកជួយសហគមន៍ឱ្យមានភាពរីកចម្រើនក្រោមរូបភាពជាទំពជួរក្រោយ ដោយទទួលរ៉ាប់រងទៅលើកិច្ចការបង្កើតនិងបណ្តុះបណ្តាលធនធានមនុស្សការងារសង្គមកិច្ចនិងសេដ្ឋកិច្ចទាំងក្នុងនិងក្រៅប្រព័ន្ធផងដែរ។ ម្យ៉ាងវិញទៀត ការសិក្សាទៅលើប្រធានបទនៃការអភិវឌ្ឍន៍ស្ត្រីនៅតំបន់ជនបទនេះក៏អាចឱ្យយើងបានដឹងអំពីឧបសគ្គនិងដំណោះស្រាយមួយចំនួនដែលគេប្រើប្រាស់ដើម្បីយកឈ្នះទៅលើរបាំងដែលរាំងស្ទះទៅលើការអភិវឌ្ឍស្ត្រីមានដូចជា ផ្នត់គំនិត ប្រពៃណី ទំនៀមទម្លាប់ ពេលវេលា និងគម្លាតនៃស្តង់ដារស់នៅ ដែលសុតសឹងជារនាំងរាំងខ្ទប់ស្ត្រីមិនឱ្យទទួលបានឱកាសក្នុងការបញ្ចេញនិងប្រើប្រាស់ទេពកោសល្យរបស់ខ្លួនឱ្យបានពេញលេញ និងនៅដាច់ឆ្ងាយពីសង្គមដែលមានភាពស៊ីវីល័យ។

អាស្រ័យដោយហេតុផលខាងលើនេះហើយ ទើបយើងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទ "ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ" មកធ្វើជាសារណាបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបន្សល់ទុកជាស្នាដៃសម្រាប់និស្សិតជំនាន់ក្រោយសិក្សាស្វែងយល់នៅថ្ងៃខាងមុខ។ យើងខ្ញុំមានការប្រាកដក្នុងចិត្តថា ស្នាដៃឯកសារស្រាវជ្រាវនេះអាចសិក្សាបានត្រឹមតែមួយផ្នែកតូច និងមិនទាន់មានលក្ខណៈឥតខ្ចោះនោះទេ ពីព្រោះការស្រាវជ្រាវនិងប្រមូលឯកសារយោងនិងទិន្នន័យមកចងក្រងជួបប្រទះនូវភាពលំបាកដោយសារបញ្ហានៃជំងឺរាតត្បាតកូវីត១៩ បាននឹងកំពុងរីកសាយភាយយ៉ាងរឹករវក្នុងកំឡុងពេលដែលយើងខ្ញុំដំណើរការរៀបចំឯកសារស្រាវជ្រាវនេះ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំទាំងពីរនាក់នៅតែបន្តប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីតាក់តែងអត្ថបទស្រាវជ្រាវនេះឱ្យមានលក្ខណៈសាមញ្ញ ងាយស្រួលយល់ និងអាចទទួលយកបានពីសំណាក់អ្នកអានទាំងអស់។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោកអ្នកនឹងភាពរីករាយនិងអាចទទួលយកចំណេះដឹងមួយចំនួនចេញពីក្នុងការសិក្សានេះ។ យើងខ្ញុំនឹងទទួលយកនូវមតិកែលំអរមកលើកំហុសឆ្គងក្នុងការរៀបចំពាក្យពេចន៍ អត្ថបទ ឬខ្លឹមសារក្នុងចំណុចណាមួយដែលមានភាពខ្វះចន្លោះដោយក្តីសោមនស្ស។ ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចំណាយពេលអានការសិក្សាស្រាវជ្រាវនេះ និងសូមជូនពរឱ្យលោកអ្នកមាន សុខភាពល្អ សុវត្ថិភាព និងសុភមង្គល។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម

១. លំនាំដើមនៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. វិធីសាស្ត្រស្រាវជ្រាវ ........ ២
**៤.១ ទិន្នន័យចំបង** ........ ២
**៤.២ ទិន្នន័យបន្ទាប់បន្សំ** ........ ២
៥ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
៦ សារសំខាន់នៃការស្រាវជ្រាវ ........ ៣
៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី១
## ការសិក្សាលើទ្រឹស្តី ពាក់ព័ន្ធនឹងការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ

១.១ និយមន័យ ........ ៤
១.១.១ និយមន័យនៃការអភិវឌ្ឍ ........ ៤
១.១.២ និយមន័យស្ត្រី ........ ៥
១.១.៣ និយមន័យនៃការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ ........ ៥
១.២ ទស្សនៈផ្សេងៗទាក់ទងនឹងការអភិវឌ្ឍ ........ ៥
១.២.១ ទ្រឹស្តីនៃការអភិវឌ្ឍ ........ ៥
១.៣. ទស្សនៈវិស័យនៃការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ ........ ៦
១.៣.១ គោលបំណងនៃការអភិវឌ្ឍស្ត្រីនៅជនបទ ........ ៧
១.៣.២ គោលដៅក្នុងការអភិវឌ្ឍ ........ ៧
១.៣.៣ មូលហេតុនៃការអភិវឌ្ឍស្ត្រីនៅជនបទ ........ ៨

១.៤ គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍស្ត្រីនៅជនបទ ........ ៨
១.៤.១ យុទ្ធសាស្ត្រនារីរតនៈ ........ ៨
១.៤.២ គោលនយោបាយពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម ........ ១០
១.៤.៣. យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ........ ១១
១.៥ ទិសដៅក្នុងការអភិវឌ្ឍស្ត្រីក្នុងតំបន់ជនបទ ........ ១២
១.៥.១ ទិសដៅបង្កើនលទ្ធភាពដល់ស្ត្រីនៅជនបទ ........ ១២
១.៥.២ ទិសដៅលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខមាលភាព ........ ១៣
១.៥.៣ ទិសដៅលើកកម្ពស់ការអប់រំ ........ ១៣
១.៥.៤ ទិសដៅបញ្ចប់ភាពខ្វះខាត ........ ១៣

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ស្ត្រីនៅជនបទ

២.១ ស្ថានភាពទូទៅ ........ ១៥
២.១.១ ចរឹកលក្ខណៈ ........ ១៥
២.១.២ ផ្នត់គំនិត ........ ១៥
២.១.៣ ជីវភាព ........ ១៦
២.១.៤ ការអប់រំ និងទស្សនៈ ........ ១៦
២.១.៥ ការចូលរួមចំណែកក្នុងកិច្ចការសង្គម និងសេដ្ឋកិច្ច ........ ២១
២.១.៦ គម្លាតស្តង់ដារនៃជីវភាពរស់នៅរវាងស្ត្រីនៅជនបទ និងទីក្រុង ........ ២២
២.២. របាំងរារាំងដល់ការអភិវឌ្ឍ ........ ២៤
២.២.១ កត្តាផ្នត់គំនិត ........ ២៤
២.២.២ កត្តាប្រពៃណី និងទំនៀមទំលាប់ ........ ២៦
២.២.៣ កត្តាសេដ្ឋកិច្ច និងពេលវេលា ........ ២៧
២.២.៤. កត្តាកង្វះការលើកទឹកចិត្ត ........ ២៧
២.៣ មូលហេតុដែលទាមទារឲ្យមានការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ ........ ២៨
២.៣.១ ការកសាងធនធានមនុស្ស ........ ២៩
២.៣.២ ឱកាសក្នុងការបញ្ចេញសក្តានុពលពីខាងក្នុង ........ ៣០

២.៣.៣ ស្ត្រី និងភាពជាអ្នកដឹកនាំ.......... ៣១
២.៣.៤ ការកែលម្អ ពង្រឹងនិងអភិវឌ្ឍន៍សមត្ថភាព.......... ៣២
២.៣.៥ កាត់បន្ថយគំលាតស្តង់ដារនៃការរស់នៅ.......... ៣៥
២.៤ មធ្យោបាយក្នុងការអភិវឌ្ឍស្ត្រីនៅជនបទ.......... ៣៦
២.៤.១ ការអប់រំបណ្តុះបណ្តាល និងវិជ្ជាជីវៈ.......... ៣៦
២.៤.២. ការអភិវឌ្ឍលើវិស័យកសិកម្ម.......... ៤០
២.៤.៣ ការអភិវឌ្ឍលើវិស័យឧស្សាហកម្ម.......... ៤១
២.៤.៤ ការបង្កើតការងារ និងលក្ខខណ្ឌការងារដែលល្អប្រសើរជាងមុន.......... ៤២
២.៤.៥ ការកាត់បន្ថយការចំណាយខ្ពស់ សម្រាប់ឥណទានជនបទ.......... ៤៣

**ជំពូកទី៣**

**ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ**

៣.១. ទិន្នន័យនៃការស្រង់មតិ.......... ៤៤
៣.១.១. ការវិភាគបែបពិពណ៌នា.......... ៤៤
៣.១.២. ការវិភាគលើឥទ្ធិពលនៃការអភិវឌ្ឍទៅលើសង្គម និងសេដ្ឋកិច្ច.......... ៤៧

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

១. សេចក្តីសន្និដ្ឋាន.......... ៥០
២. អនុសាសន៍.......... ៥១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១. លំនាំដើមនៃការស្រាវជ្រាវ

តាំងពីសម័យបុរាណកាល ស្ត្រី បំពេញតួនាទីមួយផ្នែកធំក្នុងការរួមចំណែកកសាងសង្គមឱ្យមានស្ថិរភាពនិងរីកចម្រើនតាមរយៈការបង្កើតធនធានមនុស្ស និងជួយទំនុកបម្រុងលើការបង្ហាត់បង្ហាញមនុស្សជំនាន់ថ្មីទាំងនោះទាក់ទងនឹងផ្នែកឥរិយាបថ សីលធម៌ វិជ្ជាមេផ្ទះ និងចរិយាមាយាទ ដើម្បីឱ្យពួកគេក្លាយជាធនធានដែលទ្រង់ទ្រង់សង្គមផ្អែកលើផ្នែកសុជីវធម៌។ លុះមកដល់សម័យបច្ចុប្បន្ន ដោយរបត់សង្គមមានការប្រែប្រួល តួនាទីរបស់ស្ត្រីត្រូវបានបន្ថែមពីលើការងារគោលជានាយិកាគ្រប់គ្រងផ្ទះមួយជាន់ទៀតគឺ ការចេញទៅខាងក្រៅប្រឡូកចូលទៅក្នុងការងារសង្គមនិងសេដ្ឋកិច្ច ដែលជាហេតុផលមួយទាមទារឱ្យមានការអភិវឌ្ឍន៍ទៅលើផ្នែកសមត្ថភាពរបស់ស្ត្រីនិងការផ្ដល់ឱកាសឱ្យនារីៗទទួលបាននូវសមភាពក្នុងការពង្រឹងខ្លួនឱ្យកាន់តែរឹងមាំ និងមានឯករាជ្យភាពពេញលេញក្នុងការជ្រើសរើសយករបៀបរបបគ្រប់គ្រងជីវិតរបស់ខ្លួនតាមការចង់បាន។ ប៉ុន្តែ ដោយសារការអភិវឌ្ឍន៍មិនអាចធ្វើទៅបានស្មើគ្នារវាងតំបន់នីមួយៗ ស្ត្រីដែលរស់នៅជនបទហាក់មានការរស់នៅមួយដែលស្រដៀងទៅនឹងស្ត្រីដែលរស់នៅជំនាន់បុរាណ ខុសគ្នាស្ទើរតែទាំងស្រុងពីស្ត្រីដែលរស់នៅតំបន់ទីប្រជុំជនមានការធ្វើទំនើបកម្ម។

ជាក់ស្ដែង នៅក្នុងតថភាពសង្គមរបស់ប្រទេសកម្ពុជាផ្ទាល់យើងសង្កេតឃើញថា ជាទូទៅស្ត្រីដែលរស់នៅតំបន់ដាច់ស្រយ៉ាលទទួលរងនូវបន្ទុកនិងភាពលំបាកជាច្រើនក្នុងការរស់នៅ ដែលបញ្ហាទាំងអស់នោះពាក់ព័ន្ធជាមួយនឹងសកម្មភាពមួយចំនួនដូចជា ការទទួលរងអំពើហឹង្សាទាំងផ្នែកផ្លូវកាយនិងផ្លូវចិត្ត កង្វះចំណេះដឹងដោយសារការរៀនសូត្រមិនបានវែងឆ្ងាយ បោះបង់ការសិក្សាចោល ជីវភាពរស់នៅទាប ត្រូវរ៉ាប់រងទំនួលខុសត្រូវទៅលើការងារមេផ្ទះ និងមិនសូវទទួលបានការផ្ដល់តម្លៃទៅលើកិច្ចការដែលពួកគេបានធ្វើ។ បញ្ហាទាំងអស់នេះហើយជាហេតុផលដែលធ្វើឱ្យស្ត្រីមួយចំនួនធំនៅក្នុងប្រទេសកម្ពុជាទទួលរងនូវគំនាប និងមិនមានទំនុកចិត្តក្នុងការបញ្ចេញមតិនិងបន្តដំណើរស្វែងរកអ្វីក្ដីសុបិន្តរបស់ខ្លួន ជាពិសេសគឺការកំណត់នូវស្ដង់ដាជីវិតរស់នៅប្រចាំថ្ងៃឱ្យមានលក្ខណៈប្រសើរឡើងជាងមុន។ ដោយសារមើលឃើញពីបញ្ហាទាំងនេះហើយ ទើបការអភិវឌ្ឍស្ត្រីក្លាយជាប្រធានបទមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពិនិត្យឱ្យបានច្រើនបំផុត ដើម្បីធ្វើយ៉ាងណាឱ្យស្ត្រីដែលរស់នៅតំបន់ឆ្ងាយៗអាចមានឱកាសក្នុងការទទួលយកការធ្វើទំនើបកម្មផ្នែកស្មារតីតាមរយៈការបណ្ដុះបណ្ដាលទៅលើចំណេះដឹង ជំនាញ និងសតិបញ្ញា ដើម្បីឱ្យស្ត្រីអាចទទួលបាននូវសមភាពក្នុងការរស់នៅ អាចបញ្ចេញទេពកោសល្យចូលរួមទៅក្នុងកិច្ចការផ្សេងៗ និងជាពិសេសអាចវិវត្តន៍ខ្លួនឱ្យក្លាយជាមាតាគំរូនិងជាកម្លាំងចលករដ៏មានសក្ដានុពលសម្រាប់សង្គមជាតិ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការអភិវឌ្ឍស្ត្រីជាគន្លឹះដ៏សំខាន់ក្នុងការធ្វើឱ្យស្ត្រីទទួលបាននូវសមភាព និងការពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការកែប្រែជីវភាពរស់នៅ និងអាចចូលរួមក្នុងកិច្ចការសង្គមនិងសេដ្ឋកិច្ចផងដែរ។

តើការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទអាចសម្រេចបានដោយរបៀបណា? ជួបនឹងឧបសគ្គអ្វីខ្លះ? ហើយតើគេគួរចាត់វិធានការបែបណាដើម្បីឱ្យគោលដៅនៃការអភិវឌ្ឍស្ត្រី អាចទទួលបានលទ្ធផលគាប់ប្រសើរ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវអំពី "ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទនេះ" មានគោលបំណងក្នុងការអភិវឌ្ឍន៍និងលើកកំពស់ស្ត្រីដោយផ្តោតទៅលើកម្មវត្ថុ ៣ ដូចខាងក្រោម៖

- លើកកំពស់ស្តង់ដាជីវភាពរស់នៅរបស់ស្ត្រីនៅតំបន់ជនបទ
- កែប្រែទស្សនៈ និងការយល់ឃើញរបស់ស្ត្រីខ្លួនឯងឱ្យមានលក្ខណៈទូលំទូលាយ និងទំនើបជាងមុន
- លើកកំពស់ការចូលរួមរបស់ស្ត្រីនៅក្នុងសង្គម។

## ៤. វិធីសាស្ត្រស្រាវជ្រាវ

អត្ថបទកិច្ចការស្រាវជ្រាវនេះបាន យើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបចម្រុះរវាងវិធីសាស្ត្រគុណវិស័យនិងបរិមាណវិស័យ ដែលមានការប្រើប្រាស់ផ្នែកគុណវិស័យច្រើនជាងបរិមាណវិស័យ។

- វិធីសាស្ត្របរិមាណវិស័យ៖ ជាវិធីសាស្ត្រក្នុងការស្រាវជ្រាវដោយផ្តោតទៅលើបញ្ហាមិនមែន ជាតួសលេខ ដើម្បីយល់ពីយោបល់ឬបទពិសោធន៍។
- វិធីសាស្ត្របរិមាណវិស័យ៖ ជាវិធីសាស្ត្រក្នុងការស្រាវជ្រាវតាមរយៈតួលេខ អាចកំណត់បាន ឬវាស់បាន និងអនុវត្តតាមវិធីគណិតវិទ្យា ឬបច្ចេកទេសគណនាផ្សេងៗ។

ហើយដើម្បីអាចឱ្យការស្រាវជ្រាវនេះដំណើរការទៅបានយើងខ្ញុំបានធ្វើការប្រមូលព័ត៌មានមកពីប្រភពទិន្នន័យពីរប្រភេទគឺ **ទិន្នន័យចំបង** (Primary data) **និង ទិន្នន័យបន្ទាប់បន្សំ** (Secondary data) ៖

**៤.១ ទិន្នន័យចំបង៖** បានមកតាមរយៈការធ្វើកម្រងសំណួរអង្កេតតាមប្រព័ន្ធអេឡិចត្រូនិច ដោយយើងខ្ញុំពុំបានចុះទៅកាន់តំបន់មូលដ្ឋានធ្វើការសម្ភាសន៍ផ្ទាល់ឡើយ ដោយសារបញ្ហាជំងឺរាតត្បាតកូវីត១៩ កំពុងមានស្ថានភាពរីករ ដែលធ្វើឱ្យយើងខ្ញុំត្រូវធ្វើការទំនាក់ទំនងពីចម្ងាយដើម្បីការពារការរាតត្បាតនៃជំងឺនេះជាយថាហេតុ។

**៤.២ ទិន្នន័យបន្ទាប់បន្សំ៖** ចំពោះទិន្នន័យនេះ យើងខ្ញុំបានធ្វើការប្រមែប្រមូលមកពីប្រភពគេហទំព័រផ្សេងៗតាមរយៈប្រព័ន្ធអ៊ីនធឺណេតដើម្បីសិក្សាស្រាវជ្រាវបន្ថែម មានដូចជាគេហទំព័រធនាគារពិភពលោក

ធនាគារអភិវឌ្ឍអាស៊ី ឯកសាររបស់រាជរដ្ឋាភិបាលកម្ពុជា វិទ្យាស្ថានស្ថិតិជាតិ និងគេហទំព័រក្នុងស្រុកនិងគេហទំព័របរទេសមួយចំនួនទៀត។

## ៥ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអំពីប្រធានបទ ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ បានលើកឡើងអំពីស្ថានភាពរបស់ស្ត្រីដែលរស់នៅក្នុងប្រទេសកម្ពុជាគិតពីត្រឹមឆ្នាំ ២០១៤ ដល់ ២០១៨ ដោយផ្តោតទៅលើកត្តាសំខាន់ៗមួយចំនួនដូចជា ការសិក្សាអប់រំ កម្រិតជីវភាពស្តង់ដារស់នៅ ការចូលរួមក្នុងកិច្ចការសហគមន៍និងសេដ្ឋកិច្ច ព្រមទាំងសិក្សាអំពីបញ្ហាប្រឈមនានាដែលរាំងស្ទះស្ត្រីក្នុងការឈោងចាប់ឱកាសអភិវឌ្ឍន៍ខ្លួនដោយយោងទៅតាមទិដ្ឋភាពសង្គមជាក់ស្តែង និងដំណោះស្រាយសម្រាប់ស្ត្រីទៅលើបញ្ហានៃវិសមភាពក្នុងការអភិវឌ្ឍនេះ។

## ៦ សារសំខាន់នៃការស្រាវជ្រាវ

ឯកសារស្រាវជ្រាវអំពី "ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ" នឹងផ្តល់នូវអត្ថប្រយោជន៍ដូចជា៖

- អាចស្វែងយល់ពីស្ថានភាពស្ត្រីដែលរស់នៅតំបន់ជនបទ
- យល់ដឹងអំពីកត្តារាំងស្ទះ ដែលធ្វើឱ្យស្ត្រីពិបាកក្នុងការទទួលបានការអភិវឌ្ឍ
- យល់ដឹងអំពីសក្តានុពលរបស់ស្ត្រីក្នុងការចូលរួមលើកិច្ចការផ្សេងៗ
- ទទួលបានចំណេះដឹងបន្ថែមអំពីដំណោះស្រាយនានា ដែលរាជរដ្ឋាភិបាលបានដាក់ចេញសម្រាប់លើកកំពស់ស្ត្រី
- ផ្តល់ជាគំនិតក្នុងការលើកកំពស់គោលការណ៍សមភាពយេនឌ័រ និងលើកស្ទួយស្ត្រី
- យល់ដឹងអំពីសារសំខាន់នៃការអភិវឌ្ឍស្ត្រី។

## ៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទ "ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ" ត្រូវបានបែងចែកជា៣ជំពូកដូចតទៅ៖

សេចក្តីផ្តើម

ជំពូកទី១៖ រំលឹកទ្រឹស្តី ការអភិវឌ្ឍនិងស្ត្រី

ជំពូកទី២៖ ស្ថានភាពទូទៅរបស់ស្ត្រីនៅតំបន់ជនបទ

ជំពូកទី៣៖ ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី១

# ការសិក្សាលើទ្រឹស្តីពាក់ព័ន្ធនឹងការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ

# ជំពូកទី១

# ការសិក្សាលើទ្រឹស្តី ពាក់ព័ន្ធនឹងការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ

## ១.១ និយមន័យ

### ១.១.១ និយមន័យនៃការអភិវឌ្ឍ

**ការអភិវឌ្ឍ**ត្រូវបានគេឲ្យនិយមន័យខុសៗគ្នាទៅតាមសម័យកាលនីមួយៗក្នុងការសិក្សាស្រាវជ្រាវ។ ប៉ុន្តែទោះបីជាមាននិយមន័យច្រើនផ្សេងៗគ្នាយ៉ាងណាក៏ដោយ ក៏វាផ្តោតទៅលើចំណុចគោលនៃការអភិវឌ្ឍ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរ រីកចម្រើនជាងមុន និងជឿនលឿនជាងមុន។ ដូចនេះពាក្យ អភិវឌ្ឍ ត្រូវបានគេអោយក្នុងអត្ថន័យផ្សេងៗគ្នាដូចជា៖

**ការអភិវឌ្ឍ**៖ គឺជាការកើនឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាជន ការបង្កើត ពង្រីកចំណូល និងឱកាសការងារក្នុងតំបន់។

**ការអភិវឌ្ឍ**៖ គឺសំដៅលើការកែលំអរស្ថានភាពសេដ្ឋកិច្ច ការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើតទ្រព្យសម្បត្តិនិងជីវិតប្រជាជន។

**ការអភិវឌ្ឍ**៖ គឺជាការផ្សារភ្ជាប់ទៅនឹងការកើនឡើងនៃផលិតភាពពលកម្ម កម្រិតចំនេះដឹងរបស់ប្រជាជន ការផ្លាស់ប្តូរបទពិសោធន៍ និងការអប់រំរបស់ប្រជាជនទូទៅ។

**ការអភិវឌ្ឍ**៖ គឺជាចលនាវិវត្តន៍ពីស្ថានភាពមួយទៅស្ថានភាពមួយទៀតដែលប្រសើរជាងមុន។

ការអភិវឌ្ឍអាចស្តែងចេញតាមមាត្រដ្ឋានចំនួន ៥គឺ៖

១. **មាត្រដ្ឋានសេដ្ឋកិច្ច៖** ការអភិវឌ្ឍគឺជាកំណើនសេដ្ឋកិច្ចដែលត្រូវផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចដោយកែលំអរ និងពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធថាមពល ប្រព័ន្ធផ្គង់ផ្គង់ទឹក ការពង្រីកវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងសេវាកម្មផ្សេងៗ ទៀត។

**២. មាត្រដ្ឋានសង្គម៖** ការអភិវឌ្ឍគឺជាការផ្លាស់ប្តូរផ្នែកសង្គមកិច្ចដូចជា សមធម៌ និងយុត្តិធម៌តាមរយៈការកាត់បន្ថយភាពក្រីក្រដោយធ្វើយ៉ាងណាឲ្យគំលាតរវាងអ្នកមាននិងអ្នកក្រសមល្មមអាចទទួលយកបាន លើកកម្ពស់នារីភេទ ជាពិសេសធានាបាននូវសមភាពយេនឌ័ររវាងបុរស និងស្ត្រីក្នុងសង្គម។

**៣. មាត្រដ្ឋាននយោបាយ៖** ការអភិវឌ្ឍត្រូវបានស្ថិតនៅក្នុងបរិស្ថាននយោបាយសមស្របសម្រាប់ជំរុញវឌ្ឍនភាពសង្គមតាមច្បាប់ និងធានានូវការគោរពសិទ្ធិមនុស្ស។

**៤. មាត្រដ្ឋានបរិស្ថាន៖** ការអភិវឌ្ឍត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃការយកចិត្តទុកដាក់ ថែរក្សាគុណភាពបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិឲ្យបានឋិតថេរ។

**៥. មាត្រដ្ឋានធនធានមនុស្ស៖** ការអភិវឌ្ឍផ្សារភ្ជាប់នឹងការកើនឡើងនៃផលិតភាពពលកម្ម

និងកម្រិតចំនេះដឹងរបស់ប្រជាជន ការផ្លាស់ប្តូរបទពិសោធន៍ និងបច្ចេកទេស ការផ្តល់សេវាសុខភាពសាធារណៈ និងការអប់រំសម្រាប់ប្រជាជនទូទៅ។

### ១.១.២ និយមន័យស្ត្រី

**ស្ត្រី** គឺជាកម្លាំងចលករដ៏មានសក្តានុពល និងជាភាគីពាក់ព័ន្ធដ៏សម្ខាន់មិនអាចខ្វះបាន ហើយបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការលើកស្ទួយកម្រិតជីវភាពគ្រួសារ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**ស្ត្រី** គឺជាមនុស្សដែលមានភេទដទៃពីបុរស។

### ១.១.៣ និយមន័យនៃការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ

ការអភិវឌ្ឍស្ត្រីនៅជនបទ គឺជាដំណើរការនៃការធ្វើឱ្យមានភាពរីករចម្រើនតាមរយៈការលើកកម្ពស់ និងផ្តល់ឱកាសដល់ស្ត្រីឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការកសាងសមត្ថភាព ជីវភាព និងកែប្រែស្តង់ដាកម្រិតជីវភាពរបស់ខ្លួនឱ្យមានលក្ខណៈរីកចម្រើនជាងមុន កាត់បន្ថយវិសមភាពយេនឌ័រនិងបង្រួមគម្លាតការរស់នៅរបស់ស្ត្រីនៅតំបន់ជនបទនិងទីក្រុង។

## ១.២ ទស្សនៈផ្សេងៗទាក់ទងនឹងការអភិវឌ្ឍ

### ១.២.១ ទ្រឹស្តីនៃការអភិវឌ្ឍ

ការអភិវឌ្ឍ មានអត្ថន័យទូលំទូលាយណាស់ ពីព្រោះការអភិវឌ្ឍស្តែងចេញពីការធ្វើឱ្យមានប្រសើរឡើងនៅក្នុងការរស់នៅ មិនតែប៉ុននោះន័យរបស់ការអភិវឌ្ឍក៏មានការផ្លាស់ប្តូរទៅតាមសម័យកាលនិងការប្រើប្រាស់ផងដែរ។ ដូច្នេះហើយ ដើម្បីយល់ពីនិយមន័យការអភិវឌ្ឍឱ្យបានច្បាស់ យើងគួរពិនិត្យមើលទៅលើទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួនដូចតទៅៈ

- **ទ្រឹស្តីលោក** Walt Whitman Rostow

ដោយយោងទៅតាមទស្សនៈ លោក Walt Whitman Rostow បានបង្ហាញថា ការអភិវឌ្ឍ គឺសំដៅលើទំនាក់ទំនងនឹងការបំលាស់ប្តូរពីជីវិតរស់នៅបែបប្រពៃណី ទៅកាន់ជីវិតមួយបែបដែលទំនើប ដែលមានរបៀបរស់នៅល្អប្រសើរជាងមុននាពេលអនាគត។ ក្នុងទ្រឹស្តីនេះ ក៏បានបែងចែកជាបួនដំណាក់កាលដោយលោកបានអះអាងថាគ្រប់ប្រជាជាតិទាំងអស់អាចឈានទៅដល់ចំណុចអភិវឌ្ឍបានរួមមាន

**ក. ដំណាក់កាលបែបប្រពៃណីៈ** គឺជាសង្គមដែលគ្មានកំណើនទាល់តែសោះ ដោយប្រជាជនប្រកបរបរកសិកម្ម ជាលក្ខណៈគ្រួសារ ចិញ្ចឹមសត្វ និងការរស់នៅបែបប្រមូលផ្តុំ ហើយធ្វើការផលិតឡើងតាមបែបរៀងៗខ្លួន។

**ខ. ដំណាក់កាលធ្វើឲ្យមានការអភិវឌ្ឍ៖** គឺជាដំណាក់កាលធ្វើឲ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ការធ្វើឲ្យប្រសើរឡើងផ្នែកបច្ចេកវិទ្យា និងការធ្វើឲ្យប្រជាជនមានភាពជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ព្រមទាំងធ្វើឲ្យមានការកើនឡើងនៃអត្រាសន្សំវិនិយោគមកលើប្រទេសដែលស្ថិតនៅអន្តរកាលនៃការអភិវឌ្ឍ។

**គ. ដំណាក់កាលការកើនឡើងនៃការអភិវឌ្ឍ៖** គឺជាការកើនឡើងនូវភាពខ្លាំងនៃអត្រាអទិភាពនយោបាយ ស្ថាប័នដែលនាំឲ្យមានកំណើន។ ប្រទេសដែលអាចចាត់ទុកថាមានឧស្សាហកម្មថ្មីមានពីរចំនុចគឺ៖

- វិស័យអាទិភាពនៃសេដ្ឋកិច្ចមានការកើនឡើង និងរីកធំធាត់ជាលំដាប់
- កំណើនសេដ្ឋកិច្ចត្រូវបានក្លាយទៅជាបញ្ហាសាមញ្ញ និងអាចរក្សាបានដោយស្វ័យប្រវត្តិនៃស្ថិរភាពសេដ្ឋកិច្ច។

**ឃ. ដំណាក់កាលពីបំរាស់៖** គឺជាការផលិតទំនិញ និងសេវាកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយ។ ដំណាក់កាលនេះបានធ្វើឲ្យអំណាចសេដ្ឋកិច្ចត្រូវបានពង្រីកក្នុងពេលដែលមានការអភិវឌ្ឍសេដ្ឋកិច្ចលើវិស័យសុខុមាលភាពសង្គម និងមានសេចក្តីត្រូវការជាមូលដ្ឋានដែលត្រូវបានដោះស្រាយបានជាស្ថាពរ។

- **ទ្រឹស្តីលោក** W. Arthur Lewis

បើយោងតាមទ្រឹស្តីរបស់លោក W. Arthur Lewis បានឲ្យនិយមន័យ ការអភិវឌ្ឍថាជាការផ្លាស់ប្តូរនូវអ្វីដែលជាភាពចាំបាច់ដំបូង រឺការផ្លាស់ប្តូររចនាសម្ព័ន្ធ សម្រាប់តម្រូវការមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

- **ទ្រឹស្តីលោក** Michael P.Todaro

បើយោងតាមទ្រឹស្តីលោក Michael P.Todaro ឱ្យអត្ថន័យលើពាក្យអភិវឌ្ឍថា ការអភិវឌ្ឍអាចកើតឡើងបានគឺត្រូវចាប់ផ្តើមពីសហគមន៍ក្នុងតំបន់ជនបទ ជាពិសេសក្នុងវិស័យកសិកម្មហើយប្រទេសមួយឈានដល់ការអភិវឌ្ឍត្រូវមានបីចំណុចដូចខាងក្រោម៖

- ពន្លឿនការនាំចេញ តាមរយៈការធ្វើកំណែទម្រង់ស្ថាប័ន និងបច្ចេកវិទ្យាដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតភាពសម្រាប់កសិករតូចតាច។
- បង្កើនតម្រូវការក្នុងស្រុកសម្រាប់ផលិតផលកសិកម្មដែលមានប្រភពច្បាស់លាស់មកពីយុទ្ធសាស្ត្រអភិវឌ្ឍការងារក្នុងតំបន់សហគមន៍។
- សកម្មភាពអភិវឌ្ឍជនបទដើម្បីពង្រីកកម្លាំងពលកម្ម និងវិស័យផ្សេងៗទៀតដែលគាំទ្រដោយផ្ទាល់ឬដោយប្រយោលពីស្ថាប័នពាក់ព័ន្ធ។

## ១.៣. ទស្សនៈវិស័យនៃការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ

ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ ជាការធ្វើយ៉ាងណាឱ្យស្ត្រីដែលរស់នៅតាមតំបន់ដាច់ស្រយ៉ាល អាចមានឱកាសក្នុងការទទួលបានការអភិវឌ្ឍខ្លួនលើផ្នែកសមត្ថភាព ជំនាញ ដើម្បីពង្រឹងខ្លួនឱ្យក្លាយជាធនធាន

មនុស្សដ៏ពូកែក្នុងការកែប្រែស្ថានភាពរស់នៅរបស់ខ្លួនឱ្យមានភាពសមប្រកប និងអាចបញ្ចេញសក្តានុពលពីក្នុងខ្លួនចូលរួមទៅក្នុងការកិច្ចការសង្គមនិងសេដ្ឋកិច្ច។

### ១.៣.១ គោលបំណងនៃការអភិវឌ្ឍស្ត្រីនៅជនបទ

គោលបំណងនៃការអភិវឌ្ឍស្ត្រីនៅជនបទ គឺដើម្បីដោះស្រាយនូវរាល់បញ្ហាដែលទាក់ទងនឹងការលំបាកដែលស្ត្រីតែងតែជួបប្រទះក្នុងការរស់នៅ និងរួមចំណែកលើកកម្ពស់ស្ត្រីព្រមទាំងជម្រុញបន្ថែមដើម្បីឲ្យមានការចូលរួមវត្តមានស្ត្រីក្នុងសង្គម ព្រមទាំងជំរុញឲ្យមានការអភិវឌ្ឍតំបន់ជនបទ ឲ្យមានការរីកចម្រើនលើសុខុមាលភាពសាធារណៈ ការរស់នៅប្រសើរជាងមុន។ ដូចនេះហើយទើបរដ្ឋាភិបាលបានបង្កើនការយកចិត្តទុកដាក់ខ្លាំងលើការអភិវឌ្ឍតំបន់ជនបទ ជាពិសេសស្ត្រីផ្ទាល់តែម្តង។

ការអភិវឌ្ឍមានគោលបំណងបីគឺៈ

- ដើម្បីឆ្ពោះទៅកាន់ការកាត់បន្ថយភាពក្រីក្រ ភាពមិនស្មើគ្នាក្នុងសង្គម និងភាពឥតការងារធ្វើ
- ផ្តល់ជូនកម្រិតរស់នៅមួយខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន នូវលើវិស័យអប់រំ សុខភាព ទីជម្រក និងស្បៀងអាហារ
- ផ្តល់នូវឱកាស ទាំងផ្នែកសេដ្ឋកិច្ច (Economic Opportunity) និងសង្គម (Social Opportunity) ។
    - ✓ ឱកាសសេដ្ឋកិច្ច (Economic Opportunity) គឺជាការផ្តល់ជូននូវឱកាសដើម្បីវិនិយោគ ដើម្បីបង្កើតទ្រព្យ ពង្រីកអាជីវកម្ម ដោយផ្តល់ឱកាសឲ្យសហគ្រិនទទួលបាននូវកម្ចីបង្កើតជាអាជីវកម្មខ្នាតតូច និងឱកាសក្នុងការស្វែងរកការងារធ្វើ។
    - ✓ ឱកាសសង្គម (Social Opportunity) គឺជាការផ្តល់ឱកាសដើម្បីចូលរួមក្នុងសកម្មភាពនយោបាយ ឱកាសដើម្បីបញ្ចេញយោបល់ជាសាធារណៈ និងចូលរួមក្នុងការអភិវឌ្ឍនយោបាយ។

### ១.៣.២ គោលដៅក្នុងការអភិវឌ្ឍ

ការអភិវឌ្ឍមានគោលដៅបីយ៉ាងសំខាន់ៗគឺៈ

- ○ ពង្រីក និងបង្កើននូវការបែងចែកសេចក្តីត្រូវការជាមូលដ្ឋានមានដូចជា អាហារ ជម្រក សម្លៀកបំពាក់ សុខភាពនិងការគាំពារ
- ○ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ○ ពង្រីកនិងផ្តល់នូវជម្រើសសេដ្ឋកិច្ច និងសង្គមទៅដល់បុគ្គលម្នាក់ៗ និងជាតិទាំងមូល។

សរុបមក គោលដៅនៃការអភិវឌ្ឍស្ត្រីនៅជនបទ គឺដើម្បីឱ្យស្ត្រីទទួលបានផលប្រយោជន៍ និងទទួលបានសិទ្ធិក្នុងការសម្រេចលើកត្តាដែលជះឥទ្ធិពលដល់ស្ថានភាពរស់នៅរបស់ពួកគេ និងធ្វើយ៉ាងណាឲ្យស្ត្រីខ្លួនឯងផ្ទាល់អាចអភិវឌ្ឍខ្លួននិងក្រុមគ្រួសារផងដែរ។

### ១.៣.៣ មូលហេតុនៃការអភិវឌ្ឍស្ត្រីនៅជនបទ

ស្ត្រីដែលរស់នៅតំបន់ជនបទជួបប្រឈមនឹងបញ្ហាជាច្រើនក្នុងការរស់នៅរបស់ពួកគេ ដែលរួមមានកម្រិតជីវភាពទាប ការសិក្សាមិនបានគ្រប់គ្រាន់ ឱកាសការងារតិច និងអាចប្រឈមជាមួយនឹងវិបត្តិក្នុងការគ្រួសារទាក់ទងនឹងការប្រើប្រាស់អំពើហិង្សា។ល។ ដោយសារមូលហេតុទាំងនេះហើយ ទើបមានការទាមទារឱ្យមានការអភិវឌ្ឍទៅលើស្ត្រី ដើម្បីឱ្យស្ត្រីអាចមានលទ្ធភាពក្នុងការស្វែងរកឬបង្កើតការងារធ្វើដោយខ្លួនឯង ទទួលបានសមភាពក្នុងការរស់នៅ អាចការពារខ្លួន និងទទួលបានព័ត៌មាននិងចំណេះដឹងផ្សេងៗពីសង្គមខាងក្រៅ។

## ១.៤ គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍស្ត្រីនៅជនបទ

### ១.៤.១ យុទ្ធសាស្ត្រនារីរតនៈ

#### ១.៤.១.១ ចក្ខុវិស័យ

ប្រជាពលរដ្ឋទាំងស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាស្របតាមច្បាប់ ជាពិសេសស្ត្រីទទួលបានសុវត្ថិភាពផ្ទាល់ខ្លួនព្រមទាំងអាចចូលរួមក្នុងសកម្មភាពសង្គម ការធ្វើសេចក្តីសម្រេចសាធារណៈដោយស្មើភាពជាមួយបុរស និងក្មេងប្រុស និងភាពអង់អាចផ្នែកសេដ្ឋកិច្ច ដើម្បីធានានូវម្ចាស់ការលើខ្លួនឯង និងសុខមាលភាពក្នុងគ្រួសារ និងសហគមន៍។

#### ១.៤.១.២ គោលបំណង

ក្នុងគោលបំណងដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីក្នុងបរិបទកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងអភិបាលកិច្ច នារីរតនៈទី៤ មានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ជំរុញឲ្យមានបរិយាកាសអំណោយផល ដើម្បីបង្កើនលទ្ធភាពដល់ស្ត្រីក្នុងការទទួលបាននូវជំនាញ ការងារធនធានផលិតកម្ម កិច្ចការគាំពារសង្គម សម្លេង និងការធ្វើសេចក្តីសម្រេចក្នុងវិស័យសេដ្ឋកិច្ច។
- បង្កើនលទ្ធភាពរបស់ស្ត្រី និងកុមារក្នុងការទទួលបានសេវាអប់រំ តាម រយៈការលើកកម្ពស់ការចូលរួមការយល់ដឹង និងការបង្ករលក្ខណៈងាយស្រួលដល់ស្ត្រីនិងក្មេងស្រី ក្នុងការទទួលបានសេវា។
- លើកកម្ពស់សមភាពយេនឌ័រក្នុងការផ្តល់និងការទទួលបានសេវាសុខាភិបាល ស្របតាមតំរូវការជាក់ស្តែង។

- ធានាសុវត្ថិភាពដល់ស្ត្រី និងក្មេងស្រីក្នុងគ្រួសារនិងសង្គមតាមរយៈការបង្កើនការយល់ដឹងនិងការអនុវត្តផែនការសកម្មភាពនិងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។
- ជំរុញការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចនៅគ្រប់កម្រិតតាមរយៈការបង្កើតចំនួនមន្ត្រីរាជការជាស្ត្រី ការពង្រឹងសមត្ថភាព និងតម្លើងឋានៈតួនាទីនៅគ្រប់កម្រិត។
- បង្កើនប្រសិទ្ធិភាពជំនួយ និងចីរភាពនៃកិច្ចអភិវឌ្ឍតាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន ភាពជាម្ចាស់និងភាពជាដៃគូរ។

### ១.៤.១.៣ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

រដ្ឋាភិបាលបានផ្ដោតលើការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចដល់ស្ត្រី និងផ្ដល់ការគាំទ្រដល់ស្ត្រី ក្នុងការបង្កើនប្រាក់ចំណូលដល់គ្រួសារ រួមទាំងការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីក្នុងការផ្ដល់នូវជំនាញវិជ្ជជីវៈ និងសេវាអភិវឌ្ឍអាជីវកម្មជូនស្ត្រី។

ក្របខណ្ឌនៃការពន្លឿនគោលដៅអភិវឌ្ឍសហស្សវត្សដែលផ្ដោតលើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រីក៏បានរៀបចំឡើង ដើម្បីកៀរគការចូលរួមពីបណ្ដាដៃគូពាក់ព័ន្ធនានាទាំងរដ្ឋ និងឯកជនក្នុងការសម្រេចនូវយុទ្ធសាស្ត្របីសំខាន់ៗគឺៈ

- ការពង្រឹងជំនាញវិជ្ជាជីវៈដល់ស្ត្រីទៅតាមតម្រូវការទីផ្សារ
- ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមសម្រាប់ស្ត្រី
- ការបង្កើនជីវភាពរស់នៅជនបទ ជាពិសេសដល់ស្ត្រី។

### ១.៤.១.៤ ការអប់រំសម្រាប់ស្ត្រី និងក្មេងស្រីនិងការផ្លាស់ប្ដូរឥរិយាបថ

ច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រទាំងនេះបាននិងកំពុងរួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ និងបណ្ដុះបណ្ដាលតាមរយៈការផ្ដល់បរិយាកាសល្អផ្នែករូបវ័ន្ត ការបង្កើនកាលានុវត្តភាពក្នុងការទទួលបានការអប់រំ និងបណ្ដុះបណ្ដាល ការកែប្រែឥរិយាបថសង្គមដែលរើសអើងលើនារី និងការផ្ដល់បរិយាកាសអំណោយផលដល់ការចូលរួមរបស់ស្ត្រីនៅគ្រប់ផ្នែកនិងគ្រប់កម្រិត។

គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរបានអនុវត្តការងារតាមយុទ្ធសាស្ត្រពហុវិស័យលើការងារសីលធម៌សង្គម និងសុភមង្គលក្នុងគ្រួសារដោយលើកកម្ពស់ស្ថានភាពតួនាទីនិងសុខុមាលភាពស្ត្រីខ្មែរ។

ទន្ទឹមនិងការរីកចម្រើន បញ្ហាប្រឈមមួយចំនួនក៏បន្តកើតមានដូចខាងក្រោមៈ

- ផ្នត់គំនិតសង្គមដែលផ្ដល់តម្លៃដល់ការអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈសម្រាប់ក្មេងប្រុសជាច្រើន ជាងក្មេងស្រី អនក្ខរភាពរបស់មាតាបិតា អំពើហិង្សាក្នុងគ្រួសារ ការរៀបអាពាហ៍ពិពាហ៍

របស់ក្មេងស្រីដែលមិនទាន់គ្រប់អាយុ និងកត្តាជីវភាពគ្រួសារនៅតែបន្តកើនឡើងដែលនាំឲ្យមានផលប៉ះពាល់ជាវិជ្ជមានដល់ការសិក្សារបស់កូនស្រី។

- កិច្ចគាំពារដល់កុមារនៅមានកម្រិតជាពិសេសសម្រាប់កុមារីទាក់ទងនឹងការធ្វើដំណើរទៅមកដោយសុវត្ថិភាព និងសុខុមាលភាពអនាម័យ។
- ការចូលរួមរបស់សហគមន៍ និងមាតាបិតាក្នុងសកម្មភាពរបស់សាលាក៏ដូចជាការសិក្សារបស់សិស្សនៅមានកម្រិត។

## ១.៤.២ គោលនយោបាយពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺជាការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធិផលគួរឲ្យកត់សម្គាល់ ដោយបានបញ្ជ្រាបយេនឌ័រទៅក្នុងក្របខ័ណ្ឌគោលនយោបាយនិងផែនការអភិវឌ្ឍជាតិ បានកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈមុខងារសាធារណៈ បានពង្រីកសហគ្រិនភាពរបស់ស្ត្រី បានកាត់បន្ថយអំពើហឹង្សា និងការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារី បានលើកកម្ពស់សីលធ៌មសង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ និងបានពង្រឹងកិច្ចការការពារដល់ផ្លូវច្បាប់ដល់ស្ត្រីនិងកុមារផងដែរ។

ដូចនេះ រដ្ឋាភិបាលកម្ពុជាមានគោលដៅយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គមនេះដោយបានបន្តលើកកម្ពស់តួនាទីដល់ស្ត្រី តាមរយៈការបង្កើនសមាមាត្រនិងពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន ទាំងកម្រិតនយោបាយនិងកម្រិតជំនាញ ព្រមទាំងបន្តជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍគ្រប់ផ្នែកគ្រប់វិស័យនិងគ្រប់កម្រិត បន្តលើកស្ទួយសហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់សីល ធ៌មសង្គមខ្មែរ តម្លៃគ្រួសារខ្មែរ និងស្ត្រី តាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និងការពង្រឹងភាពជាដៃគូររវាងស្ថាប័នពាក់ព័ន្ធក្នុងការទប់ស្កាត់ការជួញដូរ និងអំពើហិង្សាលើស្ត្រី និងកុមារ។

ជាមួយគ្នានេះដែរ ក្រសួងកិច្ចការនារីក៏បានចូលរួមបន្តការសម្របសម្រួលក្នុងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីនិងប្រព័ន្ធអប់រំ និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ព្រមទាំងលើកកម្ពស់ជីវភាពសេដ្ឋកិច្ចគ្រួសារនៅតាមជនបទតាមរយៈ៖

- ការពង្រឹងសេវាអភិវឌ្ឍសហគ្រិនភាព និងធុរកិច្ចរបស់មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីប្រកបដោយភាពច្នៃប្រឌិត នវានុវត្តន៍ និងបរិយាប័ន្ន

- ការបង្កើនកាលានុវត្តភាព បរិយាកាសមេត្រីភាពនិងលទ្ធភាពឲ្យស្ត្រីទទួលបានការងារសមស្រប ការអភិវឌ្ឍជំនាញ បច្ចេកទេសនិងវិជ្ជាជីវៈ រួមទាំងបច្ចេកវិទ្យាឌីជីថល ទៅតាមតម្រូវការរបស់ស្ត្រី និងតម្រូវការទីផ្សារ ជាពិសេសបច្ចេកទេសកម្រិតស្តង់ដារ
- ការពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូពាក់ព័ន្ធក្នុងការលើកកម្ពស់សហគ្រិនភាព និងអភិវឌ្ឍសក្តានុពល បទពិសោធន៍និងបច្ចេកទេសក្នុងការបង្កើនផលិតភាព គុណភាព ផលិតផលនិងអាចឈានចូលទៅកាន់ទីផ្សារជាតិនិងក្នុងតំបន់
- ការបង្កើនការចូលរួមរបស់ស្ត្រី និងក្មេងស្ត្រីក្នុងវិស័យអប់រំនៅកម្រិតខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យាស្ទែមជាដើម
- ការលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ គាំទ្រសហគ្រាសធនតូច និងមធ្យម រួមទាំងមូលនិធិជាតិសហគ្រិនភាព និងមជ្ឈមណ្ឌលអភិវឌ្ឍសហគ្រិនភាព ដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ
- ការបន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ដែលឆ្លើយតបទៅផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហឹង្សាលើស្ត្រី និងកុមារ។

### ១.៤.៣. យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា

យុទ្ធសាស្ត្រចតុកោណ ជាគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា។ គោលនយោបាយនេះត្រូវបានរាជរដ្ឋាភិបាលដាក់ចេញប្រើប្រាស់អស់៤ដំណាក់កាលមកហើយ ដែលនៅក្នុងដំណាក់កាលនីមួយៗនៃយុទ្ធសាស្ត្រចតុកោណមានជ្រុងចតុកោណយុទ្ធសាស្ត្រ៤ សំខាន់ៗគឺ៖

១. ការអភិវឌ្ឍធនធានមនុស្ស

២. ការធ្វើពិពិធកម្មសេដ្ឋកិច្ច

៣. ការអភិវឌ្ឍវិស័យឯកជន និង ការងារ

៤. ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន។

យុទ្ធសាស្ត្រនេះក៏បានលើកឡើងផងដែរអំពីការអភិវឌ្ឍនិងលើកកម្ពស់ស្ត្រីនៅក្នុងមុំទី៤ យុទ្ធសាស្ត្រទី១ ដូចតទៅ៖

ក្នុងនីតិកាលទី៦នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១- ការបន្តលើកកម្ពស់តួនាទីស្ត្រី តាមរយៈការបង្កើតសមាមាត្រ និងការពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ , ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ក្រសួង-ស្ថាប័ន, ទាំងកម្រិតនយោបាយ និងកម្រិតជំនាញ ។

ទី២- ការធ្វើបច្ចុប្បន្នភាព និងអនុវត្ត « ផែនការយុទ្ធសាស្ត្រនារីរតនៈ» ដោយបន្តជម្រុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍគ្រប់ផ្នែក គ្រប់វិស័យ និងគ្រប់កម្រិត, បន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី, ព្រមទាំងបន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរតាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និងការពង្រឹងភាពជាដៃគូរវាងស្ថាប័នពាក់ព័ន្ធ សំដៅទប់ស្កាត់ការជួញដូរ និងអំពើហិង្សាលើស្ត្រីនិងកុមារ។

ទី៣- ការជម្រុញអនុវត្ត « ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥» ពិសេសដោយដាក់ឱ្យអនុវត្តនូវរបបហានិភ័យការងារមន្ត្រីសាធារណៈ និងរបបសោធនសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, ការកែទម្រង់សម្រាប់របបសោធនសម្រាប់មន្ត្រីរាជការ, ការធ្វើសមាហរណកម្មប្រតិបត្តិករប្រព័ន្ធសន្តិសុខសង្គម និងក្របខណ្ឌប្រព័ន្ធអភិបាលកិច្ចប្រព័ន្ធគាំពារសង្គម; ទន្ទឹមនឹងការជម្រុញការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦ - ២០៣០។

ទី៤ - ការរៀបចំក្របខណ្ឌគតិយុត្តិ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដើម្បីដាក់ឱ្យដំណើរការ កម្មវិធីជាតិជំនួយសង្គមថ្មីៗ និងពង្រីកកម្មវិធីដែលមានស្រាប់ សំដៅបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រ និងជនងាយរងគ្រោះ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមថ្មី ព្រមទាំងពង្រីកវិសាលភាពលើរបបដែលមានស្រាប់ សំដៅបង្កើនការគាំពារដល់ប្រជាជនគ្រប់រូប។

## ១.៥ ទិសដៅក្នុងការអភិវឌ្ឍស្ត្រីក្នុងតំបន់ជនបទ

ទិសដៅក្នុងការអភិវឌ្ឍស្ត្រីនៅជនបទ គឺជាទិសដៅដែលមានលក្ខណៈបរិយាប័ន្នសម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់ជនបទទាំងការរស់នៅ និងការអភិវឌ្ឍក្នុងតំបន់ជនបទ។

### ១.៥.១ ទិសដៅបង្កើនលទ្ធភាពដល់ស្ត្រីនៅជនបទ

ក្នុងការទទួលបាននិងគ្រប់គ្រងធនធានសំខាន់ៗនិងសេវាកម្មកសិកម្ម៖

- ជួយជ្រោមជ្រែងចំពោះដំណើរការនៃដីសម្បទានសង្គមកិច្ចដែលធានាបាននូវការផ្តល់ផលប្រយោជន៍ដល់ស្ត្រីនិងបុរស
- បង្កើនសមត្ថភាពរបស់ស្ត្រីនៅជនបទឲ្យចូលរួមក្នុងវិស័យឯកជន
- បង្កើនការយល់ដឹងដល់គ្រួសារក្រីក្រ/គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ស្តីពីកម្មវិធីនានាដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀង
- ធ្វើឱ្យប្រសើរឡើងនូវឱកាសដល់កសិករស្ត្រីឲ្យចូលរួមក្នុងក្រុម ភូមិ និងសហគមន៍
- សម្រួលលទ្ធភាពដល់ស្ត្រី ក្នុងការទទួលបានសេវាកម្មឥណទាន
- កែលំអសេវាកម្មផ្សព្វផ្សាយដល់ស្ត្រីនិងបុរស

- រៀបចំសិក្ខាសិលា និងទស្សនៈកិច្ចសិក្សាដើម្បីឲ្យប្រសើរឡើងនូវលទ្ធភាពរបស់ស្ត្រីជនបទក្នុងការទទួលបាននិងប្រើប្រាស់ធនធាននានា។

### ១.៥.២ ទិសដៅលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខមាលភាព

- កាត់បន្ថយអត្រាមរណភាពនៃមាតា
- បញ្ចប់ការរីករាលដាលនៃជំងឺអេដស៍ គ្រុនចាញ់ ត្រូវបានយកចិត្តទុកដាក់តាមតំបន់ជនបទ
- ពង្រឹងការបង្ការ និងការព្យាបាលរួមទាំងការប្រើប្រាស់ជាតិស្រវាដែលនាំឲ្យកើតគ្រោះថ្នាក់។

### ១.៥.៣ ទិសដៅលើកកម្ពស់ការអប់រំ

ទិសដៅលើកកម្ពស់នូវការផ្តល់ការអប់រំពេញលេញដល់កុមារា កុមារី គ្រប់រូបប្រកបដោយសមធ៌មនិងគុណភាព៖

- លុបបំបាត់គំលាតយេនឌ័រក្នុងវិស័យអប់រំ និងធានាបាននូវភាពស្មើគ្នាក្នុងការអប់រំគ្រប់កម្រិត
- ផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការទទួលយកនូវចំណេះដឹង នឹងជំនាញដែលត្រូវការដើម្បីជំរុញការអភិវឌ្ឍការសិក្សា មានសិទ្ធិមនុស្សមានតម្លាភាពយេនឌ័រ ការលើកកម្ពស់វប្បធ៌ម សន្តិភាព និងគ្មានអំពើហឹង្សា។

### ១.៥.៤ ទិសដៅបញ្ចប់ភាពខ្វះខាត

- លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរសម្រាប់ប្រជាជនគ្រប់រូបនៅជនបទ
- កាត់បន្ថយសមាមាត្រនៃបុរសស្ត្រី ដែលរស់នៅក្នុងភាពក្រីក្ររបស់សមាសភាព
- លើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅជនបទឲ្យមានស្វ័យភាពសេដ្ឋកិច្ចគ្រប់គ្រាន់និងឈានឡើងប្រហាក់ប្រហែលនឹងបណ្តាប្រទេសក្នុងតំបន់
- លើកទឹកចិត្តដល់ចលនាប្រជាសាស្ត្រជនបទក្នុងការចូលរួមក្នុងជំនាក់កាលនៃគម្រោងអភិវឌ្ឍនៅតំបន់ជុំវិញសហគមន៍ ដើម្បីធានាបាននូវប្រសិទ្ធិភាពការងារនិងភាពស្ថិតស្ថេរនៅថ្ងៃអនាគត
- រៀបចំកម្មវិធីឲ្យបានសមស្របទៅតាមលទ្ធភាពនិងជំនាញសង្គមជនបទ ណែនាំប្រជាកសិករឲ្យចូលរួមក្នុងការកែលំអផលិតផលកសិកម្ម។

# ជំពូកទី២
# ស្ថានភាពទូទៅរបស់ស្ត្រីនៅជនបទ

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ស្ត្រីនៅជនបទ

## ២.១ ស្ថានភាពទូទៅ

### ២.១.១ ចរិតលក្ខណៈ

ស្ត្រីនៅតំបន់ជនបទ ដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំគ្រួសារនិងសហគមន៍ជនបទឱ្យទទួលបានភាពរីកចម្រើនទាំងផ្នែកសេដ្ឋកិច្ចនិងសុខុមាលភាពជីវភាពតាមរយៈការចូលរួមក្នុងសកម្មភាពជាច្រើនដែលរួមមានទាំង ការទ្រទ្រង់ស្ថិរភាពផ្នែកសន្តិសុខស្បៀងតាមរយៈការធ្វើការងារកសិកម្ម ស្វែងរកប្រាក់ចំណូលនៅតាមសហគ្រាសជនបទ ក៏ដូចជាការងារផ្សេងៗទៀតនៅតាមផ្នែកសេវាកម្មនិងផលិតកម្មក្នុងតំបន់ ហើយក៏ជាភ្នាក់ងារក្នុងការជួយជ្រោមជ្រែងឱ្យដំណើរការសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រព្រឹត្តទៅបានដោយងាយស្រួលផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងក៏ដោយ ស្ត្រីនៅតែមានភាពលំបាកក្នុងការទទួលបាននូវសិទ្ធិសេរីភាពក្នុងការបង្កើនចំណេះដឹងពង្រីកសមត្ថភាពរបស់ខ្លួនឱ្យបានទូលំទូលាយ ដោយសាបញ្ហាគំនាបសង្គម វិសមភាពយេនឌ័រ កង្វះខាតផ្នែកហិរញ្ញវត្ថុ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធនិងកង្វះខាតទំនុកចិត្តផ្ទាល់ខ្លួន ព្រមទាំងមិនសូវទទួលបានការផ្តល់តម្លៃទៅលើកិច្ចការដែលខ្លួនបានធ្វើផងនោះ ទើបស្ត្រីជាច្រើនរូបបាត់បង់ឱកាសក្នុងការស្រូបយកចំណេះជំនាញនិងការចូលរួមក្នុងការងារសង្គមមិនសូវបានច្រើន។

### ២.១.២ ផ្នត់គំនិត

នៅតាមតំបន់ជនបទ ដោយសាការអភិវឌ្ឍនៅមានកម្រិតទាប ស្ត្រីនិងក្មេងស្រីជាច្រើនបាននឹងកំពុងរស់នៅជាមួយនឹងផ្នត់គំនិតចាស់បុរាណនៅឡើយ មួយក្នុងចំណោមនោះគឺ "កូនស្រីមិនបាច់រៀនវែងឆ្ងាយច្រើន"។ ផ្នត់គំនិតនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវិតស្ត្រី ជាពិសេសនារីក្មេងៗដែលបោះបង់ការសិក្សាពាក់កណ្តាលទី និងមិនបានរៀនសូត្រឱ្យបានខ្ពង់ខ្ពស់ ធ្វើឱ្យពួកគេមានចំណេះដឹងមូលដ្ឋានតិចជាពិសេសទាក់ទងនឹងផ្នែកសុខភាពនិងការរស់នៅប្រចាំថ្ងៃ ហើយក៏ជាមូលហេតុដែលធ្វើឱ្យពួកគេងាយនឹងត្រូវធ្លាក់ក្នុងការបោកបញ្ឆោតពីសំណាក់ជនខិលខូចទាំងក្នុងនិងក្រៅបណ្តាញសង្គមផងដែរ។

ក្រៅពីនេះ នៅក្នុងសហគមន៍ដាច់ស្រយ៉ាលប្រជាពលរដ្ឋក៏ដូចជាស្ត្រីខ្លួនឯងផ្ទាល់នៅប្រកាន់ទស្សនៈមិនជឿនលឿនមួយទៀតគឺ "ភារកិច្ចចំបងរបស់ស្ត្រីគឺរ៉ាប់រងការងារមេផ្ទះ" ។ ផ្នត់គំនិតនេះបានធ្វើឱ្យមនុស្សស្រីជាច្រើនរូបសុខចិត្តបោះបង់ការងារខាងក្រៅផ្ទះ ហើយមករស់នៅក្នុងនាមជាភរិយា ជាម្តាយ ចិញ្ចឹមមើលថែសមាជិកគ្រួសារដោយមិនទទួលបានកម្រៃ ហើយពេលខ្លះថែមមិនទទួលបានការផ្តល់តម្លៃ បែជាទទួលបានការប្រមាទមើលងាយជិះជាន់កម្លាំងកាយចិត្តពីសំណាក់បុរសជាមេគ្រួសារទៀតផង។ ម្យ៉ាងវិញទៀត ដោយសាមិនទទួលបានការរៀនសូត្រយល់ដឹងពីសិទ្ធិក្នុងការពារខ្លួន ស្ត្រីខ្លះសុខចិត្តទ្រាំទទួលទារុណកម្មទាំងនេះដោយយល់

ថាជាកម្មពាររបស់ខ្លួនទៅវិញ។ ទស្សនៈទាំងនេះហើយ ដែលចងជីវិតនិងបិតបាំងការយល់ឃើញរបស់ស្ត្រីមិនឱ្យមានទស្សនវិស័យវែងឆ្ងាយទាក់ទងនឹងរបៀបក្នុងការរៀបចំផែនការជីវិតឱ្យមានលក្ខណៈល្អប្រសើរ ជៀសឆ្ងាយពីការរំលោភបំពាន។

### ២.១.៣ ជីវភាព

កម្រិតជីវភាពរស់នៅរបស់ស្ត្រីនៅតំបន់ជនបទ ច្រើនមានលក្ខណៈបង្គួរ ដោយប្រាក់ចំណូលរបស់ពួកគេភាគច្រើនបានមកពីការងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ពាណិជ្ជកម្មនិងសេវាកម្ម,ផលិតកម្ម ហើយ នារីវ័យក្មេងមកពីតំបន់ដាច់ស្រយ៉ាល មានទំនោរក្នុងការធ្វើទេសន្តប្រវេសន៍ពីទីកន្លែងកំណើតរបស់ខ្លួនទៅធ្វើការនៅទីក្រុងក្រោមរូបភាពជាកម្មការិនីនៅតាមរោងចក្រផ្សេងៗ មានដូចជារោងចក្រកាត់ដេរជាដើម។

គួរបញ្ជាក់ផងដែរថា ស្ត្រីដែលមានការងារធ្វើមាន៥៣%នៅទូទាំងប្រទេស និង៦៣%នៅជនបទ ប៉ុន្តែការងាររបស់ពួកគេភាគច្រើនស្ថិតនៅក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានផលិតភាពទាប និងបញ្ជាក់ពីការទទួលផលក្នុងកម្រិតទាបសម្រប់កម្លាំងពលកម្មស្ត្រី។ ការងារកសិកម្ម ជាទូទៅត្រូវបានបែងចែកទៅតាមភេទ ក្នុងនោះស្ត្រីទទួលខុសត្រូវជាចម្បងលើការសាប ស្ទូង ដកស្នៅ បោកបែនដោយដៃ និងចិញ្ចឹមសត្វទ្រង់ទ្រាយតូច។បុរសទទួលខុសត្រូវលើការងារធំៗដូចជាការរៀបដី ធារាសាស្ត្រ បោកបែនដោយម៉ាស៊ីន និងចិញ្ចឹមសត្វទ្រង់ទ្រាយធំ។ ស្ត្រីមានឧបសគ្គច្រើនជាងបុរសនៅក្នុងការរកទីផ្សារទំនិញកសិកម្មដោយសារតែ ការទទួលខុសត្រូវថែទាំក្រុមគ្រួសារ ការព្រួយបារម្ភផ្នែកសុវត្ថិភាព និងសន្តិសុខនៅពេលដែលធ្វើដំណើរទៅទីកន្លែងសាធារណៈ ការអប់រំផ្នែកហិរញ្ញវត្ថុនៅមានកម្រិតទាប ការបង់ថ្លៃសេវាក្រៅផ្លូវការ ក៏ដូចជាការលំបាកក្នុងការទទួល និងផ្តល់ព័ត៌មាន និងទំនាក់ទំនងជាមួយក្រុមអ្នកលក់ជាដើម។

ម្យ៉ាងវិញទៀតនៅក្នុងបរិបទនៃការស្វែងរកប្រាក់ចំណូល ស្ត្រីជួបប្រទះនូវឧបសគ្គចម្បងៗដូចជា៖

១. ការអប់រំមានកម្រិតទាប និងអក្ខរកម្ម

២. ប្រាក់កម្រៃអប្បបរមាទាប

៣. ការរើសអើងក្នុងការងារ ក៏ដូចជាកិច្ចសន្យាការងារដែលមានរយៈពេលខ្លីជាច្រើន។

មិនតែប៉ុណ្ណោះ ស្ត្រីក៏ជួបការលំបាកដោយសារភាពទន់ខ្សោយផ្នែកច្បាប់ការងារ ដូចជាកង្វះភាពជាក់លាក់នៃការផ្តល់ប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលទាមទារសមត្ថភាព ឬជំនាញស្មើគ្នា និងកង្វះការបញ្ជាក់ក្នុងនិយមន័យ និងយន្តការសម្រាប់ដោះស្រាយបញ្ហាបៀតបៀនផ្លូវភេទ។

### ២.១.៤ ការអប់រំ និងទស្សនៈ

នៅតាមតំបន់ជនបទ ស្ត្រីនិងក្មេងស្រីជាច្រើនពុំសូវទទួលបានការសិក្សាអប់រំបានខ្ពង់ខ្ពស់ឡើយ ដោយហេតុថាការយល់ដឹងរបស់ពួកគេនៅមានកម្រិតទាប រួមទាំងមានការដក់ជាប់នូវទស្សនៈបុរាណទាក់ទងនឹងការ

មិនសូវឱ្យកូនស្រីរៀនបានច្រើនផងនោះ ទើបធ្វើឱ្យនារីវ័យក្មេងភាគច្រើនមានទំនោរក្នុងការបោះបង់ការសិក្សាចោល ហើយឆាប់ចេញធ្វើការដើម្បីស្វែងរកចំណូលទ្រទ្រង់គ្រួសារឬនៅជំនួសដៃជើងម្តាយក្នុងការកាន់កាប់ការងារផ្ទះសម្បែងតែម្តង។ តថភាពនេះស្តែងឱ្យឃើញតាមរយៈការលើកឡើងនៅក្នុងឯកសា **សមភាពយេនឌ័រក្នុងវិស័យអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ** ដូចតទៅ៖ "សមភាពយេនឌ័រក្នុងវិស័យអប់រំកំពុងមានការរីកចម្រើន ប៉ុន្តែនៅមានគម្លាតយេនឌ័រនៅឡើយបើពិនិត្យទៅតាមតំបន់និងអាយុ។ ក្មេងស្រីនៅតាមតំបន់ជនបទជាពិសេសកុមារជនជាតិដើមភាគតិច ជាទូទៅជួបការលំបាកជាងក្មេងស្រីនៅតំបន់ទីក្រុងក្នុងការទទួលបានការអប់រំ លើកលែងតែនៅកម្រិតមធ្យមសិក្សាបឋមភូមិដែលអត្រាក្មេងប្រុសមានតែ ២៧ភាគរយប៉ុណ្ណោះ ចំណែកក្មេងស្រីមាន៣៣ភាគរយ។ ថ្វីត្បិតតែការទទួលបានការអប់រំក្នុងចំណោមមនុស្សវ័យក្មេងមានភាពរីកចម្រើនក៏ដោយ ក៏ប៉ុន្តែសម្រាប់ក្រុមមនុស្សវ័យចំណាស់ អក្ខរភាពនៅមានគម្លាតនៅឡើយរវាងបុរសនិងស្ត្រី។ អត្រាអក្ខរកម្មរបស់ពួកគេមានកម្រិតទាប ដែលនៅតែជាបញ្ហាប្រឈមចម្បងផ្នែកយេនឌ័រនិងការអភិវឌ្ឍ។"

តាមរយៈការលើកឡើងនេះ យើងអាចសង្កេតឃើញថានៅក្នុងសង្គមជនបទ ទោះបីជាស្ថិតនៅក្នុងសម័យវិទ្យាសាស្ត្រជឿនលឿននេះហើយក៏ដោយ ក៏ក្មេងស្រីនៅតែទទួលបានឱកាសក្នុងការអប់រំតិចជាងក្មេងប្រុសដដែល ហើយនេះក៏ជាមូលហេតុដែលធ្វើឱ្យស្ត្រីមានការពិបាកក្នុងការឈានជើងទៅក្នុងទីផ្សារការងារ និងមានការចូលរួមទៅក្នុងការងារសង្គមបានតិចជាងបុរសផងដែរ។ ម្យ៉ាងទៀត ដោយសារកើតមាននូវបញ្ហាវិសមភាពយេនឌ័រក្នុងផ្នែកវិស័យអប់រំនេះគេសង្កេតឃើញថា៖

- ស្ត្រី ច្រើនទទួលបានតំណែងទាបក្នុងការងារ ហើយការងារភាគច្រើនរបស់ស្ត្រីជាការងារដែលពុំសូវទាមទារជំនាញខ្ពស់ មានតែស្ត្រីមួយចំនួនតូចប៉ុណ្ណោះដែលមានតួនាទីជាអ្នកគ្រប់គ្រង។
- ការងាររបស់ស្ត្រីច្រើនផ្តុំគ្នានៅក្នុងវិស័យមួយចំនួនតូចប៉ុណ្ណោះ ជាពិសេសក្នុងការងារដែលសង្គមពុំសូវឱ្យតម្លៃដូចជាការងារក្នុងសេវាកំសាន្ត ផ្សព្វផ្សាយស្រាបៀរជាដើម។
- ការចូលរួមរបស់ស្ត្រីនៅមានកម្រិតទាបនៅឡើយនៅក្នុងការបណ្តុះបណ្តាលផ្លូវការដែលមាន រយៈពេលវែង ជាពិសេសក្នុងជំនាញដែលទីផ្សារត្រូវការនិងមានប្រាក់ឈ្នួលខ្ពស់ ដូចជាក្នុងផ្នែកសំណង់និងមេកានិកជាដើម។
- ទោះបីជាការចូលរួមរបស់ស្ត្រីនៅក្នុងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសមានការកើនឡើងក៏ដោយ ក៏ប៉ុន្តែជំនាញដែលផ្តល់ជូនដល់ស្ត្រីភាគច្រើនជាជំនាញតាមបែបប្រពៃណី ដូចជាជំនាញតម្បាញ ធ្វើសក់ សំអាងការនិងការងារសិប្បកម្មជាដើម។
- អ្នកបណ្តុះបណ្តាលជាស្ត្រីក៏នៅមានចំនួនតិចផងដែរ នៅតាមស្ថាប័នបណ្តុះបណ្តាលគ្រូបច្ចេកទេស។

មិនតែប៉ុណ្ណោះ បទដ្ឋានសង្គមនៅកម្ពុជាបានធ្វើឱ្យស្ត្រីនិងក្មេងស្រីឆាប់រៀបការនៅវ័យក្មេងជាងបុរស ដែលជាឧបសគ្គរារាំងដល់ការអប់រំរបស់ស្ត្រីផងដែរ។ ការចូលរៀនយឺតរបស់ក្មេងស្រីជាងក្មេងប្រុស និងការបូកបញ្ចូលគ្នានៃការចូលរៀនយឺតនិងឈប់រៀនមុនក្មេងប្រុសបណ្តាលឱ្យរយៈពេលនៃការសិក្សាសម្រាប់ក្មេងស្រីកាន់តែខ្លី។ យោងតាមការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា (CDHS) ឆ្នាំ ២០១០ ស្ត្រីប្រមាណ ១ភាគ៤ ក្នុងប្រទេសកម្ពុជាដែលមានអាយុចាប់ពី២៥ ទៅ៤៩ឆ្នាំ បានរៀបការនៅអាយុ១៨ឆ្នាំ។ អាយុរៀបការជាមធ្យមគឺ ២០,៣ឆ្នាំសម្រាប់ស្ត្រីធៀបនឹង ២២,៦ឆ្នាំសម្រាប់បុរស។ ឥរិយាបថនៃការឆាប់រៀបការបានកម្រិតឱកាសរៀនសូត្ររបស់ក្មេងស្រី ខណៈការដែលរៀបការរួច បទដ្ឋានសង្គមជាប្រពៃណីបានតម្រូវឱ្យស្ត្រីទទួលបន្ទុកលើការងារផ្ទះ មើលថែទាំកូននិងមនុស្សចាស់។

ខាងក្រោមនេះជាតារាងស្ថិតិមួយចំនួនដែលបង្ហាញពីអត្រាអក្ខរកម្មមនុស្សពេញវ័យ គឺជាចំណែកនៃប្រជាជនអាយុចាប់ពី១៥ឆ្នាំទៅដែលចេះអាន និងសរសេរសារធម្មតាក្នុងភាសាណាមួយបាន។ ជាទូទៅ អត្រាអក្ខរកម្មក្នុងចំណោមបុរសគឺខ្ពស់ជាងស្ត្រីនៅគ្រប់អាយុទាំងអស់ លើកលែងតែក្រុមអាយុ ៦-១៤ឆ្នាំ និង ១៥-២៤ឆ្នាំ។

- អក្ខរកម្មតាមក្រុមអាយុ ឆ្នាំ២០១៤ និង ២០១៦ គិតជាភាគរយ




ប្រភព៖ ការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៤ និង ២០១៦ ដោយវិទ្យាស្ថានជាតិស្ថិតិ។

- អនក្ខរកម្ម (អាយុ១៥ឆ្នាំឡើង) តាមតំបន់ភូមិសាស្ត្រឆ្នាំ ២០១៤, ២០១៥ និង ២០១៦




ប្រភព៖ ការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៤, ២០១៥ និង ២០១៦ ដោយវិទ្យាស្ថានស្ថិតិ។

ក្រាហ្វិចនេះ បង្ហាញថាអត្រាអក្ខរកម្មក្នុងបណ្ដាញបុរសនិងស្ត្រីនៅតាមទីប្រជុំជន គឺមានចំនួនខ្ពស់ជាងបុរស និងស្ត្រីនៅតាមទីជនបទនៅគ្រប់ក្រុមឆ្នាំទាំងអស់។ អត្រាអក្ខរកម្មមនុស្សពេញវ័យនៃប្រជាជនអាយុ ១៥ ឆ្នាំឡើងទៅ គឺស្ត្រីមានកម្រិតទាបជាងបុរសនៅគ្រប់តំបន់ទាំងអស់។

- អត្រាចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សា គិតជាភាគរយ




ប្រភព៖ ស្ថិតិអប់រំ និងសូចនាកររបស់ក្រសួងអប់រំយុវជន និងកីឡា។

○ អត្រាចូលរៀនពិតនៅមធ្យមសិក្សាបឋមភូមិឆ្នាំ២០១៤-២០១៧ គិតជាភាគរយ

| | ២០១៤-២០១៥ | | ២០១៥-២០១៦ | | ២០១៦-២០១៧ | |
|---|---|---|---|---|---|---|
| | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស |
| កម្ពុជា | ៥៥ | ៥២ | ៥៧ | ៥១ | ៦០ | ៥២ |
| ទីប្រជុំជន | ៥៩ | ៥៨ | ៥៦ | ៥៥ | ៥៧ | ៥៤ |
| ទីជនបទ | ៥៥ | ៥០ | ៥៧ | ៥០ | ៦០ | ៥២ |

ប្រភព៖ ស្ថិតិអប់រំ និងសូចនាកររបស់ក្រសួងអប់រំយុវជន និងកីឡា

តាមតារាងយើងឃើញថា នៅតំបន់ជនបទដែលការចូលរៀនក្នុងចំណោមស្ត្រីគឺមានប្រហែល២៣% និង ២០% គឺសម្រាប់បុរស។

○ អត្រាចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០១៤-២០១៧ គិតជាភាគរយ

| | ២០១៤-២០១៥ | | ២០១៥-២០១៦ | | ២០១៦-២០១៧ | |
|---|---|---|---|---|---|---|
| | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស |
| កម្ពុជា | ២៥ | ២៤ | ២៥ | ២៤ | ២៧ | ២៤ |
| ទីប្រជុំជន | ៤០ | ៣៨ | ៣៩ | ៣៨ | ៣៩ | ៣៨ |
| ទីជនបទ | ២០ | ២០ | ២១ | ១៩ | ២៣ | ២០ |

ប្រភព៖ ស្ថិតិអប់រំ និងសូចនាកររបស់ក្រសួងអប់រំយុវជន និងកីឡា។

នៅចន្លោះឆ្នាំ ២០១៤-២០១៥ និង ២០១៦-២០១៧ អត្រាចូលរៀននៅកម្រិតមធ្យមសិក្សាគឺទាបជាងតិចតួចសម្រាប់ស្ត្រី និងគ្មានការប្រែប្រួលសម្រាប់បុរសនៅតាមទីប្រជុំជន និងតំបន់ជនបទ។

○ អត្រាបោះបង់ការសិក្សាកម្រិតភូមិសិក្សា ឆ្នាំ២០១៣-២០១៦

| | ២០១៣-២០១៤ | | ២០១៤-២០១៥ | | ២០១៥-២០១៦ | |
|---|---|---|---|---|---|---|
| | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស | ក្មេងស្រី | ក្មេងប្រុស |
| កម្ពុជា | | | | | | |
| មធ្យមសិក្សាទុតិយភូមិ | ២៥ | ៣០ | ២២ | ២៥ | ១៨ | ២១ |
| មធ្យមសិក្សាបឋមភូមិ | ២០ | ២២ | ១៨ | ២០ | ១៦ | ១៩ |
| កម្រិតបឋមសិក្សា | ៧ | ៩ | ៥ | ៧ | ៤ | ៦ |
| ទីប្រជុំជន | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| មធ្យមសិក្សាទុតិយភូមិ | ២០ | ២៥ | ១៩ | ២១ | ១៤ | ១៧ |
| មធ្យមសិក្សាបឋមភូមិ | ១៣ | ១៥ | ១៣ | ១៥ | ១២ | ១៦ |
| កម្រិតបឋមសិក្សា | ៥ | ៧ | ៤ | ៦ | ៣ | ៥ |
| ទីជនបទ | | | | | | |
| មធ្យមសិក្សាទុតិយភូមិ | ២៨ | ៣២ | ២៤ | ២៨ | ២០ | ២៣ |
| មធ្យមសិក្សាបឋមភូមិ | ២២ | ២៤ | ២០ | ២២ | ១៦ | ១៩ |
| កម្រិតបឋមសិក្សា | ៨ | ១០ | ៤ | ៨ | ៤ | ៦ |

ប្រភព៖ ស្ថិតិអប់រំ និងសូចនាកររបស់ក្រសួងអប់រំយុវជន និងកីឡា

សំណួរពីមូលហេតុនៃការបោះបង់ការសិក្សាត្រូវបានសាកសួរចំពោះតែអ្នកមានអាយុក្រោម១៨ឆ្នាំ ប៉ុណ្ណោះដែលពួកគេមិនបានចូលរៀន។ ក្មេងស្រីប្រហែល៥៤% និងក្មេងប្រុសប្រហែល៤៥% នៅតំបន់ជនបទ បានឆ្លើយថាពួកគេមិនអាចចូលរៀនបានទេ ដោយសារពួកគេត្រូវតែរួមចំណែកដល់ការរកប្រាក់ចំណេញសម្រាប់គ្រួសារ។ ជារួម មូលហេតុនានានៃការធ្វើការងារដើម្បីរួមចំណែកដល់ការរកប្រាក់ចំណូលក្នុងគ្រួសារគឺមានកម្រិតទាបនៅក្នុងឆ្នាំ២០១៦ ជាជាងក្នុងឆ្នាំ២០១៤ សម្រាប់ក្មេងស្រី និងក្មេងប្រុសនៅគ្រប់តំបន់ទាំងអស់។

### ២.១.៥ ការចូលរួមចំណែកក្នុងកិច្ចការសង្គម និងសេដ្ឋកិច្ច

ស្ត្រីដែលរស់នៅតំបន់ជនបទជាទូទៅ ពុំសូវបានចូលរួមចំណែកទៅក្នុងការងារសង្គមកិច្ចច្រើននោះឡើយ ពីព្រោះមួយភាគធំនៃការបែងចែកពេលវេលារបស់ពួកគេគឺចំណាយពេលនៅខាងក្នុងរ៉ាប់រងទៅលើកិច្ចការមេផ្ទះដូចជាការដាំស្ល និងការចិញ្ចឹមបីបាច់ថែរក្សាកូន។ ចំណែកឯលទ្ធភាពនៅក្នុងការស្វែងរកចំណូលវិញ ស្ត្រីនៅតំបន់ជនបទភាគច្រើនប្រកបកិច្ចការនៅក្នុងផ្នែកកសិកម្ម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធមួយចំនួនទៀតដូចជាការបើកតូបលក់ទំនិញប្រើប្រាស់ គ្រឿងឧបភោគបរិភោគ និងចំណីអាហារសម្រន់នៅតាមផ្ទះជាដើម។ ជាងនេះទៅទៀតតាមការលើកឡើងរបស់ក្រសួងកិច្ចការនារីបានបញ្ជាក់ផងដែរថា ស្ត្រីនិងក្មេងស្រីភាគច្រើនត្រូវបានសង្គមតម្រូវឱ្យបំពេញការងារសេសំខាន់ៗភាគច្រើន ប៉ុន្តែនៅក្នុងការងារក្នុងផ្ទះ និងមើលថែទាំដែលមិនទទួលបានប្រាក់កម្រៃនៅក្នុងគ្រួសារនិងសហគមន៍។ ការនេះបានបង្កជាឧបសគ្គដែលមើលមិនឃើញសម្រាប់ក្មេងស្រី និងរារាំងស្ត្រីមិនឱ្យទទួលបានកម្រិតសិក្សាខ្ពស់ដែលអាចធ្វើឱ្យស្ត្រីទទួលបានការងារមានប្រាក់កម្រៃខ្ពស់ និងកម្រិតជម្រើសជីវិត និងស្វ័យភាពផ្នែកសេដ្ឋកិច្ចក្នុងវដ្តជីវិតរបស់ពួកគេ។

មិនតែប៉ុណ្ណោះ ផ្នត់គំនិតសង្គមបានកម្រិតសមត្ថភាព និងឱកាសរបស់ស្ត្រីក្នុងការចូលរួមក្នុងការងារដែលមានជំនាញច្រើនឬការងារក្នុងវិស័យសាធារណៈ។ ចំណែកឯការចូលរួមក្នុងផ្នែកសេដ្ឋកិច្ចវិញ ការចូលរួមរបស់ស្ត្រីក្នុងសមាគមន៍អាជីវកម្មដែលគ្រប់គ្រងដោយបុរសនៅមានកម្រិត និងក្នុងបណ្តាញជំនាញព័ត៌មានក្រៅ

ផ្លូវការដែលអាចត្រូវបានចែករំលែកសម្រាប់ឱកាស និងការពង្រីកអាជីវកម្ម។ ទោះបីជាស្ត្រីគ្រប់គ្រងមុខរបរប្រមាណជាង៦៥%ក៏ដោយ ក៏ប៉ុន្តែភាគច្រើន អាជីវកម្មទាំងនោះមានទំហំតូចនិងទទួលបានសេវាអភិវឌ្ឍន៍អាជីវកម្មមានកម្រិត។ នៅកម្ពុជាមានស្ត្រីជាអ្នកគ្រប់គ្រងមុខរបរតូចតាច នៅតាមផ្លូវមានប្រមាណ ៧៥,៧% នៃចំនួនមុខរបរតូចតាចសរុប។ ផ្នត់គំនិតដែលយល់ថាស្ត្រីគួរធ្វើតែ ការងារផ្ទះ បានបង្កជារបាំងដល់ស្ត្រីមិនអាចឱ្យពង្រីកអាជីវកម្មរបស់ខ្លួននិងក្នុងវិស័យផ្សេងទៀត។

### ២.១.៦ គម្លាតស្តង់ដារនៃជីវភាពរស់នៅរវាងស្ត្រីនៅជនបទ និងទីក្រុង

ស្តង់ដារជីវភាពរស់នៅរបស់ស្ត្រីនៅតំបន់ជនបទមានគម្លាតខុសគ្នាឆ្ងាយពីស្ត្រីដែលរស់នៅទីក្រុង ដែលជារួមគេ លក្ខណៈនេះបណ្តាលមកពីនៅក្នុងសង្គមជនបទ ប្រជាជននៅប្រកាន់ខ្ជាប់ទស្សនៈបុរាណ ទាក់ទងនឹងការរៀនសូត្រ ការប្រកបកិច្ចការ ការថែរក្សាវ័យ និងការយល់ដឹងទៅលើផ្នែកសុខភាពរបស់ស្ត្រីនៅមានកម្រិតទាបជាងនៅតំបន់ទីក្រុង។ ជាក់ស្តែង យើងអាចសង្កេតឃើញថានៅតំបន់ដាច់ស្រយ៉ាល ស្ត្រីនិងនារីក្មេងៗមិនសូវមានចំណាប់អារម្មណ៍ខ្លាំងទៅលើរបៀបរបបក្នុងការរៀបចំឥរិយាបថ ការស្លៀកពាក់ ការជ្រើសរើសនិងគ្រប់គ្រងអាជីវកម្ម ជម្រើសសម្ភារៈនិងឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន ហើយក៏ពុំសូវជាចាប់អារម្មណ៍ទៅលើការថែទាំសុខភាពខាងក្នុងនិងការរូបរាងខាងក្រៅក្រោយពេលពេញវ័យឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដោយការរៀបចំរបបអាហារឬក៏ការហាត់ប្រាណនោះដែរ ជារួម ស្ត្រីនៅតំបន់ជនបទច្រើនមានទំនោរក្នុងការប្រលែងខ្លួនចោលនិងមិនសូវថែទាំខ្លួនប្រាណឱ្យបានដឹតដល់ដូចស្ត្រីដែលរស់នៅទីក្រុងនោះឡើយ។

ម្យ៉ាងវិញទៀត យោងទៅតាមតថភាពនៅក្នុងប្រទេសកម្ពុជាផ្ទាល់យើងសង្កេតឃើញថា នៅពេលទំនេរពីការប្រកបរបរប្រចាំថ្ងៃ ជាទូទៅស្ត្រីដែលរស់នៅតំបន់ជនបទ ចូលចិត្តចំណាយពេលនៅផ្ទះ រៀបចំផ្ទះសម្បែង ឬទៅលំហែរជជែកគ្នាលេងជាមួយនឹងអ្នកជិតខាងភូមិផងរបងជាមួយគ្នាទៅតាមទម្លាប់រៀងខ្លួនៗ។ ផ្ទុយមកវិញ ស្ត្រីនៅទីក្រុងច្រើនចំណាយពេលវេលាទំនេររបស់ខ្លួនទៅលើសកម្មភាពផ្សេងៗដូចជា ការមើលភាពយន្ត ដើរផ្សារទំនើប ហាត់ប្រាណ ទិញទំនិញ ធ្វើដំណើរទៅទីកន្លែងកំសាន្តផ្សេងៗដែលមាននៅក្នុងក្រុងឬជាយក្រុង បរិភោគអាហារនិងភេសជ្ជៈនៅតាមហាងមួយចំនួន និងចំណាយពេលនៅក្នុងការប្រើប្រាស់បណ្តាញសង្គមផ្សេងៗនៅក្នុងផ្ទះតែម្តង។

ចំពោះការរៀបចំខ្លួនវិញ ស្ត្រីនៅជនបទនិយមការស្លៀកសម្លៀកបំពាក់ជាប្រភេទ អាវកក្អម ខោជើងវែង អាវយឺត ស្លៀកសារ៉ុង ឬសម្លៀកបំពាក់ជាឈុតបែបនៅផ្ទះ ពាក់មួក ចងឬបួងសក់ឡើងលើដោយប្រើដង្កៀបឬក្រចាប់។ ចំពោះនារីក្មេងៗ ជាទូទៅចូលចិត្តស្លៀកខោខាប៊ិយ អាវកជិត បន្ថែមពីលើដោយអាវក្រៅ ឬស្លៀកពាក់បែបចម្រុះពណ៌ ជាមួយនឹងស្បែងជើងរាប ស្បែកជើងផ្ទាត់ ស្បែកជើងស៊ក ឬជាប្រភេទស្បែកជើងស្មោរមានកែងខ្ពស់បន្តិច។ ដោយឡែកពីនេះ ស្ត្រីនៅទីក្រុងនិយមលើការស្លៀកពាក់បែបបើកបង្ហាញ មានដូចជាសំពត់ឬខោខ្លី

អាវវាលក អាវដៃខ្លី ខោក្រណាត់ឬខោសាច់កប្បាស សំពត់ រ៉ូប និងសម្លៀកបំពាក់មានម៉ូដទៅតាមសម័យនិយមផ្សេងទៀត និងមិនមានលក្ខណៈចម្រុះពណ៌ច្រើនដូចនារីនៅតំបន់ជនបទនោះទេ ហើយជាទូទៅពួកគេចូលចិត្តទម្លាក់សក់ លាបពណ៌និងធ្វើម៉ូដផ្សេងៗតាមចំណូលចិត្ត អមជាមួយនឹងស្បែកជើងឃ្លប់មុខមានកែងទាប ស្បែកជើងកីឡា ស្បែកជើងស៊ក និងស្បែកជើងកែងចោត។

ក្រៅពីនេះបើពិនិត្យមើលទៅលើបរិបទនៃការធ្វើអាជីវកម្មវិញ យើងសង្កេតឃើញថា ស្ត្រីនៅតំបន់ជនទច្រើនប្រកបមុខរបរខ្នាតតូចនិងមធ្យមទាក់ទងទៅនឹងការលក់គ្រឿងទេស គ្រឿងឧបភោគបរិភោគ និងផលិតផលកសិកម្មដោយមិនមានធ្វើការសិក្សាទៅលើតម្រូវការអតិថិជនឬការធ្វើទីផ្សារអាជីវកម្ម ក៏ដូចជាវិធីសាស្ត្រក្នុងការផ្សព្វផ្សាយផលិតផលឱ្យបានទូលំទូលាយនោះដែរ ហើយក៏មិនសូវសំបូរចំណេះដឹងក្នុងការជ្រើសរើសផលិតផលយកទៅលក់ឬប្រើប្រាស់ឱ្យបានសមស្របនោះដែរ ភាគច្រើនពួកគេលក់និងប្រើប្រាស់ទំនិញដូចៗគ្នាទៅតាមការនិយមរបស់អ្នកនៅតំបន់នោះនិងស្តាប់ការការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយតៗគ្នា។ មិនខុសគ្នាប៉ុន្មានពីស្ត្រីនៅតំបន់ជនបទនោះទេ ស្ត្រីដែលរស់នៅទីក្រុងក៏ប្រកបរបរខ្នាតតូចនិងមធ្យមដូចគ្នាដែរ ប៉ុន្តែអ្វីដែលខុសគ្នានោះគឺ ស្ត្រីនៅទីក្រុងមានទំនោរក្នុងការលក់ផលិតផលជាប្រភេទគ្រឿងសំអាង សម្លៀកបំពាក់ កាបូប ស្បែកជើង គ្រឿងអលង្ការ និងអាហារសម្រន់ដែលមានជាប្រភេទនំបរទេសនិងភេសជ្ជៈដូចជា កាហ្វេ តែ និងទឹកផ្លែឈើផ្សេងទៀតដែលមានការកែច្នៃរសជាតិបែបថ្មី។ មិនតែប៉ុណ្ណោះ ការធ្វើអាជីវកម្មរបស់ពួកគេ មានការពឹងផ្អែកទៅលើរបៀបនៃការធ្វើទីផ្សារដើម្បីទាក់ទាញអតិថិជនគោលដៅ ការប្រកួតប្រជែងលើថ្លៃនិងគុណភាព ព្រមទាំងសេវាកម្មមួយចំនួនទៀតមានដូចជាការដឹកជញ្ជូនពីទីតាំងលក់ទៅកាន់ទីកន្លែងរបស់អតិថិជនផងដែរ។ លើសពីនេះទៅទៀត ស្ត្រីខ្លះថែមទាំងបានរៀនពីរបៀបរបបក្នុងការរៀបចំផែនការអាជីវកម្ម ការគ្រប់គ្រងទីផ្សារ ស្តុកទំនិញតាមរយៈការរៀនជំនាញនៅតាមគ្រឹះស្ថានបណ្តុះបណ្តាល ក៏ដូចជាការចូលរួមទៅក្នុងវគ្គសិក្សាខ្លីៗ និងការស្វែងយល់បន្ថែមតាមរយៈប្រព័ន្ធអនឡាញ និងមានការជួបពិភាក្សាជាមួយនឹងដៃគូរអាជីវកម្មទាំងក្នុងនិងក្រៅប្រទេសថែមទៀតផង។

នេះគ្រាន់តែជាឧទាហរណ៍ខ្លះៗនៅក្នុងទិដ្ឋភាពសង្គមជាក់ស្តែង ដែលអាចសបញ្ជាក់ឱ្យឃើញថា ស្តង់ដាជីវភាពរស់នៅរបស់ស្ត្រីនៅតំបន់ជនបទនិងទីក្រុងមានគម្លាតខុសពីគ្នាឆ្ងាយ ហើយការរស់នៅរបស់ស្ត្រីនៅតំបន់ជនបទពុំសូវមានលក្ខណៈសម្បូរបែបដូចស្ត្រីនៅទីក្រុងនោះទេ ពោលគឺ មានលក្ខណៈអន់ថយនៅឡើយ។

វិសមភាពនៃគម្លាតស្តង់ដាជីវភាពរស់នៅរបស់ស្ត្រីនៅតំបន់ជនបទនិងទីក្រុងបណ្តាលមកពីកត្តាមួយចំនួនដូចតទៅ៖

- **បរិដ្ឋានរស់នៅជុំវិញខ្លួន៖** ដូចការលើកឡើងពីខាងដើម សង្គមជនបទពុំទាន់មានលក្ខណៈជឿនលឿននៅឡើយ ហើយលទ្ធភាពនៃការទទួលបានការសិក្សាអប់រំនៅមានកម្រិត បូករួមទាំងនៅមានការរក្សា

ផ្នត់គំនិតបុរាណក្នុងការរស់នៅប្រចាំថ្ងៃ និងពុំសូវបានជួបប្រទះនឹងបទពិសោធន៍ឬមនុស្សថ្មីៗផងនោះ ស្ត្រីនៅតំបន់ជនបទកម្រនឹងមានទស្សនៈក្នុងការអភិវឌ្ឍខ្លួនបន្ថែមពីលើសមត្ថភាពដែលមានស្រាប់ណាស់ ហើយម្យ៉ាងវិញទៀតទេពកោសល្យរបស់ស្ត្រីក៏អាចនឹងត្រូវបានកប់ចោលទៅក្នុងការងារផេតកម្រៃផ្សេងទៀតដូចជា ការចាប់យកការងារខាងផ្ទះនិងការធានាខុសត្រូវទៅលើការទទួលបន្ទុកចិញ្ចឹម និងមើលថែគ្រួសារជាដើម។ ផ្ទុយមកវិញ ស្ត្រីដែលរស់នៅទីក្រុងមានឱកាសច្រើនជាងក្នុងការទទួលបានការសិក្សាខ្ពស់ និងចូលប្រឡូកក្នុងកិច្ចការខាងក្រៅផ្ទះ ហើយក៏មានឱកាសក្នុងការបានជួបនឹងទិដ្ឋភាពថ្មីៗ មនុស្សប្លែកៗ និងទទួលបានចំណេះដឹងថ្មីៗបន្ថែមពីលើអ្វីដែលខ្លួនចេះស្រាប់កាន់តែប្រសើរឡើងមួយកម្រិតទៀត។

- **ភាពខ្សត់ខ្សោយនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គម៖** ដោយសារការអភិវឌ្ឍនៅមានកម្រិតទាបនៅឡើយ ធ្វើឱ្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទនៅមានភាពខ្វះខាតនៅឡើយ ជាពិសេស សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ និងមធ្យោបាយធ្វើដំណើរផ្សេងៗទៀត។ កត្តានេះ ជាមូលហេតុមួយដែលធ្វើឱ្យស្ត្រីនៅតំបន់ជនបទមានឱកាសតិចក្នុងការទទួលបានការរៀនសូត្រ និងការទទួលបានសេវាសាធារណដទៃទៀតដូចជាការថែទាំសុខភាពតិច ដោយសារបញ្ហាផ្ទះនៅឆ្ងាយពីសាលារៀន និងជួបប្រទះភាពលំបាកនៅក្នុងការធ្វើដំណើរនិងការធានាលើផ្នែកសុវត្ថិភាពផងដែរ។
- **កត្តាជីវភាព៖** កត្តាជីវភាពក៏ជាផ្នែកមួយក្នុងការធ្វើឱ្យស្ត្រីមានលទ្ធភាពតិចក្នុងការទទួលបានការអប់រំខ្ពស់ផងដែរ ពីព្រោះកាលណាគ្រួសារមានជីវភាពទាបនារីៗមានទំនោរក្នុងការបោះបង់ការសិក្សាពាក់កណ្តាលទីដើម្បីស្វែងរកការងារធ្វើរកចំណូលមកជួយផ្គត់ផ្គង់គ្រួសារ ជាហេតុធ្វើឱ្យស្ត្រីមានចំណេះដឹងទាបនិងជួបប្រទះនូវភាពលំបាកក្នុងការអភិវឌ្ឍខ្លួនឱ្យទាន់ទៅនឹងសង្គមដែលមានការធ្វើទំនើបកម្ម។

ទាំងនេះជាដើមចមដែលធ្វើឲ្យមានស្តង់ដាជីវភាពរស់នៅរវាងស្ត្រីដែលរស់នៅតំបន់ជនបទនិងទីក្រុង។

## ២.២. របាំងរារាំងដល់ការអភិវឌ្ឍ

### ២.២.១ កត្តាផ្នត់គំនិត

បញ្ហាផ្នត់គំនិតនៅតែជាឧបសគ្គមួយដែលបន្តរារាំងការអភិវឌ្ឍស្ត្រីរហូតមកដល់ពេលបច្ចុប្បន្ន ហើយវាក៏ជាកត្តាមួយដែលចាក់ឫសជ្រៅចូលទៅក្នុងចិត្តគំនិតបុគ្គល ធ្វើឱ្យស្ត្រីពិបាកក្នុងការផ្លាស់ប្តូរទទួលយកការកែប្រែថ្មីរបស់សង្គមទាក់ទងទៅនឹងបរិបទក្នុងការរស់នៅ ក៏ដូចជាការឈានជើងប្រឡូកទៅក្នុងការបម្រើការនៅក្នុងវិស័យសាធារណៈនិងវិស័យសេដ្ឋកិច្ចតាមបែបថ្មីផងដែរ។

បញ្ហានេះកើតឡើងដោយសារ ផ្នត់គំនិតសង្គមបានដាក់សម្ពាធឱ្យស្ត្រីស្ថិតនៅក្រោមបង្គាប់ និងមិនសូវបានបង្ហាញពីគំនិតនិងយោបល់របស់ខ្លួនជាសាធារណៈ។ ហើយផ្នត់គំនិតសង្គមដដែលនោះក៏នៅតែបន្តមាន

ការប្រកាន់រើសអើងភេទចំពោះស្ត្រីនៅក្នុងការប្រកបកិច្ចការផងដែរ ដោយយល់ថា ស្ត្រីមានលក្ខណៈមិនគ្រប់គ្រាន់ក្នុងការចូលរួមក្នុងវិស័យនយោបាយឡើយ ដែលជាមូលដ្ឋានមួយក្នុងការធ្វើឱ្យស្ត្រីក្លាយជាមនុស្សបន្ទាប់បន្សំនិងត្រូវបានបែងចែកនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចនៅមានកម្រិត។ម្យ៉ាងវិញទៀត ជំនឿជាប្រពៃណី ដែលមិនបានឱ្យតម្លៃលើសមត្ថភាព និងសក្តានុពលរបស់ស្ត្រី គឺជាឧបសគ្គដែលរារាំងក្នុងការចូលរួមយ៉ាងសកម្មរបស់ស្ត្រី។ ប្រការនេះពិតជាកើតមានសម្រាប់ស្ត្រីវ័យក្មេងដែលជឿថា ពួកគេមិនសូវមានសមត្ថភាពដូចបុរស ហើយមិនសូវសក្តិសមក្នុងមុខតំណែងសំខាន់ៗក្នុងវិស័យនយោបាយនិងអភិបាលកិច្ច។ ជាទូទៅ ស្ត្រីមានបទពិសោធន៍តិចក្នុងភាពជាអ្នកដឹកនាំ ការគ្រប់គ្រងនិងក្នុងវិស័យនយោបាយ។

មិនតែប៉ុណ្ណោះ វិសមភាពយេនឌ័រនិងការឱ្យតម្លៃលើបុរសជាងស្ត្រីនូវតែបន្តមានមិនថានៅកន្លែងការងារឬក្នុងសង្គម ជាពិសេសនៅក្នុងសង្គមដែលឲ្យតម្លៃខ្ពស់ដល់មនុស្សប្រុស ការរំពឹងទុករបស់សង្គមទៅលើតួនាទីរវាងមនុស្សប្រុស និងមនុស្សស្រីនៅតែបន្តកើតមានឡើង។ បទដ្ឋានសង្គមខ្មែរ បានធ្វើឱ្យប្រជាជននៅតែយល់ឃើញថាការងារផ្ទះ ការមើលថែទាំសមាជិកគ្រួសារជាកិច្ចការងាររបស់ស្ត្រីដែលត្រូវទទួលខុសត្រូវតែម្នាក់គត់។ការនេះបង្ករជាឧបសគ្គដែលមើលមិនឃើញសម្រាប់ក្មេងស្រី និងរារាំងស្ត្រីមិនឲ្យទទួលបានកម្រិតសិក្សាខ្ពស់ដែលធ្វើឱ្យស្ត្រីមិនទទួលបានការងារមានប្រាក់កម្រៃខ្ពស់ និងកម្រិតជម្រើសជីវិតនិងស្វ័យភាពផ្នែកសេដ្ឋកិច្ចនៅក្នុងវដ្តជីវិតរបស់ពួកគេ។

ស្ត្រីមានលទ្ធភាពតិចតួចជាងបុរស ក្នុងទទួលបានធនធានដើម្បីពង្រីកអាជីវកម្មរបស់ខ្លួនដោយសារតែផ្នត់គំនិតសង្គមដែលធ្វើឲ្យស្ត្រីមានអំណាចតិចជាងបុរសក្នុងដំណើរការធ្វើសេចក្តីសម្រេច។ ស្ត្រីក៏ប្រឈមនឹងឧបសគ្គផ្នែកវប្បធម៌ផ្អែកលើផ្នត់គំនិតនិងអាកប្បកិរិយា ព្រមទាំងបញ្ហាប្រឈមទាក់ទងនឹងតុល្យភាពការងារនិងជីវិតផងដែរ។

ឥទ្ធិពលប្រពៃណីនិងផ្នត់គំនិតរបស់ស្ត្រីរួមផ្សំនឹងនិន្នាការនយោបាយនៅកម្ពុជាផងនោះ បានជះឥទ្ធិពលដល់ការចូលរួមរបស់ស្ត្រីនៅក្នុងជីវិតនយោបាយ។ ស្ត្រីត្រូវបានសង្កេតឃើញថា ការរួមចំណែកសំខាន់នឹងគោលការណ៍វប្បធម៌ ប្រពៃណី ទំនៀមទំលាប់កំណត់ដោយច្បាប់ស្រីដែលទូន្មានស្ត្រីពីតួនាទីដែលត្រូវប្រតិបត្តិស្វាមី និងកិច្ចការផ្ទះសំបែង។ នេះមានន័យថាស្ត្រីដែលអាចប្រឡូកក្នុងនយោបាយនិងត្រូវទទួលបន្ទុកគឺពួកគាត់មិនត្រឹមតែត្រូវទទួលខុសត្រូវលើការងារការិយាល័យមួយមុខនោះទេ តែថែមទាំងត្រូវរ៉ាប់រងនូវកិច្ចការផ្ទះផងដែរ។ ការយល់ច្រលំអាចនឹងនូវតែបន្តមាន ដែលថាស្ត្រីមិនអាចធ្វើការដូចបុរស ខ្សោយជាងបុរស មិនអាចដោះស្រាយនិងបញ្ហាសន្តិសុខនៅក្នុងសហគមន៍ពួកគាត់ ហើយនូវតែមិនអាចទទួលរ៉ាប់រងការងារផ្សេងទៀតដូចបុរសបានដូចជាពាក្យមួយដែលគេចំណាំនិយាយតគ្នាថា "មនុស្សស្រីមុជមិនជ្រៅ ទៅមិនឆ្ងាយ ឬស្ត្រីបង្វិលចង្ក្រានមិនជុំ"

ជាដើម ដែលសុតសឹងជាទស្សនៈជាន់ពន្លិចសមត្ថភាពនិងទេពកោសល្យស្ត្រីមិនឱ្យមានការរីកលូតលាស់ ឬទទួលបានឱកាសក្នុងការអភិវឌ្ឍខ្លួនបន្ថែម។

### ២.២.២ កត្តាប្រពៃណី និងទំនៀមទំលាប់

ប្រពៃណីនិងទំនៀមទម្លាប់មួយភាគធំបានចងជីវិតនិងដាក់គំនាបទៅលើការរស់នៅរបស់ស្ត្រីយ៉ាងខ្លាំងក្លា ជាពិសេសទៅលើរបៀបក្នុងការជ្រើសរើសប្រើប្រាស់ជីវិតផ្ទាល់ខ្លួនរបស់ស្ត្រី ទាក់ទងទៅការស្វែងរកប្រាក់ចំណូល ការបញ្ចេញមតិយោបល់ ការរស់នៅប្រចាំថ្ងៃ ជម្រើសជីវិតក៏ដូចជាសិទ្ធិក្នុងការជ្រើសរើសគូស្រករផងដែរ។ ស្ត្រីនៅតែ បន្តជួបនឹងភាពលំបាកទាំងនេះ ដោយសាមូលហេតុធំមួយគឺ ការរស់នៅក្នុងសង្គមរើសអើងផ្តល់តម្លៃទៅឱ្យមនុស្សប្រុសខ្លាំងជាងមនុស្សស្រី ដូចជាទស្សនៈមួយលើកឡើងថា "បុរសគួរធ្វើជាអ្នកដឹកនាំ និងជាអ្នកការពារ" នៅតែបន្តមាននៅក្នុងសង្គម។ មិនតែប៉ុណ្ណោះ តាមការសិក្សារបស់អង្គការយេនឌ័រ និងអភិវឌ្ឍន៍កម្ពុជាឆ្នាំ ២០១០ បានបញ្ជាក់ថា បុរសមួយចំនួនប្រកាន់នូវគោលគំនិតថា បុរសគួរបំពេញតួនាទីជាមេគ្រួសារ ជាអ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុក្នុងគ្រួសារ និងគ្រប់គ្រងស្ត្រី។ ជាធម្មតាការដែលស្ត្រីឱ្យបុរសមានបុព្វសិទ្ធិគ្រប់គ្រងលើស្ត្រីក៏ជាបញ្ហាមួយផងដែរ។ ស្ត្រីមួយចំនួនមិនមានទំនុកចិត្តលើសមត្ថភាពរបស់ខ្លួនដោយសារតែផ្នត់គំនិតនិងឥរិយាបថសង្គម។ តាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ ២០១០ បានបង្ហាញថា ស្ត្រីភាគច្រើនមិនជឿថា ប្រពន្ធគួរមានសិទ្ធិបញ្ចេញមតិយោបល់របស់ខ្លួនឡើយ។ ការសិក្សារបស់កម្មវិធីជាដៃគូរដើម្បីទប់ស្កាត់ឆ្នាំ ២០១៣ ក៏បានរកឃើញផងដែរថាមានបុរស ៦២,៦% និងស្ត្រី៥៧.១% យល់ស្របថា បុរសគួរជាអ្នកសម្រេចចិត្តចុងក្រោយគ្រប់បញ្ហាគ្រួសារទាំងអស់ ហើយបុរសនិងស្ត្រីជឿថា បុរសមានសិទ្ធិធ្វើជាអ្នកសម្រេចចិត្តដ៏សំខាន់ក្នុងគ្រួសាររបស់ខ្លួន។ ការពឹងផ្អែករបស់ស្ត្រីលើស្វាមីនៅក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យឯកជនមិនអាចមើលឃើញឡើយ ក៏ប៉ុន្តែបានឆ្លុះបញ្ចាំងពីកម្រិតនៃភាពក្លាហាននិងភាពជឿជាក់របស់ស្ត្រី ក្នុងការចូលរួមធ្វើសេចក្តីសម្រេចនៅក្នុងវិស័យសាធារណៈ។

មិនតែប៉ុណ្ណោះ គេសង្កេតឃើញថា អាពាហ៍ពិពាហ៍ដោយបង្ខំនៅតែបន្តកើតមាន ហើយនៅពេលដែលបានរៀបការជាប្តីប្រពន្ធមានការដាក់សម្ពាធយ៉ាងខ្លាំងលើពួកគេឱ្យរក្សាឱ្យបាននូវចំណងអាពាហ៍ពិពាហ៍។ ទម្លាប់នៃការរៀបអាពាហ៍ពិពាហ៍ពីវ័យក្មេងនៅតែកើតមាន ហើយឪពុកម្តាយមួយចំនួនបានដាក់សម្ពាធលើកូនស្រីឱ្យរៀបការជាមួយបុរសដែលគាត់បានជ្រើសរើសតាំងពីនាងនៅក្មេង។

លើសពីនេះទៅទៀត ការលែងលះ គឺត្រូវបានចាត់ទុកថាជាទង្វើរដ៏គួរឱ្យខ្មាស់អៀន ជាពិសេសប្រសិនបើស្ត្រីជាអ្នកផ្តើមគំនិតលែងលះ។ ជារឿយៗ ការលែងលះបានដាក់ស្ត្រីទៅក្នុងស្ថានភាពមួយកាន់តែរងគ្រោះដោយសារតែពួកគេអាចខ្វះសមត្ថភាពក្នុងការទាមទារសិទ្ធិទទួលបានទ្រព្យសម្បត្តិរបស់ខ្លួន និងការអនុវត្តន៍ទាក់ទងនឹងអាហារកិច្ចមិនបានសមស្រប។ ឧបសគ្គជាក់លាក់របស់ស្ត្រី និងការមាក់ងាយជុំវិញបញ្ហាលែងលះ

នៅតែមិនទាន់ដឹងច្បាស់ ហើយត្រូវធ្វើការស្រាវជ្រាវដើម្បីជម្រុញគោលនយោបាយឱ្យធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពសម្រាប់អត្ថប្រយោជន៍របស់ស្ត្រី និងកូន ដែលងាយរងគ្រោះ ពាក់ព័ន្ធទៅនឹងបញ្ហាការទទួលកេរ្តិ៍មរតក ទ្រព្យជាកម្មសិទ្ធិ និងទ្រព្យសម្បត្តិព្រមទាំងទទួលរងការរើសអើងក្នុងសង្គម និងក្លាយជាកូនដែលមានតែម្តាយ។ ការណ៍នេះ បានធ្វើឱ្យស្ត្រីជាច្រើន ត្រូវទ្រាំរស់នៅក្នុងជីវិតគ្រួសារមួយដែលមានភាពរកាំរកូស មិនមានសន្តិសុខផ្លូវកាយនិងផ្លូវចិត្ត ដោយសារតែរងគំនាបនិងការមើលស្រាយពីសង្គមទៅលើភាពបរាជ័យនៃជីវិតអាពាហ៍ពិពាហ៍ និងសុខចិត្តទ្រាំទ្រនឹងភាពលំបាក ឬពេលខ្លះអាចត្រូវប្រឈមមុខនឹងអំពើហិង្សាពីសំណាក់បុរសជាមេគ្រួសារថែមមួយកម្រិតទៀតផង។

បញ្ហានេះបានធ្វើឱ្យស្ត្រីជាច្រើនទទួលរងនូវសម្ពាធនិងការរើសអើង ជាពិសេសនៅពេលដែលផ្នត់គំនិតសង្គម បានដាក់គំនាបលើស្ត្រីដែលមានប្រវត្តិខុសៗគ្នា ដូចជាវណ្ណៈ អាយុ ពិការភាព ជាតិពន្ធុ និងនិន្នាការផ្លូវភេទ។ តម្រូវការខុសៗគ្នារបស់ស្ត្រីដែលមានភាពងាយគ្រោះទាំងនេះ ទទួលបានការយកចិត្តទុកដាក់នៅមានកម្រិតទាបនៅឡើយ។ ការស្រាវជ្រាងផ្អែកតាមភស្តុតាង គឺមានសារសំខាន់ណាស់ក្នុងការជំរុញឱ្យមនាការយកចិត្តទុកដាក់ដល់ការឆ្លើយតបកម្រិតគោលនយោបាយសមស្រប។ កង្វះខាតទិន្នន័យនិងស្ថិតិច្បាស់លាស់នៅក្នុងការវិភាគស៊ីជម្រៅពីភាពងាយរងគ្រោះរបស់ពួកគេធ្វើឱ្យអ្នកតាក់តែងគោលនយោបាយមិនអាចធ្វើអន្តរាគមន៍ដល់រាល់បញ្ហាកើតឡើងប្រកបដោយប្រសិទ្ធភាពនោះទេ។

### ២.២.៣ កត្តាសេដ្ឋកិច្ច និងពេលវេលា

កត្តាសេដ្ឋកិច្ចនិងពេលវេលាក៏ជាផ្នែកមួយដែលជះឥទ្ធិពលទៅលើការអភិវឌ្ឍស្ត្រីផងដែរ ពីព្រោះកាលណាគ្រួសារមានកម្រិតជីវភាពនាវីៗនៅតំបន់ជនបទ មានទំនោរក្នុងការបោះបង់ការសិក្សាចោលពាក់កណ្តាលទីរួចទៅស្វែងរកការងារធ្វើដើម្បីជួយទ្រទ្រង់ជីវភាព និងមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការទៅទទួលយកការបណ្តុះបណ្តាលនៅសាលារៀន ជាហេតុធ្វើឱ្យស្ត្រីខ្វះចំណេះដឹងនិងជំនាញក្នុងការអភិវឌ្ឍសមត្ថភាពខ្លួនឱ្យកាន់តែពូកែ និងមានភាពលំបាកក្នុងការផ្លាស់ប្តូរកម្រិតជីវភាពរបស់ខ្លួនឱ្យមានការកើនឡើងជាមុនបាន។ មិនតែប៉ុណ្ណោះ បន្ថែមពីលើបញ្ហាជីវភាពទាប ស្ត្រីក្មេងៗខ្លះទៀតត្រូវចំណាយពេលមួយភាគធំ ទៅលើការទទួលរ៉ាប់រងលើការធ្វើកិច្ចការក្នុងផ្ទះជំនួសម្តាយឪពុក ដែលធ្វើឱ្យពួកគេកាន់តែមានឱកាសកាន់តែតិចក្នុងការរៀនសូត្រទាំងក្នុងនិងក្រៅប្រព័ន្ធអប់រំ។

### ២.២.៤. កត្តាកង្វះការលើកទឹកចិត្ត

ការលើកទឹកចិត្ត គឺជាកត្តាមួយដ៏សំខាន់និងអាចជួយឱ្យជួយជម្រុញឱ្យស្ត្រីកាន់តែមានភាពស្វាហាប់ក្នុងការអភិវឌ្ឍសមត្ថភាព ទទួលបាននូវគំនិតថ្មីៗ និងអាចកសាងខ្លួនឱ្យកាន់តែរឹងមាំនិងជម្នះឧបសគ្គនានា។ ប៉ុន្តែ នៅក្នុងទិដ្ឋភាពជាក់ស្តែង ស្ត្រីនៅតំបន់ជនបទមិនត្រឹមតែមិនទទួលបានការលើកទឹកចិត្តនោះទេ ផ្ទុយទៅ

វិញពួកគេច្រើនតែទទួលបានការបន្ទុះបង្អាប់ និងការជាន់ពន្លិចថែមមួយកម្រិតទៀត ជាពិសេសនៅពេលដែលសហគមន៍ឬតំបន់ដែលពួកគេរស់នៅ សំបូរទៅដោយមនុស្សដែលមានផ្នត់គំនិតចាស់គំរឹលឬអភិរក្សនិយមជ្រុលដែលជារឿយៗបញ្ហានេះបានធ្វើឱ្យស្រ្តីខ្វះទំនុកចិត្តក្នុងការបន្តដំណើរឆ្ពោះទៅរកក្តីស្រម៉ៃដែលខ្លួនចង់បាន។

ជាងនេះទៅទៀតនៅក្នុងទិដ្ឋភាពសង្គមជាក់ស្តែងសម្លេងអវិជ្ជមានទាំងនោះ បានធ្វើឱ្យស្រ្តីខ្លះចុះចាញ់និងបោះបង់គោលជំហររបស់ខ្លួនចោលថែមទៀតផង។ ជាឧទាហរណ៍ នៅពេលដែលនារីម្នាក់មានគោលបំណងចង់បន្តការសិក្សារបស់ខ្លួនឱ្យបានខ្ពស់ អ្នកដែលនៅជុំវិញខ្លួននារីនោះច្រើនពោលពាក្យថា" មិនដឹងរៀនច្រើនពេកធ្វើអីទេ បើគង់តែរៀនចប់រៀបការក្លាយជាប្រពន្ធគេ នៅផ្ទះមើលកូនដដែល " ឬអ្នកខ្លះទៀតនិយាយថា "មនុស្សស្រីរៀនខ្ពស់ពេក មិនងាយមានអ្នកយកទេ ដឹងតែនៅក្រមុំចាស់ហើយ" ។ល។ ពាក្យសំដីបំបាក់ទឹកចិត្តទាំងនេះភាគច្រើនគេគិតថាជាការនិយាយលេងសើច តែតាមពិតទៅវាបានបង្កប់នូវផ្នត់គំនិតនៃការរើសអើងស្រ្តីនៅក្នុងនោះ ដោយមានន័យថា មនុស្សស្រីមិនចាំបាច់រៀនសូត្រខ្ពង់ខ្ពស់អីនោះទេ ទោះបីជារៀនហើយក៏មិនបានធ្វើការងារធំដុំអីផ្សេងក្រៅពីនៅផ្ទះមើលកូនដែរ ហើយអាចនឹងប្រឈមនឹងការមិនមានអ្នកដណ្តឹងយកធ្វើជាភរិយាទៀតផង។ ការណ៍នេះបញ្ជាក់ថា ទស្សនៈរបស់សង្គមចំពោះស្រ្តីគឺ កើតមកដើម្បីតែរៀបអាពាហ៍ពិពាហ៍ និងមើលថែផ្ទះសម្បែងប៉ុណ្ណោះ។ ហើយផ្នត់គំនិតអវិជ្ជមានដដែលនេះ ក៏បានធ្វើឱ្យស្រ្តីខ្លះជឿតាម និងយល់ព្រមបោះបង់ការតាំងចិត្តរបស់ខ្លួន ដោយសាចាញ់នឹងពាក្យសម្តីបំផ្លាញជំនឿចិត្តទាំងនេះ ដែលបញ្ហានេះនៅតែបន្តកើតមាននៅក្នុងសង្គមសព្វថ្ងៃនិងក្លាយជាឧបសគ្គដល់ការអភិវឌ្ឍស្រ្តី ជាពិសេសនារីដែលរស់នៅតំបន់ដាច់ស្រយ៉ាល។

## ២.៣ មូលហេតុដែលទាមទារឲ្យមានការអភិវឌ្ឍស្រ្តីនៅតំបន់ជនបទ

ស្រ្តីនៅតាមតំបន់ជនបទ គឺជាភ្នាក់ងារដ៏សំខាន់សម្រាប់ការអភិវឌ្ឍ។ ពួកគេដើរតួនាទីជាកាតាលីករឆ្ពោះទៅរកសមិទ្ធិផលនៃការកែប្រែសេដ្ឋកិច្ចបរិស្ថាននិងសង្គមដែលត្រូវការ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ដោយមើលឃើញពីលក្ខណៈពិសេសនេះហើយ ទើបបានជាមានការទាមទាឱ្យធ្វើការអភិវឌ្ឍស្ត្រីដោយផ្អែកទៅលើមូលហេតុមួយដូចខាងក្រោម៖

- កសាងធនធានមនុស្ស
- អាចឱ្យស្ត្រីមានឱកាសក្នុងការបញ្ចេញសក្តានុពលពីខាងក្នុង
- បញ្ចេញសមត្ថភាពក្នុងតួនាទីជាអ្នកដឹកនាំ
- ទទួលបានការអភិវឌ្ឍនិងពង្រឹងសមត្ថភាព
- កាត់បន្ថយគម្លាតស្តង់ដាជីវភាពនៃការរស់នៅរវាងស្ត្រីនៅជនបទ និងទីក្រុង។

### ២.៣.១ ការកសាងធនធានមនុស្ស

ស្ត្រីជាធនធានមនុស្សដែលមានសក្តានុពលបំផុតសម្រាប់ការកសាងប្រទេសជាតិ ពីព្រោះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដោយមិនគិតពីតួនាទីនៅក្នុងការងារការិយាល័យ ស្ត្រីមានភារកិច្ចចម្បងមួយគឺ ការដើរតួនាទីជាអ្នកអប់រំណែនាំ ប្រៀនប្រដៅ និងតម្រែតម្រង់ផ្លូវរបស់បុត្រធីតាដែលជាទំពាំងស្នងឫស្សីរបស់ជាតិ ពោលគឺជា "គ្រូទី១" របស់កូនៗ ដែលចាំចង្អុលបង្ហាញទៅលើផ្នែកឥរិយាបថ សុជីវធម៌ សីលធម៌ និងបំណិនជីវិត។ ដូច្នេះហើយ កាលណាមានការវិនិយោគលើកកម្ពស់សមត្ថភាពស្ត្រីកាន់តែច្រើន នោះស្ត្រីកាន់តែអាចមានលទ្ធភាពខ្ពស់ក្នុងការប្រៀនប្រដៅកូនចៅបានកាន់តែល្អប្រសើរឡើងមួយកម្រិតទៀត ជាពិសេសគឺអាចយល់ដឹងកាន់តែច្រើនទៅលើរបៀបចិញ្ចឹមកូនតាមបែបថ្មីដោយផ្អែកលើរបកគំហើញខាងផ្នែកវិទ្យាសាស្ត្រ និងអាចបង្រៀនកូនឱ្យក្លាយជាធនធានមនុស្សដ៏ល្អសម្រាប់សង្គមជាតិផងដែរ។ ផ្ទុយមកវិញ ប្រសិនបើស្ត្រីជាម្តាយមានចំណេះដឹងតិច នោះការចិញ្ចឹមកូនរបស់ស្ត្រីនោះក៏មិនសូវមានភាពជឿនលឿនប៉ុន្មានដែរ ជាពិសេសស្ត្រីនៅតំបន់ជនបទ ពោលគឺភាគច្រើនការចិញ្ចឹមកូនរបស់ពួកគេពឹងផ្អែកទៅលើជំនឿមិនសមហេតុផលមួយចំនួនទៅវិញ ហើយក៏ពុំសូវមានលទ្ធភាពក្នុងការណែនាំប្រដៅកូនឱ្យចេះដឹងពីរបៀបរបបក្នុងការប្រព្រឹត្តទៅរបស់អាកប្បកិរិយាខ្លួនថាជាអំពើអសីលធម៌ ឬជាឥរិយាបថប្រសើរនោះដែរ។ ជាឧទាហរណ៍ នៅពេលកុមារម្នាក់ប្រព្រឹត្តកិរិយាឬនិយាយស្តីមិនសមរម្យ គេច្រើនពោលទៅវិញថា "ម្តាយមិនចេះប្រដៅកូន" ឬ "កូនគ្មានម្តាយប្រដៅ" ដែលពាក្យពោលនេះបានសបញ្ជាក់យ៉ាងច្បាស់ពីតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងការចូលរួមបណ្តុះបណ្តាលធនធានមនុស្សក្រោមរូបភាពជាម្តាយ និងបានបង្ហាញពីកម្រិតចេះដឹងរបស់ស្ត្រីក្នុងការប្រៀនប្រដៅបុត្រធីតាផងដែរ។ លក្ខណៈនេះ មិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ សូម្បីតែនៅក្នុងប្រទេសចិននិងសឹង្ហបុរីក៏មានការយល់ឃើញដូចគ្នាផងដែរ ទាក់ទងទៅនឹងសមត្ថភាពរបស់ស្ត្រីក្នុងនាមជាម្តាយនិងជាអ្នកបង្ហាត់បង្ហាញធនធានមនុស្សតាមរយៈសុភាសិតមួយឃ្លាថា "បើនៅក្នុងគ្រួសារមួយមានបុរសពូកែម្នាក់ គ្រួសារនោះពូកែបានមួយជំនាន់ តែបើក្នុងគ្រួសារមួយមាននារីពូកែម្នាក់ គ្រួសារនោះពូកែបានប្រាំបួនជំនាន់" ហើយលោក **លី ក្វាន់យូ** ស្ថាបនិកប្រទេសសឹង្ហបុរីក៏ធ្លាប់មានទស្សនៈស្រដៀងគ្នានេះ ដោយលោកយល់ថា " ប្រជាជនសឹង្ហបុរីមុននឹងរៀបអាពាហ៍ពិពាហ៍ ត្រូវបំពេញភារកិច្ចសំខាន់មួយសិន គឺត្រូវរៀនឱ្យចប់យ៉ាងហោចណាស់ត្រឹមថ្នាក់បរិញ្ញាប័ត្រទាំងបុរសនិងស្ត្រី បើមិនដូច្នេះមិនអនុញ្ញាត្តិឱ្យរៀបការបង្កើតគ្រួសារឡើយ។ ពីព្រោះដើម្បីឱ្យធនធានមនុស្សជំនាន់ក្រោយរបស់ប្រទេសជាតិខ្លាំងពូកែ លុះត្រាតែម្តាយឪពុកដែលជាអ្នកដឹកនាំគ្រួសារមានចំណេះដឹងនិងសមត្ថភាពពូកែដែរ ទើបកូនៗពូកែ។" យោងទៅតាមសុភាសិតនិងទស្សនៈនេះ យើងឃើញថាក្នុងដំណើរការអភិវឌ្ឍធនធានមនុស្សនិងការកសាងប្រទេសជាតិឱ្យមានភាពរីកចម្រើន គឺត្រូវការវត្តមានស្ត្រីជាចាំបាច់ ពីព្រោះស្ត្រីជាអ្នកបង្កើតនិងបង្ហាត់បង្ហាញធនធានមនុស្សជំនាន់ក្រោយដ៏មានឥទ្ធិពលបំផុត។

ម្យ៉ាងវិញទៀត បើពិនិត្យមើលទៅលើការងារខាងក្រៅផ្ទះ ស្ត្រីក៏បានជួយចូលរួមទៅក្នុងសកម្មភាពសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ប្រទេសជាតិយ៉ាងសស្រាក់សស្រាំផងដែរ គ្រាន់តែស្ត្រីពុំសូវទទួលបានការផ្ដល់ចំណាប់អារម្មណ៍ខ្ពស់និងការលើកតម្កើងដូចបុរសតែប៉ុណ្ណោះ ដោយសារចំនួនស្ត្រីដែលស្ថិតនៅក្នុងតំណែងលំដាប់កំពូលមានតិចជាង ជាក់ស្តែងដូចជាអ្នកប្រាជ្ញស្ត្រីដ៏ល្បីល្បាញនៅក្នុងប្រវត្តិសាស្ត្រសកលផ្នែកគីមីនិងរូបវិទ្យាលោកស្រី **ម៉ារី យូរី** (Marie Curie) និងលោកស្រី **ហ្វ្លរ៉េង់ស៍ ណៃធីងហ្គែល** (Florence Nightingale) ដែលជាស្ថាបនិកនៃវេជ្ជសាស្ត្រទំនើបក្នុងសតវត្សទី ១៨ ដែលនៅក្នុងជំនាន់នោះជាជំនាន់ដែលសំបូរទៅដោយអ្នកប្រាជ្ញល្បីៗជាច្រើនរូបដែលសុតសឹងជាបុរស ដូច្នេះវត្តមានរបស់ លោកស្រី យូរី និង លោកស្រី ណៃធីងហ្គែល ជាទិដ្ឋភាពមួយដែលកម្រមាននៅក្នុងប្រវត្តិសាស្ត្រ។

ភស្តុតាងទាំងនេះបង្ហាញថា ស្ត្រីក៏ជាធនធានមនុស្សដែលមានសមត្ថភាពដ៏ពូកែទាំងការងារខាងក្នុងនិងខាងក្រៅផ្ទះផងដែរដែលមិនគួរមើលរំលង និងគួរតែទទួលបានឱកាសក្នុងការអភិវឌ្ឍឱ្យបានកាន់តែច្រើន។

### ២.៣.២ ឱកាសក្នុងការបញ្ចេញសក្តានុពលពីខាងក្នុង

សក្តានុពលត្រូវបានកំណត់ថាជាសមត្ថភាពឬជាទេពកោសល្យពីធម្មជាតិរបស់បុគ្គល ប្រើប្រាស់ដើម្បីរុញច្រានខ្លួនឱ្យសម្រេចបានសមិទ្ធិផល។ ហើយការអភិវឌ្ឍជាវិធីសាស្ត្រមួយដែលអាចធ្វើឱ្យបុគ្គលអាចស្វែងរកទេពកោសល្យនោះឃើញនិងអាចយកវាទៅប្រើប្រាស់ជាប្រយោជន៍បម្រើដល់ការរស់នៅប្រចាំថ្ងៃ។ មិនខុសគ្នាពីនេះ ស្ត្រីក៏ត្រូវការការអភិវឌ្ឍ ការបណ្តុះបណ្តាលបន្ថែមលើផ្នែកចំណេះដឹង និងសមភាពក្នុងការទទួលបានទាំងឱកាសសង្គមនិងសេដ្ឋកិច្ច ដើម្បីអាចដុសខាត់ទេពកោសល្យពីធម្មជាតិរបស់ខ្លួនឱ្យកាន់តែលេចធ្លោ និងមុតស្រួចថែមមួយកម្រិតទៀត ដើម្បីក្លាយខ្លួនជាផ្នែកមួយចូលរួមទៅក្នុងការពង្រឹងវឌ្ឍនភាពរបស់ប្រទេសជាតិ។

សក្តានុពលរបស់ស្ត្រី មានភាពទូលំទូលាយណាស់ ស្ត្រីអាចធ្វើកិច្ចការជាច្រើនផ្នែក ប្រកបដោយទំនួលខុសត្រូវ ការប្តេជ្ញាចិត្ត សុភវិនិច្ឆ័យ និងឆន្ទៈខ្ពស់។ ស្ត្រីអាចបំពេញកិច្ចការនៅក្នុងផ្នែកវិស័យសាធារណៈ ធុរកិច្ចវិស័យឯកជន និងការងារជាច្រើនទៀតក្នុងពេលតែមួយជាមួយនឹងការបំពេញតួនាទីគោលជាម្តាយ បានដោយភាពប្រាកដប្រជាផងដែរ។ មិនតែប៉ុណ្ណោះស្ត្រីខ្លះក៏មានទេពកោសល្យក្នុងការទំនាក់ទំនងបានយ៉ាងស្ទាត់ជំនាញជាមួយសង្គមខាងក្រៅ និងអាចបង្កើតផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ចបានតាមរយៈការចរចានោះ ជាមួយនឹងវិនិយោគិនទាំងក្នុងនិងក្រៅប្រទេសបានថែមទៀតផង។ តួយ៉ាងដូច លោកស្រី **វ៉េង សេរីវឌ្ឍនា** ជាម្ចាស់អាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិចម្នាក់ ដែលធ្លាប់ជួបចរចាទាក់ទាញវិនិយោគិនជនជាតិជប៉ុនជាច្រើននាក់ ទាក់ទងនឹងការធ្វើធុរកិច្ចផ្នែកគ្រឿងសំអាងឱ្យមកបោះទុនបង្កើតអាជីវកម្មនៅក្នុងប្រទេសកម្ពុជាបានដោយជោគជ័យ និងស្របតាមដំណើរការនីតិវិធីអាជីវកម្មផងដែរ។ ស្របពេលជាមួយគ្នានោះ លោកស្រីក៏បានដើរតួនាទីជាមន្ត្រីរាជការសាធារណៈនៃក្រសួងមហាផ្ទៃ និងជាអ្នកម្តាយរបស់កូនតូចៗ ២នាក់ផងដែរ។ តាមរយៈឧទាហរណ៍នេះ យើង

អាចដឹងបានថា កាលណាស្ត្រីរស់នៅក្នុងបរិបទមួយដែលជឿនលឿន ទទួលបានការអភិវឌ្ឍច្រើន និងមានចំណេះដឹងជ្រៅជ្រះ នោះស្ត្រីនឹងមានលទ្ធភាពកាន់តែច្រើនក្នុងការពង្រឹងនិងពង្រីកសមត្ថភាពខ្លួនបានកាន់តែខ្លាំង និងមានផលិតភាពការងារកាន់តែខ្ពស់។

### ២.៣.៣ ស្ត្រី និងភាពជាអ្នកដឹកនាំ

ភាពជាអ្នកដឹកនាំ គឺជាសិល្បៈនៃការជម្រុញក្រុមមនុស្សមួយក្រុម ដើរឆ្ពោះទៅរកការសម្រេចគោលដៅរួមមួយ ដោយមិនប្រកាន់នូវភេទ ពណ៌សម្បុរ ឬពូជសាសន៍ឡើយ។ ស្ត្រី ជាផ្នែកមួយសំខាន់ណាស់ក្នុងភាពជាអ្នកដឹកនាំ ពីព្រោះស្ត្រីមានសមត្ថភាពពិសេសម្យ៉ាងក្នុងការនិយាយបញ្ចុះបញ្ចូល បន្ទន់ចិត្ត និងបង្រួបបង្រួមមនុស្សឱ្យធ្វើការជាមួយគ្នាដោយភាពសោមនស្ស និងដឹកនាំពួកគេឱ្យធ្វើការជាក្រុមបានយ៉ាងមានប្រសិទ្ធភាពផងដែរ។

មិនតែប៉ុណ្ណោះ សម្រាប់ការចូលរួមអភិវឌ្ឍន៍សង្គមនិងប្រទេសជាតិ ស្ត្រីដើរតួនាទីជាអ្នកដឹកនាំក្នុងរូបភាពជាច្រើនបែប ដែលរួមមានទាំងការធ្វើជាអ្នកផ្តល់ជាកម្លាំងចិត្ត គំនិតយោបល់ និងការប្រឹក្សាដោះស្រាយបញ្ហាជាមួយនឹងមនុស្សក្នុងក្រុម និងដៃគូរសហការណ៍បានយ៉ាងមានប្រសិទ្ធភាពផងដែរ ជាពិសេសការធ្វើជាអ្នកផ្តល់យុទ្ធសាស្ត្រនៅពីខាងក្រោយខ្នងបុរស។

ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ជាផ្នែកសំខាន់មួយនៃការអភិវឌ្ឍសង្គម តាមវិធីនេះស្ត្រីនឹងទទួលបាននូវការថែទាំសុខភាព ការអប់រំ ការចិញ្ចឹមជីវិត និងការចូលរួមក្នុងសកម្មភាពសង្គមប្រសើរជាងមុន ហើយពួកគេអាចក្លាយជាធនធានមនុស្សពិតប្រាកដដែលបានរួមចំណែកក្នុងការអភិវឌ្ឍគ្រួសារ និងសង្គមជាតិរបស់ពួកគេ។ ម្យ៉ាងវិញទៀត ទោះបីជាលទ្ធភាពនៃការដឹកនាំមនុស្សនៅខាងក្រៅនៅមានកម្រិតក៏ដោយ ការផ្តល់អំណាចក្នុងការសម្រេចចិត្តទៅឱ្យស្ត្រី យ៉ាងហោចណាស់ពួកគេអាចមានសិទ្ធិសេរីភាពក្នុងការទទួលយកការអភិវឌ្ឍ ធ្វើជាជម្រើសសម្រាប់ដឹកនាំផ្លូវជីវិតខ្លួនឯងឱ្យប្រកបដោយលក្ខណៈល្អប្រសើរជាងមុនដែរ។

បើពិនិត្យទៅក្នុងសង្គមជាក់ស្តែងនៃប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាចំនួននៃថ្នាក់ដឹកនាំជាស្ត្រីមានការកើនឡើងក៏ពិតមែន តែចំនួននេះនៅតែតិចប្រសិនបើប្រៀបធៀបជាមួយនឹងថ្នាក់ដឹកនាំជាបុរស ដែលក្នុងចំណោមនោះមាន៖

- លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
- លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ
- លោកជំទាវ **ឱ វណ្ណឌីន** រដ្ឋលេខាធិការក្រសួងសុខាភិបាល
- លោកជំទាវ **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល

- លោកជំទាវ **មិថុនា ភូថង** អភិបាលនៃគណៈអភិបាលខេត្តកោះកុង។

ចំពោះការដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិ លោកជំទាវ **មិថុនា ភូថង** ជាអភិបាល នៃគណៈអភិបាលខេត្ត បានដឹកនាំខេត្តកោះកុងឱ្យមានការរីកចម្រើន និងបានចូលរួមយ៉ាងសកម្មក្នុងការធ្វើឲ្យខេត្តមានការអភិវឌ្ឍ កាន់តែល្អជាងមុន។ ដោយសារតែខេត្តកោះកុងជាខេត្តដែលទាក់ទាញដោយភ្ញៀវទេសចរណ៍ និងមានកន្លែងកម្សាន្តជាច្រើនកន្លែងទៀតផង។ សមិទ្ធិផលទាំងអស់នេះ ក៏ដោយសារតែមានការដឹកនាំដ៏ល្អក្រោមវត្តមានរបស់លោកជំទាវ និងការពុះពាររបស់លោក។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងតួនាទីជាអ្នកដឹកនាំស្ត្រីនៅតែជួបបញ្ហាប្រឈមដោយសារកត្តាមួយចំនួនដូចតទៅ៖

- **កត្តាវប្បធម៌ ប្រពៃណី និងផ្នត់គំនិត៖** ទោះបីជាឈានមកដល់សម័យកាលនេះហើយក៏ដោយ ក៏ស្ត្រីនៅតែជួបប្រទះបញ្ហានៃការរើសអើងពីសង្គមដោយផ្អែកទៅលើប្រពៃណីចាស់គំរិលដដែល ដែលផ្នត់គំនិតយេនឌ័រអវិជ្ជមាននេះបានរារាំងដល់ការចូលរួមរបស់ស្ត្រីទៅក្នុងការងារផ្នែកសង្គមនិងសេដ្ឋកិច្ចជាច្រើនបែប។ តួនាទីយេនឌ័របានបង្កើតជាឧបសគ្គ និងការរើសអើងលើស្ត្រីដែលជាលទ្ធផលធ្វើឱ្យកើតមាននូវវិសមភាពរវាងស្ត្រី និងបុរសក្នុងសង្គមកម្ពុជា។ លើសពីនេះទៅទៀត បញ្ហានេះបានចងជីវិតស្ត្រីជាមួយនឹងគំនាប ព្រមទាំងការរឹតត្បឹតស្ត្រីឱ្យប្រកាន់យកទំនួលខុសត្រូវជាចម្បងទៅលើការងារផ្ទះសម្បែង តួយ៉ាងដូចទស្សនៈមួយដែលលើកឡើងថា "ស្ត្រីមុជមិនជ្រៅទៅមិនឆ្ងាយ" ឬ "ស្ត្រីបង្វិលចង្ក្រានមិនជុំ" ជាដើម។ ទស្សនៈនេះ ជាការបន្ទាបតម្លៃនិងរើសអើងស្ត្រីមិនឱ្យចូលខ្លួនបម្រើការទៅក្នុងកិច្ចការអ្វីផ្សេងក្រៅពីការងារផ្ទះ ដែលធ្វើឱ្យសមត្ថភាពរបស់ស្ត្រីត្រូវបានកប់ចោលជាអសារបង់ទៅក្នុងភាពជាមេផ្ទះ។
- **កត្តាស្ថាប័ន៖** ទាក់ទងនឹងការកំណត់តួនាទីនិងមុខតំណែងរបស់ស្ត្រីនៅក្នុងបរិបទការងារខាងក្រៅផ្ទះ ដែលជាធម្មតាស្ត្រីទទួលបាននូវការរើសអើងមកលើសមត្ថភាពនិងទេពកោសល្យរបស់ខ្លួន។ ស្ត្រីភាគច្រើនត្រូវបានគេផ្តោតឲ្យចូលរួមធ្វើការងារក្នុងប្រពៃណី ហើយស្ថិតក្នុងតំណែងទាប។ នៅក្នុងផ្នែកឧស្សាហកម្ម ស្ត្រីនូវតែខ្វះខាតនូវឱកាសក្នុងការចូលរួមដំណើរការនៃការធ្វើសេចក្តីសម្រេចដដែល។

### ២.៣.៤ ការកែលម្អ ពង្រឹងនិងអភិវឌ្ឍន៍សមត្ថភាព

ការកែលំអរ និងអភិវឌ្ឍន៍សមត្ថភាពជារឿងចាំបាច់ណាស់សម្រាប់មនុស្សម្នាក់ៗ ដើម្បីឱ្យពួកគេបានដឹងបានស្គាល់ពីសក្តានុពល និងចំណុចខ្វះខាតរបស់ខ្លួន និងបានកែប្រែចំណុចខ្សោយនោះឱ្យមានភាពប្រសើរជាងមុន។

ក្នុងលក្ខខណ្ឌនេះ ការអភិវឌ្ឍស្ត្រីត្រូវបានទាមទារឱ្យមានសកម្មភាពជាចាំបាច់ ក្នុងគោលបំណងដើម្បីឱ្យស្ត្រីអាចមានឱកាសក្នុងការសិក្សាស្វែងយល់ពីខ្លួនឯង ទៅលើចំណុចខ្លាំង ចំណុចខ្សោយ ព្រមទាំងបទពិសោធន៍និង

កត្តាចិត្តសាស្ត្រផ្សេងៗទៀតដើម្បីឱ្យពួកគេអាចកែលំអរខ្លួនឯងឱ្យបានកាន់តែប្រសើរឡើងជាងមុន និងអាចទទួលបានចំណេះដឹងបន្ថែម ដើម្បីពង្រឹងសមត្ថភាពខ្លួន។

មិនតែប៉ុណ្ណោះ ការអភិវឌ្ឍជុសខាត់ជំនាញដែលមានស្រាប់ អាចធ្វើឱ្យស្ត្រីមានលទ្ធភាពក្នុងការគិតបានស៊ីជម្រៅទៅលើបញ្ហាដែលខ្លួនកំពុងប្រឈមមុខបានច្រើនជាងមុន អាចផលិតគំនិតច្នៃប្រឌិដ្ឋដើម្បីលើកស្ទួយការរស់នៅ និងអាចដកស្រង់យកទិន្នន័យខ្លះៗពីក្នុងសង្គមមកធ្វើការវិភាគព្យាករណ៍ ប្រមូលជាព័ត៌មានទុកសម្រាប់ប្រើប្រាស់ និងរៀបចំផែនការទៅថ្ងៃអនាគតបានយ៉ាងមានប្រសិទ្ធភាពទៀតផង។

ម្យ៉ាងវិញទៀតដើម្បីអាចធ្វើឱ្យដំណើរការនេះប្រព្រឹត្តទៅបាន ស្ត្រីមិនត្រូវរង់ចាំតែការផ្តល់ឱកាសពីសង្គមខាងក្រៅតែមួយផ្នែកនោះទេ ពោលគឺស្ត្រីត្រូវចេះមានភាពឈ្លាសវៃ ពិនិត្យមើល និងកែប្រែចំណុចខ្វះខាតដោយខ្លួនឯង តាមរយៈការចាប់ផ្តើមពីចំណុចមួយចំនួនដូចតទៅ៖

- **ឈប់ប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃ៖** ស្ត្រីត្រូវបានសង្គម ធ្វើការប្រៀបធៀបជាមួយអ្នកដទៃដែលវាបានក្លាយទៅជារឿងទូទៅ ឬជារឿងធម្មតាបាត់ទៅហើយ។ មិនតែប៉ុណ្ណោះ ស្ត្រីខ្លះក៏ចាប់ផ្តើមធ្វើការធៀបដំណើរជីវិតខ្លួនជាមួយនឹងស្ត្រីដទៃ ថាគេល្អជាងខ្លួនឬខ្លួនល្អជាងគេ តែបែជាមិនយកពេលប្រៀបធៀបនោះទៅធ្វើការខិតខំប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពខ្លួនទៅវិញ ដែលប្រការនេះធ្វើឱ្យស្ត្រីមួយចំនួនមានការអាក់អន់ស្រពន់ចិត្តទៅលើជោគវាសនារបស់ខ្លួន ហើយខ្លះទៀតក្លាយជាមនុស្សដែលមានអំនួតក្អេងក្អាងខុសពីសភាពដើមរបស់ខ្លួន។ តែផ្ទុយមកវិញ ប្រសិនបើស្ត្រីយកពេលវេលាក្នុងការប្រៀបធៀបនោះ ទៅជាការធ្វើសកម្មភាពយល់ដឹងបន្ថែមតាមរយៈការពិនិត្យមើលលើសកម្មភាព សមិទ្ធផលជាក់ស្តែង ស្វែងយល់ពីតម្លៃផ្ទាល់ខ្លួន និងទទួលយកភាពជាខ្លួនឯងហើយឈប់ប្រៀបធៀបខ្លួនទៅនឹងអ្នកដទៃ នោះស្ត្រីនឹងកាន់តែមានភាពរឹងមាំ និងមានជំនឿជាក់លើខ្លួនឯងវិញជាប្រាកដ។
- **កាត់បន្ថយការព្រួយបារម្ភពីទស្សនៈនិងការវាយតម្លៃរបស់សង្គម៖** ទស្សៈដដែលៗ និងផ្នត់គំនិតរបស់សង្គមតែងតែវាយប្រហារមកលើស្ត្រីថា ស្ត្រីធ្វើអ្វីមិនបានដូចបុរស ឬការងារនេះមិនសក្តិសមនឹងស្ត្រីទេ ឬកូនស្រីមិនគួររៀនជំនាញនេះទេ។ល។ គំនិតទាំងនេះបានដក់ជាប់នឹងដួងចិត្តរបស់ស្ត្រីទាំងអស់ ដែលធ្វើឱ្យពេលខ្លះពួកគេបាត់បង់ទំនុកចិត្ត សង្ស័យលើខ្លួនឯង ភ័យខ្លាចមិនហ៊ានចាប់ផ្តើមតាមក្តីសុបិន្តរបស់ខ្លួន ដោយសាតែការព្រួយបារម្ភតតបានការទៅនឹងការវាយតម្លៃពីមជ្ឈដ្ឋានខាងក្រៅដែលចាំតែទិតៀន រិះគន់ជាន់ពន្លិច នៅពេលដែលពួកគេធ្វើអ្វីមួយខុសពីការរំពឹងទុករបស់សង្គម ឬទទួលបានភាពបរាជ័យទៅលើសកម្មភាពដែលស្ត្រីកំពុងធ្វើជាដើម។ ម្យ៉ាងទៀត បញ្ហានេះក៏អាចកើតឡើងបានដោយសារមនុស្សខ្វះការអប់រំចេញពីក្នុងសង្គមគ្រួសារ អាក់សមត្ថភាព ទំនេរជ្រុល ខ្វះសីលធម៌ និងជា

ទម្លាប់មិនល្អជាប់ខ្លួន ព្រមទាំងមិនមានគំនិតក្នុងការស្ថាបនាខ្លួនឯងឱ្យបានល្អ ទើបជារឿយៗគេប្រទះឃើញសកម្មភាពនេះឧស្សាហ៍កើតមានចំពោះជនទូទៅ និងជាពិសេសគឺស្ត្រីតែម្តង។

- **អនុញ្ញាតឱ្យខ្លួនឯងបង្កើតឱ្យមានកំហុស៖** យើងតែងតែត្រូវបានគេប្រាប់ម្តងហើយម្តងទៀតពី វ័យក្មេងមកថា គ្មាននរណាម្នាក់ល្អឥតខ្ចោះនោះទេ មនុស្សអាចធ្វើខុសបានគ្រប់ពេល។ ទោះបីជាមានការលើកឡើងបែបនេះក៏ដោយ ក៏ស្ត្រី ឬយើងទាំងអស់គ្នាតែងតែមានការព្រួយបារម្ភភ័យខ្លាចក្នុងការធ្វើឱ្យមានកំហុសជាខ្លាំង ទោះបីជាពេលខ្លះយើងដឹងហើយថាកំហុសនោះមិនបានជះឥទ្ធិពលអវិជ្ជមានមកលើជីវិត ហើយផ្តល់ជាបទពិសោធន៍ល្អដល់យើងក៏ដោយ។ ប្រការនេះបណ្តាលមកពី នៅពេលណាដែលយើងធ្វើអ្វីមួយខុស យើងតែងតែទទួលបានការស្តីបន្ទោសនិងការសើចចម្អកពីមជ្ឈដ្ឋានខាងក្រៅ និងទទួលបានក្រសែរភ្នែកមនុស្សដែលមើលមកកាន់យើងថាជា មនុស្សបរាជ័យ ឬមនុស្សល្ងង់។ល។ ហើយជាពិសេសនៅពេលដែលអ្នកបង្កើតឱ្យមានកំហុសនោះជាស្ត្រីភេទ នោះសង្គមនឹងចាប់ផ្តើមវាយប្រហារដោយប្រើពាក្យសម្តីផ្សេងៗថា "ខ្លួនជាស្រីទេ តែរឹងចចេសណាស់" ឬ "ខ្លួនជាស្រីទេ មិនដឹងធ្វើអញ្ចឹងដើម្បីអី" ឬទទួលរងការរិះគន់ថាជាសកម្មភាពដើម្បីទាក់ទាញចំណាប់អារម្មណ៍ជាដើម។ តែតាមការពិតទៅ ការបង្កើតឱ្យមានកំហុសមិនមែនមានន័យថាជារឿងមិនល្អរហូតឡើយ ពីព្រោះការធ្វើឱ្យមានកំហុសអាចបង្ហាញថា យើងបានព្យាយាម បានសាកល្បង និងបានប្រើប្រាស់សមត្ថភាពរបស់យើងរួចហើយ ហើយក៏ល្អជាងមិនបានធ្វើសោះនោះដែរ។ ម្យ៉ាងវិញទៀត កំហុសក៏អាចដើរតួជាមេរៀន ដែលអាចឱ្យយើងបានដឹងពីចំណុចខ្វះខាតផ្ទាល់ខ្លួន ទទួលបានបទពិសោធន៍ និងអាចប្រើប្រាស់ដើម្បីបង្ការការបង្កើតឱ្យមានកំហុសនៅពេលក្រោយទៀតដែរ ដូច្នេះស្ត្រីមិនគួរភ័យខ្លាចនឹងការបង្កើតឱ្យមានកំហុសឡើយ។
- **កសាងទំនុកចិត្តផ្ទាល់ខ្លួន៖** ការកសាងទំនុកចិត្តផ្ទាល់ខ្លួនជារឿងសំខាន់បំផុតសម្រាប់មនុស្ស ពីព្រោះទំនុកចិត្តជាកត្តាម្យ៉ាងដែលជួយរុញច្រានមនុស្សឱ្យឆាប់បានទៅដល់គោលដៅ ឬមានភាពក្លាហានក្នុងការធ្វើសកម្មភាពអ្វីមួយក្នុងការបង្កើតបានជាប្រយោជន៍។ ដូចគ្នានេះដែរ ចំពោះស្ត្រី ទំនុកចិត្តក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យស្ត្រីមានភាពរឹងប៉ឹង ហ៊ានប្រឈមមុខនឹងបញ្ហា ហ៊ានសាកល្បងនឹងអ្វីៗដែលថ្មីៗ ព្រមទាំងអាចមានលទ្ធភាពខ្ពស់ក្នុងការឈានទៅដល់ចំណុចកំពូលនៃជីវិតរស់នៅ និងអាចបង្ហាញភាពម្ចាស់ការ និងភាពជាខ្លួនឯងបានផងដែរ។ ប្រការនេះ ក៏អាចធ្វើឱ្យស្ត្រីសម្រេចនូវសមិទ្ធិផលធំៗ និងធ្វើឱ្យសម្លេងរបស់ស្ត្រីអាចបន្លឺឡើងទៅដល់កន្លែងឆ្ងាយៗបានថែមទៀតផង។
- **ចាត់ទុកខ្លួនឯងជាអាទិភាព៖** ចំណុចនេះមានន័យថា ស្ត្រីគួរចេះផ្តល់ជម្រើសដល់ខ្លួនឯងមុនអ្នកណាទាំងអស់ ជាពិសេសស្ត្រីត្រូវចេះដឹងពីរបៀបក្នុងការផ្តល់ក្តីស្រឡាញ់និងការគោរពចំពោះខ្លួនឯងឱ្យបាន

ច្រើន មុននឹងចែករំលែកទៅឱ្យអ្នកដទៃ ពីព្រោះមានតែមនុស្សដែលចេះយកចិត្តទុកដាក់មើលថែទាំខ្លួនឯងបានល្អគ្រប់គ្រាន់ប៉ុណ្ណោះ ទើបចេះផ្ទេរអារម្មណ៍នោះទៅឱ្យអ្នកដទៃបាន។ ប៉ុន្តែ នៅក្នុងន័យនេះមិនមែនមានន័យថា ស្ត្រីត្រូវប្រកាន់យកឥរិយាបថអាត្មានិយមនោះទេ ពោលគឺស្ត្រីត្រូវចេះយល់ដឹងពីរបៀបក្នុងការធ្វើឱ្យខ្លួនឯងក្លាយជាមនុស្សមានតម្លៃ មានទិដ្ឋិត្រឹមត្រូវ និងមានការតាំងចិត្តជាឧបេក្ខា មិនតំកើងខ្លួនខ្លាំងពេក ហើយក៏មិនបន្ទាបខ្លួនជ្រុលពេកដែរ គឺធ្វើយ៉ាងណាឱ្យសមល្មមក្នុងនាមជាមនុស្ស និងជាមាតាពិភពលោក។ មិនតែប៉ុណ្ណោះ ស្ត្រីក៏ត្រូវចេះស្វែងយល់ពីរបៀបក្នុងការបដិសេដសំណើរក្នុងកាលៈទេសៈមិនសមរម្យ ឬធ្វើឱ្យខ្លួនឯងមិនមានភាពស្រណុកចិត្ត ដោយមិនបង្ករឱ្យមានទំនាស់ និងត្រូវចេះស្វែងយល់ពីរបៀបក្នុងការដាក់កម្រិតកំនត់ស្តង់ដារបស់ខ្លួន និងត្រូវចេះបង្កើតជម្រើសសម្រាប់ខ្លួនឯងកុំឱ្យទោរទន់ទៅតាមការយល់ឃើញរបស់អ្នកដទៃ។ ស្ត្រីអាចបង្កើតឱ្យមានលក្ខណៈទាំងអស់នេះសម្រាប់ខ្លួនឯងបានតាមរយៈការស្វែងរកចំណេះដឹងថ្មីៗ ការប្រាស្រ័យទាក់ទងជាមួយមនុស្សវិជ្ជមាន ការរៀនសូត្រពីក្រមសីលធម៌សង្គម ផ្តល់ពេលវេលាខ្លះសម្រាប់ខ្លួនឯងក្នុងការវិភាគមើលពីស្ថានភាពខាងក្នុងចិត្ត និងការកំណត់ទស្សនវិស័យឱ្យបានឆ្ងាយ ព្រមទាំងការធ្វើឱ្យមានតុល្យភាពរវាងជីវិតផ្ទាល់ខ្លួន ជីវិតគ្រួសារ និងការរស់នៅក្នុងសង្គម។

### ២.៣.៥ កាត់បន្ថយគំលាតស្តង់ដារនៃការរស់នៅ

ការកាត់បន្ថយគម្លាតស្តង់ដាជាការធ្វើយ៉ាងណាឱ្យវិសមភាពនៃកម្រិតជីវភាពរស់នៅរវាងទីក្រុងនិងតំបន់ជនបទមានការកាត់បន្ថយ និងធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ទាំងពីរមានលក្ខណៈប្រហាក់ប្រហែលគ្នា។ កាលណាគម្លាតនៃជីវភាពរស់នៅមានទំហំធំពេក នោះអ្នកដែលរស់នៅតំបន់ជនបទ ច្រើនជួបប្រទះនូវភាពលំបាកផ្សេងៗដែលរួមមាន ការបាត់បង់ឱកាសក្នុងការទទួលបានសេវាសាធារណៈ ការបែងចែកប្រាក់ចំណូលពុំស្មើគ្នា ឱកាសក្នុងការទទួលបានការសិក្សាទាប និងមានជីវភាពមិនសូវធូរធារ ងាយប្រឈមនឹងការធ្វើចំណាកស្រុកនិងពិបាកក្នុងការកែប្រែផ្នត់គំនិតផងដែរ។

ការកាត់បន្ថយវិសមភាពនៃការរស់នៅ គឺជាជំហានសំខាន់បំផុតដែលត្រូវដោះស្រាយដើម្បីបង្កើននូវសុខុមាលភាពរបស់ប្រជាជន ជាពិសេសការកាត់បន្ថយវិសមភាពជាកត្តាម្យ៉ាងដែលអាចជួយបើកផ្លូវឱ្យស្ត្រីដែលរស់នៅតំបន់ជនបទមានឱកាសក្នុងការទទួលបានសិទ្ធិសេរីភាពក្នុងការរស់នៅ ការស្គាល់ពីពិភពខាងក្រៅ អាចរៀនសូត្របានទូលោះទូលាយនិងមានលទ្ធភាពក្នុងការអភិវឌ្ឍខ្លួនឱ្យទទួលបាននូវភាពល្អប្រសើរ និងអាចជួយចូលរួមក្នុងការកែប្រែមុខមាត់គ្រួសារ សហគមន៍ និងប្រទេសជាតិឱ្យមានភាពរុងរឿង។

## ២.៤ មធ្យោបាយក្នុងការអភិវឌ្ឍស្ត្រីនៅជនបទ

### ២.៤.១ ការអប់រំបណ្តុះបណ្តាល និងវិជ្ជាជីវៈ

#### ២.៤.១.១ ការអប់រំ បណ្តុះបណ្តាល

ការអប់រំជាមធ្យោបាយដ៏មានឥទ្ធិពលបំផុតក្នុងការកែប្រែជីវិតមនុស្ស ក៏ដូចជាសង្គមជាតិឱ្យមានភាពរីកចម្រើន។ ការផ្តល់នូវចំណេះដឹងអាចធ្វើឱ្យមនុស្សមានប្រាជ្ញា មានស្មារតី ចេះស្គាល់ល្អអាក្រក់ និងចេះយល់ពីរបៀបក្នុងប្រកាន់យកឥរិយាបថចប្រពៃ ព្រមទាំងអាចផ្លាស់ប្តូរវាសនាមនុស្សឱ្យក្លាយជាមនុស្សថ្មីមានភាពប្រសើរឡើងជាងមុនបានផងដែរ។

ការអប់រំ ត្រូវបានទទួលយកជាសកលថាជាមូលដ្ឋានសិទ្ធិមនុស្សមួយដ៏សំខាន់។ ការអប់រំក៏ជាកត្តាកាត់បន្ថយភាពក្រីក្រផងដែរ តាមរយៈបទពិសោធន៍ដែលទទួលបានពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០១-២០០៥ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ មួយទៀត ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ហើយផែនការនេះបានបញ្ចូលនូវគោលដៅទាំងឡាយនៃផែនការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ២០០៣-២០១៥។ ផែនការនេះ គឺជាក្របខ័ណ្ឌគោលនយោបាយ និងការអនុវត្តដ៏សំខាន់មួយ សម្រាប់ការកែលម្អស្ថានភាពរស់នៅរបស់អ្នកក្រដោយប្រើប្រាស់ការអប់រំជាកត្តាសំខាន់ក្នុងការលើកកម្ពស់ការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ច។ ការផ្តោតយកចិត្តទុកដាក់ ត្រូវបានធ្វើឡើងនៅក្នុងការកែលម្អគុណភាពអប់រំនៅគ្រប់កម្រិតទាំងនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។

បង្អែករឹងមាំរបស់ប្រទេសជាតិមួយ គឺជាសំណុំសំខាន់នៃធនធានមនុស្សដែលមានការអប់រំមានជំនាញមានទេពកោសល្យ និងមានសមត្ថភាពក្នុងវិស័យនានា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០ និងគោលនយោបាយសំខាន់ៗ ការងារដែលត្រូវធ្វើជាអាទិមាន៖

- ការធានាឲ្យមានលទ្ធភាពចូលរៀនប្រកបដោយភាពងាយស្រួលនិងសមធម៌ ជាពិសេសសម្រាប់អ្នកក្រក្មេងស្រី ជនជាតិភាគតិច និងកុមារក្រីក្រ ក៏ដូចជាប្រជាជនរស់នៅក្នុងតំបន់ដែលមានអត្រាភាពក្រីក្រខ្ពស់
- សកលកម្មនៃការអប់រំជាមូលដ្ឋាន ៩ឆ្នាំ និងលើកកម្ពស់កាលានុវត្តភាពជីវិតរស់នៅ
- ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំដោយរាប់បញ្ចូលទាំងតាមរយៈការធ្វើទំនើបកម្ម និងកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព

- ការផ្សារភ្ជាប់ការអប់រំ និងការបណ្តុះបណ្តាលទៅនឹងទីផ្សារពលកម្មរយៈពេលវែង និងមធ្យមទៅនឹងសង្គមដោយរួមបញ្ចូលទាំងការអប់រំឲ្យមានជំនាញ សម្រាប់ការរស់នៅទៅនឹងសុខភាពល្អ និងការអប់រំពីការការពារមេរោគហ៊ីវ ឬជម្ងឺអេដស៍
- ការអភិវឌ្ឍបន្ថែមទៀតក្នុងវិស័យយុវជន និងកីឡាដោយបង្កើនការយកចិត្តទុកដាក់ចំពោះយុវជនក្នុងគ្រប់ជំនាញ
- ការបន្ថែម និងការកសាងសមត្ថភាពស្ថាប័នសំខាន់ៗសម្រាប់ការងាររិមជ្ឈការ។

ក្នុងពេលថ្មីៗនេះ វឌ្ឍនភាពសំខាន់ៗមួយចំនួនត្រូវបានធ្វើឲ្យសម្រេចឡើង ក្នុងការបង្កើនកម្រិតចុះឈ្មោះចូលរៀន នៅសាលាបឋមសិក្សានិងមធ្យមសិក្សា(បញ្ចប់ការសិក្សាជាមូលដ្ឋាន៩ឆ្នាំ)ប៉ុន្តែទោះបីជាដូចនេះក្តីភាពឃ្លាតឆ្ងាយពីគ្នាចំពោះអ្នកក្រ និងនៅតំបន់ដាច់ស្រយាលនៅតែមាននៅឡើយ។ ដូចនេះគោលដៅសំខាន់ៗចំពោះមុខរបស់វិស័យអប់រំរួមមាន៖

- កាត់បន្ថយចម្ងាយផ្លូវ ដែលកុមារធ្វើដំណើរពីផ្ទះមកកាន់សាលា តាមរយៈការកសាង និងបើកសាលារៀននៅជិតភូមិ ជាពិសេសនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក
- បង្ករលក្ខណៈងាយស្រួល ដើម្បីឲ្យកុមារីបានចូលរៀននៅសាលាមធ្យមសិក្សា បឋមភូមិនិងកម្រិតសិក្សាខ្ពស់ជាងនេះ
- កាត់បន្ថយការចំណាយ របស់ឪពុកម្តាយសិស្សក្នុងការចុះឈ្មោះចូលរៀន និងធានាឲ្យមានការចូលរៀន និងការសិក្សារបស់កុមារក្រីក្រ ហើយតាមរយៈនេះនឹងធានាឲ្យមានការកាត់បន្ថយកម្លាំងពលកម្មកុមារផងដែរ
- បង្កើនគុណភាពអប់រំ និងក្រោយកម្រិតអប់រំជាមូលដ្ឋានរាប់បញ្ចូលទាំងការសម្រួលកម្មវិធីសិក្សា និងការដាក់បញ្ចូលស្តង់ដារអប្បបរមានៃលទ្ធផលនៃការសិក្សារបស់សិស្ស និងប្រព័ន្ធវាយតម្លៃនៃការសិក្សារបស់សិស្សសម្រាប់ថ្នាក់ទី៣ ថ្នាក់ទី៦ និងថ្នាក់ទី៩។

**២.៤.១.២ ការបណ្តុះបណ្តាលវិជ្ជាជីវៈ**

ការទទួលបានការអប់រំ និងការបណ្តុះបណ្តាលឱ្យស្ត្រីនៅតាមជនបទមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសក្តានុពលរបស់ពួកគេ ហើយនិងទទួលបានអត្ថប្រយោជន៍ពីឱកាសបង្កើតប្រាក់ចំណូល និងលើកកម្ពស់សុខុមាលភាពទូទៅរបស់ពួកគេ។ បញ្ហាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាបញ្ហាស្នូល ដែលរដ្ឋាភិបាលកំពុងខិតខំដោះស្រាយដើម្បីការរស់នៅដោយសុខដុមរមនារបស់ប្រជាពលរដ្ឋ។ ក្រសួងអភិវឌ្ឍជនបទ បានយកចិត្តទុកដាក់ និងកំណត់អាទិភាពមួយក្នុងចំណោមអាទិភាពទាំងបួនរបស់ក្រសួង។ ការបង្កើនល្បឿនផលិតកម្មសេដ្ឋកិច្ចជនបទ និងសហគ្រិនភាព គឺដើម្បីគាំទ្រដល់ការបង្កើនប្រាក់ចំណូលតាមគ្រួសារនៅជនបទឲ្យមាន

ជីវភាពប្រសើរឡើង ដែលចូលរួមដល់កម្មវិធីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាមតំបន់ជនបទ។ ក្នុងន័យនេះ ក្រសួងនឹងជំរុញការផ្តល់ចំណេះដឹង ចំណេះជំនាញ បង្កើតការងារ ផ្តល់ឥណទានសមស្រប រកទីផ្សារ និងបង្កើតបរិយាកាសធុរកិច្ច ដល់ប្រជាជនប្រកបដោយបរិយាប័ន្ន ដើម្បីធានាបង្កើនស្ថិរភាពប្រាក់ចំណូលតាមគ្រួសារនីមួយៗ។

សកម្មភាពទាំងអស់រួមមានៈ

- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ ចំនេះជំនាញមូលដ្ឋានចល័តនៅតាមសហគមន៍ជនបទឱ្យបានច្រើន
- ជំរុញប្រជាជនឱ្យចូលរួមទទួលការបណ្តុះបណ្តាលចំណេះជំនាញមូលដ្ឋាន
- ជំរុញឱ្យប្រជាជនក្នុងសហគមន៍ ចូលរួមកម្មវិធីបង្កើតអាជីវកម្មខ្នាតតូច និងខ្នាតគ្រួសារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលមុខវិជ្ជាទៅតាមតម្រូវការនៅតាមតំបន់នីមួយៗ
- ផ្តល់ជំនាញដល់ជនជាតិដើមភាគតិចក្នុងសហគមន៍ដែលពួកគេរស់នៅ
- ជំរុញបង្កើតទីផ្សារសហគមន៍ជនបទ តាំងបង្ហាញផលិតផល
- ជួសជុល និងសាងសង់ផ្សារជនបទដើម្បីដោះដូរផលិតកម្មក្នុងស្រុក
- បណ្តុះបណ្តាលស្ត្រីមេផ្ទះ ក្នុងការថែរក្សាទុក និងការកែច្នៃម្ហូប អាហារ និងរៀបចំសួនដំណាំរបស់គ្រួសារសម្រាប់បំពេញតម្រូវការ និងការបង្កើនប្រាក់ចំណូល
- ជំរុញការផ្តល់សេវាប្រាក់កម្ចីដែលមានអត្រាការប្រាក់សមរម្យ សម្រាប់ការអភិវឌ្ឍសិប្បកម្ម មុខជំនាញសហគ្រាសខ្នាតតូច និងមធ្យមជាមួយនឹងការផ្តល់បច្ចេកទេស ជំនាញ និងការយល់ដឹងពីការបង្កើតមុខរបរព្រមទាំងការខិតខំ ពង្រីកទីផ្សារ ដើម្បីដំណើរការផលិតផលនៅតំបន់ជនបទ
- បន្តគាំទ្រដល់ការបង្កើតធនាគារ មិនមែនសាច់ប្រាក់ដូចជា ធនាគារស្រូវ ធនាគារមាន់ ធនាគារជីជាដើម
- បង្កើតឲ្យមានក្រុមសន្សំ និងប្រើប្រាស់ថវិការឲ្យបានត្រឹមត្រូវ និងចំគោលដៅ។

ស្ត្រីចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍនយោបាយ សេដ្ឋកិច្ច និងសង្គម។ ការរួមចំណែកនេះគឺជាការចូលរួមយ៉ាងសំខាន់សម្រាប់សុខុមាលភាពគ្រួសារ និងសហគមន៍ ជាពិសេសក្នុងការអភិវឌ្ឍប្រទេសជាតិទាំងមូល។ មនុស្សភាគច្រើនដែលមានគំនិតសុទិដ្ឋិនិយមអំពីការកើនឡើងនូវការចូលរួមរបស់ស្ត្រី ព្រោះគេបានគិតថាមានស្ត្រីក្នុងវិស័យនយោបាយ កាន់តែនាំមកនូវការអភិវឌ្ឍក្នុងសហគមន៍ គេយល់ថាអ្នកដឹកនាំជាស្ត្រីមានការប្តេជ្ញាចិត្តខ្ពស់ និងចូលរួមសកម្មជាងបុរស។

- **ការចូលរួមក្នុងកម្លាំងពលកម្ម**

ចំនុចនេះបង្ហាញពីអត្រាចូលរួមនៅក្នុងកម្លាំងពលកម្មភាគរយនៃកម្លាំងពលកម្មទៅតាមក្រុម អាយុតាមតំបន់ ស្ថានភាពការងារ និងការចូលរួមចំណែករបស់ស្ត្រីក្នុងការរកប្រាក់កម្រៃ។

- អត្រាចូលរួមក្នុងកម្លាំងពលកម្មតាមតំបន់អាយុ ១៥-៦៤ឆ្នាំ នៅឆ្នាំ ២០១២ និង ឆ្នាំ២០១៥

| ការស្នាក់នៅ | ២០១២ | | ២០១៥ | |
|---|---|---|---|---|
| | ស្រី | ប្រុស | ស្រី | ប្រុស |
| កម្ពុជា | ៨០ | ៨៩ | ៧៧ | ៨៩ |
| ភ្នំពេញ | ៧២ | ៨២ | ៧១ | ៨៦ |
| ទីប្រជុំជន | ៧៥ | ៨៥ | ៧២ | ៨៤ |
| ទីជនបទ | ៨២ | ៩១ | ៧៩ | ៩០ |
| ចំនួនសរុប | ៣,៧៨៨,៨០០ | ៣,៩២៨,៩០០ | ៤,៣២៤,២០០ | ៤,០៣៥,៣០០ |

ប្រភព៖ ការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៤។

- កម្លាំងពលកម្មអាយុ ១៥-៦៤ឆ្នាំ តាមតំបន់ គិតជាភាគរយ

| កម្លាំងពលកម្ម | កម្ពុជា | ភ្នំពេញ | ទីប្រជុំជន | ទីជនបទ | ចំនួនសរុប |
|---|---|---|---|---|---|
| អត្រាមានការងារធ្វើ | | | | | |
| ស្រី | ៧៧ | ៧១ | ៧២ | ៧៩ | ៤,៣២២,៧០០ |
| ប្រុស | ៨៩ | ៨៦ | ៨៤ | ៩០ | ៤,០២៩,៧០០ |
| អត្រាគ្មានការងារធ្វើ | | | | | |
| ស្រី | | | | | ១,៥០០ |
| ប្រុស | 0.0 | 0.២ | 0.0 | 0.0 | ៥,៧០០ |

ប្រភព៖ ការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៤។

- ការរួមចំណែកក្នុងការរកប្រាក់កម្រៃរបស់ស្ត្រី ចំនួនប្រជាជនមានការងារធ្វើ អាយុ១៥-៦៤ឆ្នាំតាមតំបន់ភូមិសាស្ត្រ និងវិស័យឧស្សាហកម្មឆ្នាំ២០១៥ គិតជាភាគរយ

| ការរួមចំណែកក្នុងការរកប្រាក់កម្រៃរបស់ស្ត្រី | កម្ពុជា | ភ្នំពេញ | ទីប្រជុំជន | ទីជនបទ |
|---|---|---|---|---|
| កសិកម្ម | ៤៦ | * | ៥៦ | ៤៩ |
| ឧស្សាហកម្ម | ៤៦ | ៥៣ | ៣៨ | ៤៦ |

| | | | | |
|---|---|---|---|---|
| សេវាកម្ម | ៣៦ | ៣៧ | ៤០ | ៣៤ |
| សរុប | ៤៣ | ៤៣ | ៤០ | ៤៣ |
| ចំនួនសរុប | ២,៣៥៣,១០០ | ២,៨៩,៥០០ | ២៤១,០០០ | ១,៨២២,៦០០ |

ទិន្នន័យកសិកម្មនៅក្នុងទីក្រុងភ្នំពេញមិនអាចស្វែងរកបាន ប្រភព៖ ការសង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ២០១៥។

### ២.៤.២. ការអភិវឌ្ឍលើវិស័យកសិកម្ម

វិស័យកសិកម្ម ជាវិស័យមួយដែលនាំមុខមួយក្នុងចំណោមវិស័យដទៃទៀតដែលបានរួមវិភាគទានដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ហើយក៏បានចូលរួមចំណែកក្នុងកំណើនផលទុនជាតិ និងចំណូលពីការនាំចេញផលិតផលកសិកម្ម។ វិស័យនេះក៏បានជួយផ្តល់ការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទដែលមានជីវភាពពឹងអាស្រ័យលើការងារកសិកម្មផងដែរ។

ក្រសួងក៏បានទទួលស្គាល់ថា ប្រព័ន្ធកសិកម្មនៅកម្ពុជាភាគច្រើនជាកសិកម្មដែលផ្គត់ផ្គង់ក្នុងក្រុមគ្រួសារខ្លួនឯង ហើយនៅមានកង្វះខាតនូវទំនាក់ទំនងជាមួយនឹងការយល់ដឹងពីទីផ្សារ និងការធ្វើកសិ-ពាណិជ្ជកម្ម។ ដូចនេះ ក្រសួងក៏បានដាក់ឲ្យប្រើប្រាស់នូវឯកសារ " គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា " ដើម្បីឲ្យកសិកម្មទទួលបាន និងប្រើប្រាស់ចំណេះដឹងព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើរ។

សកម្មភាពទាំងនោះរួមមាន៖

- លើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម និងអភិវឌ្ឍសហគមន៍កសិកម្ម
- ពង្រឹង និងជម្រុញការងារផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ពិសេសការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យាសំដៅបង្កើនចំនួនអ្នកប្រើប្រាស់ កសិករ សហគមន៍កសិកម្ម ឲ្យទទួលបានឯកសារបច្ចេកទេសវិទ្យាសាស្ត្រថ្មីៗស្របតាមការរីកចម្រើននៃវិស័យកសិកម្ម
- ជំរុញការអភិវឌ្ឍសហគមន៍ ដើម្បីធ្វើឲ្យសហគមន៍ជាកន្លែងផលិតទ្រង់ទ្រាយធំដោយភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលជាគន្លឹះក្នុងការដោះស្រាយទីផ្សារកសិផល
- ពង្រឹងការគ្រប់គ្រងអង្គភាពឲ្យបានរឹងមាំ បង្កើនការផ្តល់សេវាគាំទ្រនានា និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្មឲ្យកាន់តែមានប្រសិទ្ធភាព
- ផ្តល់បច្ចេកទេសកសិកម្មទំនើបដល់និស្សិតសម្រាប់ការពង្រីកកសិ-ធុរកិច្ច ព្រមទាំងរៀបចំរចនាសម្ព័ន្ធសម្រាប់ការគាំទ្រការងារកសិកម្ម។

នៅក្នុងវិស័យកសិកម្ម ត្រូវបានផ្តោតទៅលើផលិតកម្មដំនាំប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផល និងចំណូលតាមជនបទ ការធ្វើពិពិធកម្មដំណាំ ការកែលម្អការគ្រប់គ្រងជលផល ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព

តាមរយៈកំណែទម្រង់ ការអភិរក្សបរិស្ថាន និងការអនុវត្តកំណែទម្រង់ដីធ្លី ជាពិសេសដើម្បីធានាសិទ្ធិកាន់កាប់ដីធ្លីរបស់អ្នកក្រ។ ក្នុងចំណោមយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗជាច្រើន រួមមាន៖

- បង្កើនការវិនិយោគសាធារណៈក្នុងវិស័យកសិកម្ម
- លើកកម្ពស់លទ្ធភាពទទួលបានមីក្រូហិរញ្ញវត្ថុគ្រប់គ្រាន់
- លើកទឹកចិត្តនិងសម្របសម្រួលការវិនិយោគរបស់ផ្នែកឯកជនក្នុងវិស័យកសិកម្ម និងការកែច្នៃកសិផល
- លើកកម្ពស់សន្តិសុខស្បៀង និងអាហាររូបត្ថម្ភ
- សម្របសម្រួលការបង្កើនទិន្នផលតាមរយៈការពង្រីកសេវាផ្សព្វផ្សាយ
- អនុវត្តន៍ការធ្វើអន្តរាគមន៍ដែលត្រូវធ្វើការកែប្រែដើម្បីកាត់បន្ថយភាពក្រីក្រ
- ធានាលទ្ធភាពទទួលបានប្រកបដោយចីរភាពសម្រាប់អ្នកក្រពីវិស័យជលផល
- ពង្រីក នឹងពង្រឹងផលិតកម្មបសុសត្វ
- គ្រប់គ្រងបានប្រសើរនៅតំបន់ដែលត្រូវបានការពារ។

ដើម្បីជម្រុញការអភិវឌ្ឍជនបទបន្ថែមទៀត ត្រូវស្របជាមួយនឹងវិមជ្ឈការ និងវិសហមជ្ឈការ ការផ្តោតការយកចិត្តទុកដាក់នឹងត្រូវបានគេធ្វើឡើងលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវ ទីផ្សារ មធ្យោបាយផ្តល់ទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ។ល។)

### ២.៤.៣ ការអភិវឌ្ឍលើវិស័យឧស្សាហកម្ម

វិស័យដែលមានសក្តានុពលបំផុតនោះគឺ វិស័យឧស្សាហកម្មដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកជួយស្តារ កសាងនិងអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យរីកចម្រើន និងបូករួមទាំងការចូលវិនិយោគនៅលើគ្រប់ផ្នែកទាំងអស់ គឺទាំងការវិនិយោគផលិតផលទំនិញនាំចេញ ការផលិតថាមពល ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគផ្នែកទេសចរណ៍ ក៏ដូចជាការជម្រុញការអភិវឌ្ឍ និងជម្រុញកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាឱ្យមានសន្ទុះលឿនថែមមួយកម្រិតទៀត។

ដោយសារវិស័យឧស្សាហកម្មធ្វើឱ្យមានភាពរីកចម្រើនបែបនេះហើយ ទើបយើងត្រូវធ្វើឱ្យមានការអភិវឌ្ឍប្រជាជននៅតំបន់ជនបទឲ្យពួកគាត់យល់ដឹងកាន់តែច្រើន និងបន្ថែមលើវិស័យនេះដើម្បីឱ្យជួយឲ្យតំបន់ដែលពួកគាត់រស់នៅមានការអភិវឌ្ឍផងដែរ។

ដូចនេះ ដើម្បីធ្វើការអភិវឌ្ឍតំបន់ជនបទតាមរយៈវិស័យឧស្សាហកម្មនេះ យើងត្រូវ៖

- ធ្វើការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស

- បង្កើនឱកាសទីពីរ សម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា តាមរយៈប្រព័ន្ធសមមូលសញ្ញាបត្រ ដោយផ្អែកលើការធ្វើតេស្តដែលអនុញ្ញាតិឱ្យទទួលបានវិញ្ញាបនបត្រចំណេះទូទៅ គ្រប់កម្រិតទោះនៅក្រៅប្រព័ន្ធក៏ដោយ
- ពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាដោយផ្តោតលើការពង្រឹងមូលដ្ឋានចំណេះដឹងរបស់កុមារនិងយុវជន ផ្អែកគណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកទេស
- ជម្រុញការអប់រំចំណេះទូទៅឱ្យបានយ៉ាងហោចណាស់៩ឆ្នាំ ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងលើកកម្ពស់ការចូលរៀននៅថ្នាក់មធ្យមសិក្សា
- កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ រួមមានជំនាញទំនាក់ទំនងសង្គមក្នុងការដោះស្រាយបញ្ហា ការគោរពវិន័យកន្លែងធ្វើការ និងជំនាញជាច្រើន ដែលមានសារសំខាន់សម្រាប់ការអភិវឌ្ឍមូលដ្ឋានវិស័យឧស្សាហកម្ម
- ពង្រឹងការយល់ដឹងពីការចាប់អាជីព និងជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្តដើម្បីអភិវឌ្ឍន៍ជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលដែលមានស្រាប់
- ពង្រីកការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈនៅទីកន្លែង ដោយផ្តោតការយកចិត្តទុកដាក់លើពលករតាមរោងចក្រ ដើម្បីឲ្យពលករទាំងអស់ទទួលបានការអប់រំបណ្តុះបណ្តាល និងផ្តល់ក្តីសង្ឃឹម ក្នុងការអភិវឌ្ឍជំនាញ និងបច្ចេកទេសក្នុងពេលអនាគត។

### ២.៤.៤ ការបង្កើតការងារ និងលក្ខខណ្ឌការងារដែលល្អប្រសើរជាងមុន

ទិសដៅសំខាន់ៗក្នុងការងារនេះ គឺការបង្កើនកាលានុវត្តភាពការងារដែលមានសារប្រយោជន៍ទាំងក្នុងផ្នែករៀបរយនិងផ្នែកមិនរៀបរយ ការធ្វើឲ្យប្រសើរឡើង នូវការផ្គត់ផ្គង់ពលករមានគុណភាពនិងការលុបបំបាត់រូបភាពអាក្រក់បំផុតនៃពលកម្មកុមារ។ ឧស្សាហកម្មកាត់ដេរកើតឡើងយ៉ាងឆាប់រហ័ស បានធ្វើឲ្យមានការកែប្រែនៃស្ថានភាពការងារនៅទីប្រជុំជន តាមរយៈការបង្កើតការធ្វើឲ្យមានស្ថេរភាព ការងារដែលប្រើកម្លាំងពលកម្មច្រើនជាពិសេសសម្រាប់ស្ត្រីនិងក្មេងៗ ក៏ដូចជាក្នុងវិស័យផ្សេងៗទៀតដែរ គោលនយោបាយមួយដែលមានលក្ខខណ្ឌជាប្រព័ន្ធកំពុងត្រូវបានយកមកអនុវត្ត ដើម្បីបង្កើតការងារឲ្យបានច្រើនជាងមុន ជាពិសេសសម្រាប់ប្រជាជនដែលកំពុងចូលខ្លួនក្នុងទីផ្សារពលកម្ម និងសម្រាប់ពលកម្មកម្ពុជាទាំងអស់តាមរយៈវិធានការទាំងឡាយដូចតទៅ៖

- បង្កើតផលិតភាពកសិកម្ម ដើម្បីបង្កើតកាលានុវត្តភាពការងារនៅជនបទឲ្យបានច្រើនជាងមុនដែលនិងមានឥទ្ធិពលខ្លាំងទៅលើវិស័យជាច្រើនរួមបញ្ចូលទាំង តាមរយៈការបង្កើនតម្រូវការទំនិញ និងសេវាកម្មផ្សេងៗ

- លើកទឹកចិត្តការវិនិយោគផ្ទាល់ពីបរទេសនិងការវិនិយោគក្នុងស្រុកក្នុងវិស័យអាទិភាព ជាពិសេសកសិកម្ម កសិ-ឧស្សាហកម្មនិងគម្រោងដែលប្រើប្រាស់ពលកម្មច្រើន ព្រមទាំងវិស័យទេសចរណ៍
- បង្កើតបណ្តាញអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈផ្សេងៗទៀត ដើម្បីបម្រើដោយស្មើរភាពគ្នា ទាំងបុរសនិងស្ត្រី ជាពិសេសជនក្រីក្រ ជនពិការ និងក្រុមជនដែលងាយរងគ្រោះដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារសម្រាប់រយៈពេលខ្លី និងរយៈពេលវែង
- រៀបចំបង្កើតមូលដ្ឋានទិន្នន័យកម្លាំងពលកម្មមួយ និងប្រព័ន្ធស្ថិតិមួយដោយមានទិន្នន័យដែលបំបែកលម្អិតជាច្រើនប្រភេទ ដូចជាយេនឌ័រ ពិការភាព និងកត្តាផ្សេងទៀត ដែលទាក់ទងនឹងសង្គមកិច្ច
- ជួយពលករកម្ពុជាក្នុងការស្វែងរកការងារនៅបណ្តាប្រទេសផ្សេងទៀត។

### ២.៤.៥ ការកាត់បន្ថយការចំណាយខ្ពស់ សម្រាប់ឥណទានជនបទ

ឥណទានជនបទ គឺជាកត្តាមួយដ៏សម្ខាន់សម្រាប់ការពង្រីកសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលំទូលាយសម្រាប់ការអភិវឌ្ឍជនបទ និងសម្រាប់ការកាត់បន្ថយភាពក្រីក្រតាមរយៈការគាំទ្រផលិតកម្មកសិកម្ម និងការបង្កើត ការពង្រីកធុរកិច្ច (ជាពិសេសសហគ្រាសតូច និងមធ្យម) តាមរយៈការគាំទ្រផលិតភាព ការបង្កើតចំណូលព្រមទាំងសម្រាប់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។ ដើម្បីធានាឲ្យមានលទ្ធភាពច្រើនជាងមុន និងមានលក្ខណៈងាយស្រួលដល់អ្នកក្រ ក្នុងការទទួលបានឥណទាន ជាពិសេសសម្រាប់គោលបំណងធ្វើផលិតកម្ម រដ្ឋាភិបាលនឹងចាត់វិធានការដើម្បីពង្រីកនិងបន្ថយចំណាយខ្ពស់សម្រាប់ឥណទានជនបទតាមរយៈ៖

- ការពិនិត្យពិចារណា និងការជំរុញលើកទឹកចិត្តឲ្យមានការបង្កើតស្ថាប័នដូចជា សហករណ៍អ្នកប្រើប្រាស់ដែលមាននៅក្នុងតំបន់មួយចំនួននៃទ្វីបអាស៊ី
- ការធ្វើឲ្យប្រសើរឡើងការត្រួតពិនិត្យស្ថាប័នទាំងនេះ ដើម្បីធានាបានថាស្ថាប័នទាំងនេះពិតជាដំណើរការសមស្របទៅតាមគោលការណ៍
- កាត់បន្ថយអត្រាការប្រាក់ ដែលមានជាទូទៅតាមរយៈបទពិសោធន៍ដ៏ល្អប្រសើរធ្លាប់មានមកហើយ។

# ជំពូកទី៣

# ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ

ការវិភាគនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងយល់ទៅលើលទ្ធភាព ឱកាស មូលហេតុដែលនាំឱ្យមានគម្លាតស្តង់ដាជីវិតរស់នៅរវាងស្ត្រីដែលរស់នៅតំបន់ជនបទនិងទីក្រុង និងឧបសគ្គរាំង ព្រមទាំងដំណោះស្រាយទៅលើបញ្ហានៃការអភិវឌ្ឍស្ត្រី។ មិនតែប៉ុននោះ យើងក៏សិក្សាទៅលើមូលហេតុចំបងដែលទាមទារឱ្យមានការអភិវឌ្ឍ និងចំណុចដែលគួរចាប់ផ្តើមក្នុងការកែប្រែបរិបទរស់នៅរបស់ស្ត្រី ព្រមទាំងវិភាគទៅលើចំណុចខ្លាំងនិងចំណុចខ្សោយ ព្រមទាំងធ្វើការសិក្សាស្វែងយល់ពីឥទ្ធិពលនៃការអភិវឌ្ឍស្ត្រីមកលើសង្គមនិងសេដ្ឋកិច្ចផងដែរ។

## ៣.១. ទិន្នន័យនៃការស្រង់មតិ

### ៣.១.១. ការវិភាគបែបពិពណ៌នា

លទ្ធផលនៃការស្រង់មតិនេះ គឺទទួលបានពីការស្រង់មតិលើប្រជាជនទូទៅតាមរយៈប្រព័ន្ធអនឡាញ "Google Form Survey" ដែលប្រើប្រាស់បណ្តាញសង្គមនៅក្នុងប្រទេសកម្ពុជា ចំនួន ២១នាក់ ទាំងបុរសនិងស្ត្រី។ ដែលនៅក្នុងនោះមានស្ត្រី ១០នាក់ ដែលស្មើនឹង ៤៧.៦% និងបុរស១១នាក់ ស្មើនឹង ៥២.៤% និងស្ថិតក្នុងចន្លោះអាយុចាប់ពី ១៥ឆ្នាំ រហូតដល់ ៦០ឆ្នាំ។

**ក. ស្ថិតិអ្នកចូលរួមក្នុងការស្រង់មតិគិតតាមភេទ**




ប្រភព៖ ទិន្នន័យចម្បងបានមកពីការស្រង់មតិ

**ខ. ស្ថិតិអ្នកចូលរួមក្នុងការស្រង់មតិគិតតាមអាយុ**

ដោយពឹងផ្អែកទៅលើលទ្ធផលនៃការស្រង់មតិ យើងសង្កេតឃើញថាអ្នកដែលបានចូលរួមភាគច្រើនស្ថិតក្នុងចន្លោះអាយុចាប់ពី ១៥ឆ្នាំដល់២៥ឆ្នាំ ដែលមានចំនួនសរុបស្មើនឹង១៥នាក់ ត្រូវនឹង៧១.៤%នៃចំនួនអ្នកដែលចូលរួមស្រង់មតិសរុប។ ក្រៅពីនេះអ្នកដែលមានអាយុចន្លោះចាប់ពី ២៥ឆ្នាំដល់៣៥ឆ្នាំ មានចំនួន៥នាក់ស្មើនឹង ២៣.៨% និងអ្នកដែល

មានអាយុចាប់ពីអាយុ ៣៥ឆ្នាំដល់៤៥ឆ្នាំ មាន១នាក់ស្មើនឹង៤.៨% ហើយអ្នកដែលមានអាយុផ្សេងពីនេះមិនបានចូលរួមក្នុងការស្រង់មតិឡើយ។




ប្រភព៖ ទិន្នន័យចម្បង បានមកពីការស្រង់មតិ

### គ. ការយល់ឃើញរបស់អ្នកចូលរួមស្រង់មតិ ទៅលើមូលហេតុសំខាន់ដែលគួរតែមានការអភិវឌ្ឍទៅលើស្ត្រី

### ឃ. ចំណុចដែលគួរចាប់ផ្តើមក្នុងការអភិវឌ្ឍទៅលើស្ត្រី

យោងទៅតាមលទ្ធផលនៃការស្រង់មតិយើងសង្កេតឃើញថា អ្នកចូលរួមចំនួន១០នាក់យល់ថា ការអភិវឌ្ឍស្ត្រីគួរចាប់ផ្តើមចេញពីការពង្រឹងបន្ថែមទៅលើផ្នែកចំណេះដឹងមូលដ្ឋាន ដែលត្រូវនឹង៤៧.៦% ស្មើគ្នានឹងអ្នកចូលរួម ១០ នាក់ទៀតដែលយល់ឃើញថាដំណើរការអភិវឌ្ឍស្ត្រីគួរចាប់ផ្តើមចេញពីការកែប្រែទៅលើផ្នែកផ្នត់គំនិត ទស្សនវិស័យ និងការយល់ឃើញ។ ក្រៅពីនេះមានអ្នកចូលរួមក្នុងការស្រង់មតិចំនួន ១នាក់យល់ឃើញថា ការអភិវឌ្ឍស្ត្រីគួរចាប់ផ្តើមចេញពីការបណ្តុះបណ្តាលជំនាញ ដែលស្មើនឹង ៤.៨%។




ប្រភព៖ ទិន្នន័យចម្បង បានមកពីការស្រង់មតិ

យោងទៅតាមការធ្វើអង្កេតចំពោះជម្រើសនៃចំណុចចាប់ផ្តើមក្នុងការអភិវឌ្ឍស្ត្រី បានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

- ផ្នែកផ្នត់គំនិត ទស្សនវិស័យ និងការយល់ឃើញ
    - ធ្វើឱ្យស្ត្រីមានគំនិតវិជ្ជមាន និងអាចបន្តដំណើរក្នុងការស្វែងរកចំណេះដឹងផ្សេងៗទៀត
    - កែប្រែផ្នត់គំនិតចាស់បុរាណ ដែលដក់ជាប់ពីមួយជំនាន់ទៅមួយជំនាន់
    - ការយល់ដឹងផ្នែកផ្នត់គំនិត អាចផ្តល់អត្ថប្រយោជន៍ច្រើន
    - មានសារសំខាន់ក្នុងការឈានទៅដល់ការអភិវឌ្ឍចំណេះនិងជំនាញផ្សេងទៀត
    - ដោយសាសិទ្ធិសេរីភាពរបស់ស្ត្រីនៅកម្ពុជា មិនទាន់មានលក្ខណៈគ្រប់គ្រាន់និងទូលំទូលាយដូចមនុស្សប្រុស
    - ការកែប្រែផ្នត់គំនិត ជាដំណើរការនៃការផ្លាស់ប្តូរជីវិតដ៏សំខាន់
    - ជាកត្តាចម្បងក្នុងការជម្រុញស្មារតីស្ត្រីឱ្យចាប់ផ្តើមសកម្មភាពណាមួយ
    - កាត់បន្ថយការគិតបែបអវិជ្ជមាន ដែលជាឧបសគ្គរាំងស្ទះជីវិត។
- ផ្នែកចំណេះដឹងមូលដ្ឋាន
    - ជាគ្រឹះក្នុងការស្វែងយល់
    - ជាចំណេះដែលមានលក្ខណៈទូលំទូលាយ អាចបន្តពីម្តាយដល់កូន
    - អាចកែប្រែការគិតនិងទស្សនៈរបស់ស្ត្រី
    - ជាកត្តាសំខាន់ក្នុងការយល់ពីតម្លៃផ្ទាល់ខ្លួន យល់ពីសិទ្ធិ និងយល់ពីការងារទូទៅ
    - អាចប្រើប្រាស់ចំណេះដឹង ដើម្បីអភិវឌ្ឍន៍ខ្លួន
    - ងាយស្រួលក្នុងការចាប់យកជំនាញផ្សេងៗ ដោយពឹងទៅលើចំណេះដឹងដែលមានក្នុងខ្លួន។
- ផ្នែកជំនាញ
    - ល្អសម្រាប់ស្ត្រីក្នុងការអភិវឌ្ឍខ្លួន។

**ង. ឧបសគ្គរាំងស្ទះស្ត្រីមិនឱ្យទទួលបានការអភិវឌ្ឍខ្លួនពេញលេញ**

តាមរយៈលទ្ធផលនៃការស្រង់មតិយើងសង្កេតឃើញថា អ្នកចូលរួមចំនួន ១៣នាក់យល់ថា ចំណុចរាំងស្ទះការអភិវឌ្ឍស្ត្រីមិនឱ្យប្រព្រឹត្តទៅបានដោយរលូនបណ្តាលមកពី បញ្ហាផ្នត់គំនិតនិងប្រពៃណី ដែលត្រូវនឹង៦១.៩%នៃអ្នកចូលរួមក្នុងការស្រង់មតិសរុប។ ដោយឡែកអ្នកចូលរួម ៥នាក់ទៀតដែលត្រូវនឹងចំនួន២៤% យល់ឃើញថាឧបសគ្គនេះកើតចេញពីបញ្ហា កង្វះខាតការជម្រុញទឹកចិត្តទៅលើស្ត្រី។ ក្រៅពីនេះមានអ្នកចូលរួមក្នុងការស្រង់មតិចំនួន ១នាក់ និង២នាក់ទៀត

យល់ថា បញ្ហារាំងស្ទះស្ត្រីពីការអភិវឌ្ឍគឺបណ្តាលមកពី កង្វះខាតផ្នែកសេដ្ឋកិច្ច និងកង្វះខាតពេលវេលា ដែលស្មើនឹង ៥% និង៩% តាមលំដាប់។




ប្រភព៖ ទិន្នន័យចំបង បានមកពីការស្រង់មតិ

ឧបសគ្គដែលរារាំងដល់ដំណើរការនៃការអភិវឌ្ឍស្ត្រីនេះក៏បានជះឥទ្ធិពលទៅលើស្ថានភាពគម្លាតស្តង់ដានៃជីវភាពរស់នៅរបស់ស្ត្រីដែលរស់នៅតាមតំបន់ជនបទនិងទីក្រុងផងដែរ។ ដោយយោងទៅតាមលទ្ធផលនៃការស្រង់មតិ យើងសង្កេតឃើញថា បញ្ហានេះកើតចេញពីមូលហេតុរួមមួយគឺ ផ្នត់គំនិតប្រពៃណីដែលដាក់គំនាបទៅលើស្ត្រី ជាពិសេសការមិនឱ្យកូនស្រីរៀនបានខ្ពង់ខ្ពស់ ជាហេតុធ្វើឱ្យស្ត្រីនៅតំបន់ជនបទមានចំណេះដឹងតិច មិនសូវដឹងពីរបៀបរបបក្នុងការចូលរួមក្នុងកិច្ចការសង្គមបានច្រើន។ ម្យ៉ាងវិញទៀតកត្តានេះហើយ ដែលធ្វើឱ្យស្ត្រីភាគច្រើន ជាពិសេសអ្នកដែលរស់នៅតំបន់ជនបទខ្វះទំនុកចិត្តនិងមិនទទួលបានការជម្រុញផ្តល់កម្លាំងចិត្តបន្ថែមផងនោះ ទើបធ្វើស្ត្រីជាច្រើនរូបពិបាកក្នុងការឈោងចាប់នូវឱកាសក្នុងការអភិវឌ្ឍខ្លួននិងប្រើប្រាស់ទេពកោសល្យឱ្យអស់ពីលទ្ធភាព ដែលនេះជាការខាតបង់ធនធានមនុស្សរបស់ប្រទេសជាតិអស់មួយផ្នែក។

មិនតែប៉ុណ្ណោះ ដោយសាបញ្ហាចំណេះដឹងនៅមានកម្រិតនិងផ្នត់គំនិតនៅមានលក្ខណៈបុរាណ ធ្វើឱ្យស្តង់ដានៃជីវភាពរស់នៅរបស់ស្ត្រីនៅតំបន់ជនបទភាគច្រើនមានគម្លាតខុសគ្នាឆ្ងាយពីស្ត្រីដែលរស់នៅទីក្រុង ឬអ្នកដែលរស់នៅតំបន់ជាមួយគ្នាតែមានការយល់ឃើញកម្រិតខុសគ្នា ដែលការណ៍នេះគេអាចសង្កេតមើលតាមរយៈរបៀបរបបរស់នៅ ការថែរក្សារូបរាងមុខមាត់ ការតុបតែងខ្លួន និងការយល់ដឹងទាក់ទងទៅនឹងការថែទាំសុខភាព-អនាម័យផ្ទាល់ខ្លួន ព្រមទាំងសមត្ថភាពក្នុងការទំនាក់ទំនងនៅក្នុងសង្គមនិងការយល់ដឹងពីសិទ្ធិក្នុងការការពារខ្លួនផងដែរ។

### ៣.១.២. ការវិភាគលើឥទ្ធិពលនៃការអភិវឌ្ឍនៅលើសង្គម និងសេដ្ឋកិច្ច

#### ៣.១.២.១. ឥទ្ធិពលនៃការអភិវឌ្ឍស្ត្រីទៅលើសង្គម

ការអភិវឌ្ឍស្ត្រី បានជះឥទ្ធិពលយ៉ាងធំធេងទៅលើផ្នែកសង្គមកិច្ច ដោយហេតុថា កាលណាស្ត្រីមានចំណេះដឹងនិងសមត្ថភាពកាន់តែពូកែ ស្ត្រីអាចប្រើប្រាស់សមត្ថភាពនោះទៅធ្វើការចូលរួមដឹកនាំប្រទេស តាម

រយៈការបង្កើតឱ្យមានធនធានមនុស្សល្អៗកាន់តែច្រើនឡើង ឆ្លងតាមការអប់រំប្រៀនប្រដៅ និងការតម្រែតម្រង់ទិសបុត្រធីតាឱ្យដើរនៅលើគន្លងផ្លូវដ៏ត្រឹមត្រូវក្លាយជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ។

ក្រៅពីនេះ ស្ត្រីក៏មានសក្តានុពលក្នុងការដឹកនាំសង្គម តាមរយៈការចូលរួមទៅក្នុងផ្នែកវិស័យសេវាសាធារណមានដូចជាការធ្វើជា គ្រូពេទ្យ គ្រូបង្រៀន មន្ត្រីនៅតាមគ្រឹះស្ថានថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក៏ដូចជាការចូលរួមនៅក្នុងវិស័យឯកជនផងដែរ។ មិនតែប៉ុណ្ណោះ ស្ត្រីក៏នៅមានផលិតភាពពិសេសក្នុងការជ្រែកខ្លួនបំពេញតួនាទីច្រើនយ៉ាងបានក្នុងពេលតែមួយ ក្រោមរូបភាពជាស្ត្រីមេផ្ទះផង ជាពលរដ្ឋដែលចូលរួមក្នុងកិច្ចការសង្គមបានផងដែរ។

### ៣.១.២.២. ឥទ្ធិពលនៃការអភិវឌ្ឍស្ត្រី នៅលើផ្នែកសេដ្ឋកិច្ច

ក្រៅពីចូលរួមនៅក្នុងការងារសង្គមកិច្ច ស្ត្រីក៏ជាភ្នាក់ងារដែលប្រកបដោយសមត្ថភាពខ្ពស់ក្នុងការងាសេដ្ឋកិច្ចផងដែរ ដោយយោងទៅតាមការសិក្សាយើងបានដឹងថា ស្ត្រីជាអ្នកចូលរួមដ៏មមារញឹកទៅក្នុងការងារផ្នែកកសិកម្ម សេវាកម្ម ឧស្សាហកម្ម និងជាម្ចាស់អាជីវកម្មសហគ្រាសធុនតូចនិងមធ្យមផងដែរ ដែលការងារទាំងអស់នេះជាធាតុដ៏សំខាន់ក្នុងការជួយលើកស្ទួយសេដ្ឋកិច្ចជាតិឱ្យមានកំណើន។ មិនតែប៉ុណ្ណោះ ស្ត្រីក៏មានទេពកោសល្យពិសេសក្នុងការធ្វើការងារធុរកិច្ច ទាំងតាមបែបប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ ហើយស្ត្រីក៏អាចចរចាជំនួបពាណិជ្ជកម្ម ទាក់ទាញការវិនិយោគពីបរទេសមកបង្កើនចំណូលជាតិបានថែមទៀតផង។

ប្រការនេះបានបង្ហាញថា កាលណាមានការអភិវឌ្ឍទៅលើស្ត្រីកាន់តែច្រើនទៅលើផ្នែកសេដ្ឋកិច្ច ដូចជាការផ្តល់សេវាឥណទាន ការបណ្តុះបណ្តាលវគ្គសិក្សាខ្លីៗទាក់ទងនឹងផ្នែកអាជីវកម្មឱ្យកាន់តែបានច្រើន នោះស្ត្រីនឹងកាន់តែមានឱកាសខ្ពស់ក្នុងការរួមចំណែកពន្លឿនល្បឿនកំណើនសេដ្ឋកិច្ចជាតិផងដែរ។

# សេចក្ដីសន្និដ្ឋាន និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគលទ្ធផលក្នុងការស្រង់មតិទាក់ទងនឹងការអភិវឌ្ឍស្ត្រីរួចមក យើងឃើញថា ដំណើរការនៃការអភិវឌ្ឍនេះនៅមានលក្ខណៈយឺត និងមិនទាន់មានភាពទូលំទូលាយទេ ពីព្រោះជីវភាពក្នុងការរស់នៅរបស់ស្ត្រីនៅតំបន់ជនបទនៅតែជួបប្រទះនឹងបញ្ហា ព្រមទាំងមិនទាន់មានលក្ខណៈជឿនលឿននៅក្នុងការការបង្កើតវិធីសាស្ត្រដោះស្រាយនៅឡើយ។

ម្យ៉ាងវិញទៀត នៅក្នុងការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា ការផ្សព្វផ្សាយអំពីគោលនយោបាយសមភាពយេនឌ័រនៅតាមតំបន់មូលដ្ឋាន នៅតែមានលក្ខណៈតិចតួច ជាហេតុធ្វើឱ្យស្ត្រីនៅតែបន្តរស់ជាមួយនឹងគំនាបសង្គម ផ្នត់គំនិតអវិជ្ជមាន និងមានភាពលំបាកក្នុងការទទួលបានឱកាសទាំងផ្នែកសាធារណៈ សន្តិសុខសុវត្ថិភាព និងការទទួលបានការអប់រំឱ្យបានដឹតដល់ ទោះបីជាមានការបង្កើតច្បាប់ការពារសិទ្ធិស្ត្រីពីសំណាក់រាជរដ្ឋាភិបាលហើយក៏ដោយ។ ម្យ៉ាងវិញទៀតមូលហេតុសំខាន់ជំមួយ ដែលក្លាយជារនាំងរាំងស្ទះដល់ការអភិវឌ្ឍ គឺបណ្តាលមកពីស្ត្រីមិនមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការក្រោកឈរនិងពុះពារជំនះឧបសគ្គ ហើយឆាប់ចុះចាញ់នឹងទស្សនៈសាធារណៈ។ មិនតែប៉ុណ្ណោះ ដោយសារដំណើរការនៃការអភិវឌ្ឍ និងការធ្វើកំណែទម្រង់នៅមានភាពមិនវិសមភាពរវាងទីក្រុងនិងជនបទផងដែរ ទើនបានជាសង្គមជនបទមានការវិវត្តយឺតនិងមានគម្លាតស្តង់ដាជីវភាពខុសគ្នាច្រើន ដែលធ្វើឱ្យស្ត្រីនៅតំបន់ដាច់ស្រយ៉ាលហាក់មានឱកាសតិច និងពុំសូវទទួលបានការធ្វើទំនើបកម្មកម្រិតនៃការរស់នៅឱ្យមានលក្ខណៈរីកចម្រើន។

ជារួមមក យើងអាចសន្និដ្ឋានបានថា ដើម្បីឱ្យការអភិវឌ្ឍស្ត្រីអាចប្រព្រឹត្តទៅបានដោយរលូន គេត្រូវយកចិត្តទុកដាក់ឱ្យបានខ្ពស់ជាពិសេសទៅលើការពង្រីកផ្នែកប្រព័ន្ធអប់រំឱ្យកាន់តែមានវិសាលភាពនៅតំបន់ជនបទ ដើម្បីអាចឱ្យស្ត្រីនិងក្មេងស្រីមានលទ្ធភាពខ្ពស់ក្នុងការចូលរួមទទួលយកការសិក្សាពីប្រព័ន្ធអប់រំ ដើម្បីធ្វើឱ្យពួកគេមានចំណេះដឹងខ្ពស់ មានទស្សនវិស័យវែងឆ្ងាយជាងមុន និងដើម្បីកាត់បន្ថយការយល់ខុសទៅតាមប្រពៃណីទំណៀមទម្លាប់ដែលចងជីវិតស្ត្រីរហូតមក និងដើម្បីអាចឱ្យស្ត្រីមានគំនិតក្នុងការអភិវឌ្ឍខ្លួន ព្រមទាំងអាចក្លាយជាធនធានដ៏មានតម្លៃ មានសមត្ថភាពនិងផលិតភាពក្នុងការជួយជ្រោមជ្រែងខ្លួនឯង គ្រួសារ និងសង្គមជាតិ។ ហើយដំណើរការនៃការអភិវឌ្ឍស្ត្រីនេះ ក៏អាចផ្តល់ផលវិជ្ជមានដល់ការពង្រឹងទៅលើវិស័យសេដ្ឋកិច្ច តាមរយៈសកម្មភាពក្នុងការប្រកបអាជីវកម្មរបស់ស្ត្រីបានថែមទៀតផង។

## ២. អនុសាសន៍

យោងទៅតាមការសិក្សា យើងឃើញថា ក្នុងដំណើរការនៃការអភិវឌ្ឍស្ត្រី ទាំងរាជរដ្ឋាភិបាល ស្ត្រីខ្លួនឯង និងភាគីដែលរួមចំណែកក្នុងការអភិវឌ្ឍទាំងអស់ អាចជម្រុញការធ្វើការកែប្រែឱ្យមានភាពប្រសើរឡើងនេះ តាមរយៈការលើកកម្ពស់ការវិនិយោគទៅលើផ្នែកសមត្ថភាព ការយល់ដឹង ជំនាញ និងផ្នត់គំនិតស្ត្រី តាមរយៈការផ្តល់ឱកាសក្នុងការសម្រេចចិត្ត បើកចិត្តទូលាយទទួលយកមតិនិងស្តាប់សម្លេងនៃការយល់ឃើញរបស់ស្ត្រី ព្រមទាំងផ្តល់តម្លៃដល់ស្ត្រីឱ្យក្នុងភាពជាមនុស្សឱ្យបានច្រើនជាងមុន ឬអាចធ្វើការកែប្រែតាមរយៈការបង្កើតសកម្មភាពមួយចំនួនដូចខាងក្រោម៖

- សម្រាប់ស្ត្រី
    - កសាងភាពក្លាហានក្នុងខ្លួន
    - ស្វែងរកចំណេះដឹងបន្ថែម
    - ផ្តល់ឱកាសដល់ខ្លួនឯងក្នុងការចូលរួមទៅក្នុងកម្មវិធីសង្គមផ្សេងៗ
    - ធ្វើការប្តេជ្ញាចិត្តក្នុងការដើរតាមក្តីស្រម៉ៃដោយភាពត្រឹមត្រូវ
    - ស្វែងយល់និងសិក្សាពីខ្លួនឯង និងស្គាល់ខ្លួនឯងឱ្យបានច្បាស់លាស់
    - ចេញទៅខាងក្រៅ ជួបមនុស្សថ្មីៗ ផ្លាស់ប្តូរគំនិតយោបល់ ដើម្បីទទួលបានទស្សនថ្មីសម្រាប់ស្ថាបនាខ្លួន
    - រៀនសូត្រពេញមួយជីវិត ទាំងក្នុងសាលា និងក្នុងការរស់នៅប្រចាំថ្ងៃ
    - បង្កើតទស្សនវិស័យ រៀបចំផែនការ និងកំណត់គោលដៅជីវិតផ្ទាល់ខ្លួន
    - រៀនធ្វើការវាយតម្លៃពីខ្លួនឯង ទាំងផ្នែកសកម្មភាពនិងសមត្ថភាព។
- សម្រាប់ថ្នាក់ដឹកនាំ និងភាគីពាក់ព័ន្ធ
    - ជម្រុញបន្ថែមលើសកម្មភាពនៃការលើកកម្ពស់ស្ត្រី
    - ផ្តល់តួនាទីនិងសិទ្ធិអំណាចដល់ស្ត្រីក្នុងការដឹកនាំ និងការសម្រេចចិត្ត
    - បង្កើនការផ្តល់តម្លៃដល់ស្ត្រី និងការងាររបស់ស្ត្រី
    - បង្កើនការអភិវឌ្ឍនៅតំបន់នៅតំបន់ជនបទឱ្យបានកាន់ច្រើន ដើម្បីឱ្យមនុស្សអាចតាមទាន់សង្គមនិងមានការផ្លាស់ប្តូរផ្នត់គំនិតជាថ្មី
    - បង្កើតកម្មវិធី ឬការស្វែងយល់ពីឋានៈនិងតួនាទីស្ត្រីនៅក្នុងសង្គម
    - លើកកម្ពស់ការការពារសិទ្ធិស្ត្រីនៅក្នុងគ្រប់បរិបទទាំងអស់។

# ឯកសារយោង

## ឯកសារយោងជាភាសាខ្មែរ

- សៀវភៅសារណាបញ្ចប់ការសិក្សា ការអភិវឌ្ឍសហគមន *៍ទំព័រទី *5
- សៀវភៅ សេដ្ឋកិច្ចអភិវឌ្ឍ ភាគទី២, រៀបរៀងដោយសាស្ត្រាចារ្យ យ៉ែម សំបូរបរិញ្ញាបត្រសេដ្ឋកិច្ច) អភិវឌ្ឍន៍ ឆ្នាំទី៤(
- សារណាបញ្ចប់ការសិក្សា, កម្មវិធីអភិវឌ្ឍរបស់ឃុំឆ្លូង ខេត្តក្រចេះ, ឆ្នាំ 2002-2006
- វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជជួនណាត
- សារណាបញ្ចប់ការសិក្សា *ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈការដាំបន្លែ *, និស្សិតអ៊ី :ិន សុភា និង ឡាញ់ ស្រីនាថ
- សារណាបញ្ចប់ការសិក្សា *ការអភិវឌ្ឍសហគមន៏*, និស្សិតមឿន ចាន់សុផាន់ម៉ៃ និ :ង ច្រឹង វ៉ាន់ឆ្នើម
- សារណាបញ្ចប់ការសិក្សា *ការអភិវឌ្ឍជនបទ ឃុំព្រែករ៉េ ស្រុកល្វាឯម ខេត្តកណ្តាល*, និស្សិតព្រុំ : បញ្ញា និង ហួ លីហួង
- របាយការណ៍កម្មសិក្សា ការអភិវឌ្ឍវិ*ស័យកសិកម្មសហគមន៏ត្រពាំងសង្កែ*, និស្សិតឡុង សុជា និ :ង សុត វុន, ទំព័រទី៨
- របាយការណ៍កម្មសិក្សា *ការអភិវឌ្ឍវិស័យចិញ្ចឹមមាន់សាច់នៅក្នុងឃុំដំណាក់អំពិល*, និស្សិតៈ សួន ស៊ីវហ៊ាន
- របាយការណ៍ជាតិលើកទី ៤ និង ៥ ស្ត្រីពីការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ
- របាយការណ៍សិក្សាស្រាវជ្រាវស្តីពីបញ្ហាយេនឌ័រថ្មីៗក្នុងចំណោមស្ត្រី ក្មេងស្រី និងយុវវ័យនៅកម្ពុជា ក្រសួងកិច្ចការនារី ឆ្នាំ២០១១
- យុទ្ធសាស្ត្រនារីរតនៈទី៤ រៀបរៀងដោយ ក្រសួងកិច្ចការនារី ឆ្នាំ ២០១៤
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០១៨ ទំព័រទី៥២ ដល់ទំព័រទី៥៥
- ឥរិយាបថទំនាក់ទំនង និងឥរិយាបថយេនឌ័រ, ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា ឆ្នាំ ២០១៤ ទំព័រទី៤ ទី៥ ទី៦ ទី៧ ទី១៧ ទី១៩
- វិស័យអប់រំ យេនឌ័រក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ, ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា ឆ្នាំ២០១៤ ទំព័រទី៣ ទី៤ ទី៦

- សេដ្ឋកិច្ច ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី, ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា ឆ្នាំ ២០១៤ ទំព័រទី៧


**ឯកសារជាគេហទំព័រ**


- https://sid-israel.org/en/what-is-development/

  (Society of International Development) Issue in development (Wednesday,17 in February 2021)
- https://www.sociologydiscussion.com/society/development-meaning-and-concept-of-development/688

  (Sociology Discussion) Development: Meaning and Concept of Development (Article shared by : Shel Ly Sha)
- សេចក្ដីថ្លែងការក្នុងសិក្ខាសាលាផ្សព្វផ្សាយផែនការ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យទេសចរណ៍ ដំណាក់កាលទី ៣ ឆ្នាំ ២០១៦២០១៨-, ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ០៥ ០៤: ចុះផ្សាយដោយhttps://kohsantepheapdaily.com.kh/article/139994.html
- https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/ad09fe42e30ef7fa67eaab4e7afe0726_1502983067.pdf
- (គោលនយោបាយ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម
- https://www.un.org/womenwatch/feature/ruralwomen/facts-figures.html

  (https://www.un.org/womenwatch/feature/ruralwomen/facts-figures.html
- https://m.postkhmer.com/វិភាគសង្គមនិងបទដ្ឋានយេនឌ័រលើតួនាទីស្ត្រីគួរ-ផ្ទត់គំនិតសង្គម/លើកមកនិយាយឡើងវិញ

  (https://newsroomcambodia.com/newsroom/2021/03/16/blog-three-sources-of-population-facing-economic-hardships/amp/)
- https://newsroomcambodia.com/newsroom/2021/03/16/blog-three-sources-of-population-facing-economic-hardships/amp/

  (https://newsroomcambodia.com/newsroom/2021/03/16/blog-three-sources-of-population-facing-economic-hardships/amp/)

- https://www.google.com/amp/s/amp.rfi.fr/km/big%2520gap%2520between%2520phnom%2520penh%2520city%2520and%2520countryside (https://www.google.com/amp/s/amp.rfi.fr/km/big%2520gap%2520between%2520phnom%2520penh%2520city%2520and%2520countryside)
- http://nac.org.kh/article/4990#.YO-zg2QwrDs (http://nac.org.kh/article/4990#.YO-zg2QwrDs)
- https://www.healthline.com/health/13-self-love-habits-every-woman-needs-to-have#13.-Be-kind-to-yourself (https://www.healthline.com/health/13-self-love-habits-every-woman-needs-to-have#13.-Be-kind-to-yourself)
- https://socialeurope.eu/inequality-essential-wellbeing (https://socialeurope.eu/inequality-essential-wellbeing)
- https://www.grossnationalhappiness.com (https://www.grossnationalhappiness.com/9-domains/standard-of-living-and-happiness/)
- https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/0a1f397d2ff067ef0050337d8316fe91_1502983118.pdf (https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/0a1f397d2ff067ef0050337d8316fe91_1502983118.pdf)(ទំព័រ 95-97)
- https://www.mrd.gov.kh/download/104/%E1%9E%AF%E1%9E%80%E1%9E%9F%E1%9E%B6%E1%9E%9A%E1%9E%94%E1%9F%84%E1%9F%87%E1%9E%96%E1%9E%BB%E1%9E%98%E1%9F%92%E1%9E%96/2485/%E1%9E%95%E1%9F%82%E1%9E%93%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%99%E1%9E%BB%E1%9E%91%E1%9F%92%E1%9E%92%E1%9E%9F%E1%9E%B6%E1%9E%9F%E1%9F%92%E1%9E%8F%E1%9F%92%E1%9E%9A%E1%9E%90%E1%9E%9C%E1%9E%B7%E1%9E%80.pdf

(https://www.mrd.gov.kh/download/104/%E1%9E%AF%E1%9E%80%E1%9E%9F%E1%9E%B6%E1%9E%9A%E1%9E%94%E1%9F%84%E1%9F%87%E1%9E%96%E1%9E%BB%E1%9E%98%E1%9F%92%E1%9E%96/2485/%E1%9E%95%E1%9F%82%E1%9E%93%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%99%E1%9E%BB%E1%9E%91%E1%9F%92%E1%9E%92%E1%9E%9F%E1%9E%B6%E1%9E%9F%E1%9F%92%E1%9E%8F%E1%9F%92%E1%9E%9A%E1%9E%90%E1%9E%9C%E1%9E%B7%E1%9E%80.pdf) (ទំព័រ17 ចំនុច3 កម្មវិធីទី៣(ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ :

- http://tvetsdp.ntb.gov.kh/wp-content/uploads/2017/01/Gender-Policy-and-Action-Plan-2017-2026-kh.pdf (http://tvetsdp.ntb.gov.kh/wp-content/uploads/2017/01/Gender-Policy-and-Action-Plan-2017-2026-kh.pdf)
- https://data.opendevelopmentmekong.net/dataset/00dfeab5-a5c1-428b-9cfa-9e5e1a802bc3/resource/16b93acf-3a06-4b92-a24a-354c5c42a010/download/1-introduction.pdf (https://data.opendevelopmentmekong.net/dataset/00dfeab5-a5c1-428b-9cfa-9e5e1a802bc3/resource/16b93acf-3a06-4b92-a24a-354c5c42a010/download/1-introduction.pdf)
- http://ticambodia.org/library/wp-content/files_mf/14510985531450163070industrypolicy.pdf (http://ticambodia.org/library/wpcontent/files_mf/14510985531450163070industrypolicy.pdf)ទំព័រ៣៩ (http://ticambodia.org/library/wp-content/files_mf/14510985531450163070industrypolicy.pdf)
- https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/0a1f397d2ff067ef0050337d8316fe91_1502983118.pdf

https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/0a1f397d2ff067ef0050337d8316fe91_1502983118.pdf (https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/0a1f397d2ff067ef0050337d8316fe91_1502983118.pdf)

- https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/0a1f397d2ff067ef0050337d8316fe91_1502983118.pdf (https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/0a1f397d2ff067ef0050337d8316fe91_1502983118.pdf)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១ ៖ កម្រងសំណួរ

---

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Royal University of Law and Economics

---

## កម្រងសំណួរសម្រាប់ស្ថិតិស្តីពីការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ

**ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ** ជាការស្រាវជ្រាវមួយរបស់និស្សិតបរិញ្ញាប័ត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ក្នុងគោលបំណងសិក្សាស្វែងយល់ទៅលើលទ្ធភាព ឱកាស និងឧបសគ្គរារាំង ព្រមទាំងដំណោះស្រាយទៅលើបញ្ហានៃការអភិវឌ្ឍស្ត្រី ដើម្បីអាចឱ្យពួកគាត់ទទួលបានឱកាសក្នុងការអភិវឌ្ឍន៍ខ្លួន ពង្រឹងសមត្ថភាព និងបញ្ចេញនូវសក្តានុពលរបស់ខ្លួនទៅក្នុងសង្គម។

សូមអរគុណសម្រាប់ការចូលរួមក្នុងការស្រង់មតិរបស់បងប្អូនទាំងអស់គ្នា!

- សម្រាប់សំណួរដែលមានសញ្ញាផ្កាយ ជាសំណួរដែលត្រូវតែឆ្លើយជាចាំបាច់
- សូមចុចលើប្រអប់នៅពីមុខចម្លើយ ដើម្បីជ្រើសរើស

១. សូមជ្រើសរើសភេទរបស់អ្នក

☐ ស្ត្រី

☐ បុរស

☐ ផ្សេងៗ

២. សូមជ្រើសរើសអាយុរបស់អ្នក

☐ ១៥ ដល់ ២៥ឆ្នាំ

☐ ២៥ ដល់ ៣៥ឆ្នាំ

☐ ៣៥ ដល់ ៤៥ឆ្នាំ

☐ ៤៥ ដល់ ៦០ឆ្នាំ

☐ លើសពី ៦០ឆ្នាំ

៣. តើអ្នកគិតថា អ្វីជាមូលហេតុសំខាន់បំផុតដែលទាមទារឱ្យមានការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៤. តើអ្នកគិតថា ការអភិវឌ្ឍស្ត្រីគួរផ្តើមចេញពីចំណុចណា?

□ ផ្នែកចំណេះដឹងមូលដ្ឋាន

□ ផ្នែកជំនាញ

□ ផ្នែកផ្នត់គំនិត ទស្សនវិស័យ និងការយល់ឃើញ

៥. ហេតុអ្វី បានជាអ្នកគិតថា ចំណុចដែលអ្នកបានជ្រើសរើសនៅក្នុងសំណួរទី៤ ជាចំណុចសំខាន់?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៦. តើអ្នកគិតថា អ្វីជាឧបសគ្គរាំងស្ត្រីមិនឱ្យទទួលបានការអភិវឌ្ឍខ្លួនពេញលេញ?

□ បញ្ហាផ្នត់គំនិតប្រពៃណី

□ កង្វះខាតផ្នែកសេដ្ឋកិច្ច

□ កង្វះខាតពេលវេលា

□ កង្វះខាតការជម្រុញទឹកចិត្ត

៧. តើអ្នកគិតថា អ្វីជាមូលហេតុធ្វើឱ្យមានគម្លាតស្តង់ដាជីវភាពរស់នៅរវាងស្ត្រីនៅជនបទ និងទីក្រុង?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………………

៨. តើអ្នកគិតថា ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទអាចផ្តល់ផលវិជ្ជមានអ្វីខ្លះដល់សង្គម និងសេដ្ឋកិច្ច?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៩. តើអ្នកគិតថា ការអភិវឌ្ឍស្ត្រីនៅតំបន់ជនបទសំខាន់ឬទេ?

 សំខាន់ខ្លាំង

 សំខាន់

 ធម្មតា - មិនចាប់អារម្មណ៍

 មិនសំខាន់

១០. សូមបង្ហាញពីចំណាប់អារម្មណ៍ (ការយល់ឃើញ) របស់អ្នក ទៅលើការអភិវឌ្ឍស្ត្រី?

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

សូមអរគុណ សម្រាប់ការចូលរួម!

# ឧបសម្ព័ន្ធទី២ ៖ រូបភាពមួយចំនួនរបស់ស្ត្រី

## ១. លក្ខណៈខុសគ្នារបស់ស្ត្រីនៅតំបន់ជនបទ និងទីក្រុង



រូបភាពរបស់ស្ត្រីនៅតំបន់ជនបទ[i]



រូបភាពរបស់ស្ត្រីនៅទីក្រុង[ii]

## ២. សកម្មភាពរបស់ស្ត្រីចូលរួមក្នុងការងារសង្គម និងសេដ្ឋកិច្ច



សកម្មភាពចូលរួមប្រជុំក្នុងការងារ[iii]



ការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច (ធុរកិច្ច)[iv]

---

[i] រូបភាពដកស្រង់ចេញពីគេហទំព័រ៖ http://www.oxfamamerica.org/explore/stories/brutal-attack-stiffens-cambodian-womans-resovle-to-protect-forest/

[ii] រូបភាពដកស្រង់ចេញពីបណ្តាញសង្គម facebook របស់លោកស្រី វ៉េង សេរីវឌ្ឍនា (Veng Serei Vatthana)

[iii] រូបភាពដកស្រង់ចេញពីគណនីបណ្តាញសង្គម facebook របស់លោកស្រី វ៉េង សេរីវឌ្ឍនា

[iv] រូបភាពដក់ស្រង់ចេញពីគណនីបណ្តាញសង្គម facebook របស់លោកស្រី វ៉េង សេរីវឌ្ឍនា